# ពុទ្ធព្យាករណ៍



អ្នកមានស្មារតីពោលពាក្យពិត មិនចង់តាមចិត្តនឹកឃើញថា
ខុសត្រូវនៅលើពិចារណា ដោះស្រាយបញ្ហាបានយ៉ាងល្អ

រៀបរៀងដោយ
ឧបាសក នា សុខា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

# ពុទ្ធព្យាករណ៍

## ឆ្នាំ មមី ចត្វាស័ក ព.ស ២៥៤៦

រៀបរៀងដោយ

ឧបាសក សា សុខា

*Tel : 011 673 406*

បានស្កានឡើងវិញសម្រាប់ជាធម្មទាន
ដែលបានអនុញ្ញាតដោយ ឧបាសក នា សុខា

Scan by:

www.5000-years.org

# ពុទ្ធព្យាករណ៍

រៀបរៀង

ដោយ

ឧបាសក នា សុខា

# អារម្ភកថា

ការប្រកាន់អ្វីៗថាជារបស់ខ្លួន ពុំមានសារៈខ្លឹមសារអ្វីសោះ ដោយពុំបានលាងជំរះនូវចិត្តឱ្យបានស្អាតល្អ ដែលជាហេតុធ្វើចិត្តឱ្យកខ្វក់ប្រឡាក់ជាប់នូវគ្រឿងសៅហ្មង មិនងាយបោសសំអាតជ្រះស្រឡះបាន ។ ក្នុងនោះមានព្រះពុទ្ធបញ្ញត្តិជាច្រើនតាមគម្ពីរព្រះត្រៃបិដក ដូចជាសុបិន ១៦ ប្រការជាដើម មាននៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតក សត្តម ភាគ ៥៨ និងអដ្ឋកថា ខុទ្ទកនិកាយ ឯកនិបាតជាតក ជំពូក ទី ៣ ភាគទី ២ លេខ ៥៦ យកមកធ្វើអត្ថាធិប្បាយនូវពុទ្ធដិកា ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្យាករ ។

សៀវភៅនេះមានចំណងជើងថា "**ពុទ្ធព្យាករណ៍**"។ ពាក្យថា " **ព្យាករ** " កិ.( បា. សំ -វ្យា-) ធ្វើឱ្យជាក់ច្បាស់ ធ្វើឱ្យប្រាកដ នេះជាពាក្យកិរិយាសព្ទដែលមាន នៅក្នុងវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជគណៈមហានិកាយ **ជួន ណាត ជោតញ្ញាណោ**។ ន័យមួយទៀតជា "នាម "។

ពាក្យថា **ព្យាករណ៍** ( បា.ព្យាករណ ឬ វ្យា.សំ.វ្យា)

ការធ្វើឱ្យប្រាកដ ឱ្យជាក់ច្បាស់។ ឧ. វេយ្យាករណ៍ ពុទ្ធព្យាករណ៍។

ឯពាក្យថា " **សុបិន** " នៅក្នុងវចនានុក្រមដដែល មានន័យថា សុបិន (បា.សំ.:ស្វប្ន)គឺការដេកលក់ ។ ច្រើនប្រើសំដៅសេចក្តីថា " ការយល់សប្តិឃើញ " ដូចជាយប់មិញខ្ញុំមានសុបិនមិនល្អ ។ សុបិននិមិត្តបានសេចក្តីថា ការយល់សប្តិឃើញ មានទំនងជាគ្រឿងសំគាល់ (ថានឹងមានផលអាក្រក់ឬល្អ) ។ សុបិននិមិត្តកើតនៅក្នុង" សុបិនមនោទ្វារវិថី " មិនកើតនៅក្នុងភវង្គទេ ព្រោះភវង្គជាអង្គភព គឺកន្លែងរបស់ចិត្តសម្រាប់ជ្រកនៅ ។ ពេលណាមានអារម្មណ៍តាមបញ្ចទ្វារឬធម្មារម្មណ៍តាមមនោទ្វារ ចិត្តកើតឡើងកាត់ផ្តាច់ខ្សែភវង្គឡើងកាន់វិថី ពេលនោះមនុស្សយើងដឹងខ្លួន ឬភ្ញាក់ពីសម្រាន្ត ឯ " សុបិនមនោទ្វារវិថី " មិនដូច្នោះទេ ពិតមែនមានមនោទ្វារវិថី ប៉ុន្តែមនោទ្វារវិថីនេះ ឋិតនៅត្រឹមតែជាការយល់សប្តិ គឺ ដេកលក់ គ្រាន់តែមានវិថីចិត្តដឹងរឿងរ៉ាវប៉ុណ្ណោះ ព្រោះ ប្រព្រឹត្តទៅមិនដឹងខ្លួននេះឯងហៅថា " សុបិនមនោទ្វារវិថីចិត្ត " ។

នៅក្នុងគម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ មានសំដែងអំពីសុបិន ៤ យ៉ាងដូចតទៅនេះ :-

**១-ធាតុក្ខោភៈ** សុបិន ព្រោះមានធាតុកំរើក ដោយទឹកប្រមាត់ ដូចជាពេលមានជម្ងឺផ្សេងៗ ។

**២-អនុភូតបុព្វៈ** សុបិន ព្រោះចិត្តតោងចាប់យកអារម្មណ៍ណាមួយដែលធ្លាប់អនុលោមធ្វើកន្លងមក ឬ ធ្លាប់ជួបប្រទះតាមទ្វារ ៦ មានចក្ខុទ្វារ សោតទ្វារ ជីវ្ហាទ្វារ កាយទ្វារ និងមនោទ្វារជាដើម ។

**៣-ទេវតោបសំហារៈ** សុបិន ព្រោះទេវតានាំបណ្តាលឱ្យឃើញយ៉ាងនេះ ឬយ៉ាងនោះ តាមទំនងរបស់ចិត្តទេវតាដែលមានបំណងអ្វី ឬអាថិកំបាំងយ៉ាងណាមួយដែលជាភាពចម្លែកដល់យើងមិនធ្លាប់ជួបប្រទះ ។

**៤-បុព្វនិមិត្ត** សុបិនដែលកើតឡើងពីកម្មកុសលក្តី អកុសលក្តី ឬផលអាស្រ័យហេតុបច្ច័យរបស់ធម្មជាតិពីអតីតកាលយូរឆាប់ក្តី ក៏អាចឱ្យផលធ្វើជានិមិត្តឱ្យឃើញពេលបច្ចុប្បន្ននេះ ដូចពួកញាតិរបស់ព្រះបាទពិម្ពិសារ ដែល

បានទៅកើតជាប្រេត ព្រោះតែបរិភោគអាហារមុនព្រះសង្ឃ ។ គិតទៅកន្លងច្រើនកប្បផែនដី ក៏បានមកស្រែកប្រាប់នៅតាមក្លោងទ្វារ មាត់ទ្វារ ឬតាមជញ្ជាំងតែមិនយល់ហេតុទាំងនោះ ទើបស្តេចយាង ទៅទូលសួរព្រះសម្មាសម្ពុទ្ធ ដើម្បីព្យាករ ។

សុបិនទាំង ៤ យ៉ាងនេះមានពិតខ្លះ មិនពិតខ្លះ ព្រោះដោយអំណាចនៃកិលេស ហើយមានច្រើនជាងគេគឺបុថុជ្ជននេះឯង ឯព្រះអរិយបុគ្គលនៅជាសេក្ខបុគ្គល មិនទាន់សមុច្ឆេទកិលេស ក៏នៅមានការយល់សប្តិនៅឡើយ លើកលែងតែ ព្រះខីណាស្រព ទើបលោកមិនមានសុបិននិមិត្ត គឺលោករស់នៅជាសុខស្រួលប្រសើរក្រៃលែង ដែលមិនអាចមានសុខណាយកមកប្រៀបធៀបបានឡើយ ព្រោះជាសុខក្នុងព្រះនិព្វាន ។

ការដែលខ្ញុំលើកយកសុបិន ១៦ ប្រការមកនេះ :

I - ក្នុងបំណងចង់បង្ហាញប្រាប់ពីការពិតនៅលោកតាមហេតុបច្ច័យរបស់ធម្មជាតិ ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករ ដើម្បីលាតត្រដាងប្រាប់ឱ្យឃើញនូវសច្ចះធម៌ ដែលមនុស្សបុថុជ្ជនច្រើនដោយកិលេសគ្របសង្កត់ ពុំមានការត្រិះរិះការពិចារណាឱ្យបានហ្មត់ចត់ត្រឹមត្រូវតាមហេតុផល ម្លោះ

ហើយចេះតែជឿផ្តេសផ្តាសខុសពីការពិត ។ តាមធម្មតាពុំមានផលណាមួយកើតឡើងប្រាស់ចាកហេតុឡើយ នេះជាព្រះពុទ្ធដិកាទ្រង់ត្រាស់សម្តែង មាននៅក្នុងគម្ពីរព្រះអភិធម្ម ( បរមត្ថធម៌សង្ខេប ) ។

**II** - ម្យ៉ាងទៀតចង់បង្ហាញប្រាប់នូវការលំបាកលំបិនដល់ជីវភាពរស់នៅរបស់សត្វលោក ដែលលោកសន្និវាស នេះត្រូវ ភ្លើងរាគៈ ភ្លើងទោសៈ ភ្លើងមោហៈ កំពុងឆាបឆេះ និងកំពុងចុះអាប់ឱន ទៅតាមការខែចុះនៃអាយុសង្ខាររបស់មនុស្សជាតិ នាំឱ្យមានភាពចម្រើនខាងអកុសលធម៌ ជាសកម្មភាពនិងទង្វើ អធម៌ពេញលោកទាំងមូល នៅក្នុងសាសនារបស់ព្រះសម្ពុទ្ធ ដែលថាមនុស្សយើងឃាករេចិត្តទៅជឿអ្វីផ្សេងៗ ប្រាស់ចាកកម្មផល នាំឱ្យមិនមានការរីកចំរើនផ្លូវចិត្ត ( ស្ងប់ ) ដែលជាបច្ច័យទាញសត្វទៅរកសេចក្តីវិនាស មានអបាយភូមិ គឺផ្តល់នូវទុក្ខវេទនាខ្លោចផ្សា ពុំអាចមាននរណាជួយបាន ។

**III** - ចង់បង្ហាញប្រាប់នូវព្រះមហាករុណាទិគុណរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ដែលបានព្យាករ ដើម្បីជួយសត្វ

លោក ជាការអនុគ្រោះមួយដ៏ប្រសើរក្រៃលែង កម្រមាន អ្នកណាអាចនឹងដឹងធ្វើដូចព្រះអង្គ ។ ទ្រង់បានជួយដោះស្រាយបញ្ហាព្រះរាជា ឱ្យទ្រង់ជ្រាបនូវការពិតក្នុងគោលបំណងឱ្យចៀស ផុតពីគ្រោះថ្នាក់ ភយន្តរាយដល់រាជសម្បត្តិ ដល់ព្រះជន្ម និងអាយុជីវិតរបស់ពួកសត្វ ដូចមាននៅក្នុងការទោះទាយ របស់ព្រាហ្មណ៍បុរោហិត តាមមហាសុបិន ១៦ ប្រការ ខាងមុខនេះស្រាប់ និងជួយដោះស្រាយព្យាករ បញ្ហារបស់សក្កទេវរាជទៀតផង ។ ការចំរើនអកុសលធម៌ច្រើនឡើងៗ ជាភាពអាក្រក់មួយ ដែលព្រះសម្មាសម្ពុទ្ធត្រាស់សម្តែងថា " អកុសលត្រូវលះ កុសលធម៌ត្រូវចំរើន" ។ នៅក្នុងឱវាទបាតិមោក្ខ ព្រះអង្គទ្រង់ត្រាស់សម្តែងថាៈ

**សព្វបាបស្ស អករណំ** ហាមមិនឱ្យធ្វើអំពើបាបទាំងពួង

**កុសលស្សូបសម្បទា** ឱ្យធ្វើតែអំពើជាកុសល

**សចិត្តបរិយោទបនំ** ធ្វើចិត្តឱ្យស្អាតផូរផង់

**ឯតំពុទ្ធានសាសនំ** នេះជាពាក្យប្រៀនប្រដៅ

របស់ព្រះពុទ្ធគ្រប់ៗព្រះអង្គ ។

នៅពេលអកុសលធម៌កំពុងចំរើន អ្វីៗទាំងអស់កើតឡើងប្រាសចាកពីអំពើល្អ ព្រោះអំណាចនៃកិលេសដែលចេះតែចងរួបរិតដល់សត្វលោកឱ្យដើរទៅរកផ្លូវខុស មានតណ្ហា ទិដ្ឋិ មានះ ជាធម៌ប្រចាំលោក ទាញសត្វឱ្យជាប់នៅក្នុងអន្ទាក់នៃវដ្តៈអន្ទោលទៅអន្ទោលមក កើត ចាស់ ឈឺ ស្លាប់ វិលចុះវិលឡើង ម្តងទៅកើតជាទេវតា ម្តងទៅកើតជាមនុស្សម្តងទៅកើតក្នុងអបាយភូមិ មាននរក ប្រេត តិរច្ឆាន អាសុរិកាយជាដើម ដូចជាប់នៅក្នុងពន្ធនាគារយ៉ាងដូច្នោះ ។

សេចក្តីអស្ចារ្យក្នុងមហាសុបិននេះ ជាព្រឹត្តិការណ៍អាក្រក់ខ្លាំងណាស់ ព្រោះអ្វីៗមានសភាពថោកទាប មិនធ្លាប់កើតមាន ទៅជាមាន សួរថា អ្នកណាហ្ន៎ជាអ្នកធ្វើយ៉ាងដូច្នោះ ថាគ្មានអ្នកណាម្នាក់ចង់ធ្វើដូច្នោះទេ តែនេះព្រោះ **តណ្ហា**។ មហាសុបិននេះ ព្រះរាជាពីមុនៗក៏ធ្លាប់ជួបរឿងយ៉ាងដូច្នេះដែរ ប៉ុន្តែកាលនោះ ព្រះសម្មាសម្ពុទ្ធសមណគោតមបរមគ្រូនៃយើង ទ្រង់នៅជាតាបស កំពុងសន្សំបារមី ព្រះអង្គក៏ទ្រង់បានជួយព្រះរាជាមុនៗឱ្យរួចពីគ្រោះអន្តរាយ ហើយឱ្យសមាទាន

បញ្ចសីល ដូចមានអធិប្បាយនៅខាងចុង នៃមហាសុបិន នេះស្រាប់ ។

IV - សូមឱ្យសត្វលោកបានជ្រាបហេតុដ៏ពិតនេះ រួច ប្រតិបត្តិតាម ពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ ដើម្បីជាទីពឹងខ្លួនឯង ព្រោះការប្រព្រឹត្តព្រហ្មចរិយធម៌ ជាគុណជាតិប្រសើរក្រៃលែង មិនចាំបាច់ទៅរកទីពឹងពីខាងក្រៅ នាំឱ្យតែខាតបង់ពេលវេលាឥតប្រយោជន៍ ។ ការទីពឹងខាងក្រៅពុំប្រាកដ ដែលជាហេតុធ្វើឱ្យវិនាសអន្តរាយច្រើនប្រការ ព្រោះត្រូវចំណាយមាសប្រាក់ ទ្រព្យសម្បត្តិ រហូតដល់ជីវិតសត្វក៏សឹងមាន ។ សូមកុំចេះតែជឿខុសពីច្បាប់កម្មផល ព្រោះការជឿមិនសមហេតុផល មិនមែនពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធឡើយ ។

V - ចង់បង្ហាញប្រាប់នូវអ្វីៗដែលមាននៅក្នុងលោក តែងតែធ្វើឱ្យសត្វត្រេកត្រអាល ជាប់ជំពាក់ទៅលើរបស់ទាំងនោះ តើរបស់ទាំងនោះមានហេតុបច្ច័យដូចម្ដេច? ពាក្យថា "លោក" នៅក្នុងវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជ ជួន ណាត បានសសេរថា : សភាវៈតែងតែកើត តែងតែវិនាស

រឿយៗ ឬបាត់ៗបានដល់ ទឹក ដី ភ្លើង ខ្យល់ មនុស្ស សត្វ អាកាសជាដើម ។ បើតាមគម្ពីរព្រះត្រៃបិតកសម្តែងថា សភាវៈ មិនទៀង ប្រែប្រួល ជារបស់ភូតភរកុហក ជារបស់ទទេ មិនគួរយើងទៅទីពឹងជាប់ជំពាក់ត្រេកត្រអាល ព្រោះរបស់ទាំងនោះ កើតឡើងត្រូវវិនាសទៅវិញជាធម្មតា ។ ការដឹងត្រឹមប៉ុណ្ណេះ ឈ្មោះថាមានបញ្ញា នេះជាការវិនិច្ឆ័យទៅតាមធម៌( ធម្មជាតិ) ។ ឯពាក្យថាធម៌ ( ធម្មជាតិ) ជាសភាវៈពិត មិនដូចលោកទេ ជាធម្មជាតិគួរសិក្សាឱ្យបានច្រើន ទើបលែងភូតកុហក ព្រោះមានអាថិកំបាំងដែលយើងពុំបានដឹង ។ បើចង់ជ្រាបច្បាស់ សូមខំសិក្សាស្រាវជ្រាវព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធឱ្យច្រើន ។

សៀវភៅនេះកើតឡើងដោយការព្យាយាម មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាឧបការៈ នៅក្រោមម្លប់ព្រះពុទ្ធសាសនាព្រមទាំងសម្តេចព្រះសង្ឃរាជទាំងពីរគណៈជាទីសក្ការៈ ដើម្បីបូជាចំពោះគុណព្រះរតនត្រៃ និងលើកតម្កើងព្រះពុទ្ធសាសនាឱ្យរុងរឿង ។ ឯការបោះពុម្ព សូមលើកជូនឧបាសក យន្ត សួន ជាពុទ្ធសាសនូបត្ថម្ភ ។

សូមបានជាប្រយោជន៍ និង ឧទ្ទិសជូនដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតា គ្រូឧបជ្ឈាយាចារ្យ និងញាតិមិត្ត ព្រមទាំងពុទ្ធបរិស័ទ ដែលកំពុងបដិបត្តិធម៌ ។

សូមមេត្តាជួយកែសម្រួលនូវចំណុចខ្វះខាត ដោយ សេចក្តីជ្រះថ្លា

**សូមអរ ព្រះគុណ និង អរគុណ**

រាជធានីភ្នំពេញ,
ថ្ងៃ ៤ កើតខែ ជេស្ឋ ឆ្នាំមមី
ចត្វាស័ក ព.ស ២៥៤៦

ឧបាសក នា សុខា

# វិន័យសម្រួលការ

១-ព្រះមហាសីលបញ្ញោ

២-ព្រះភិក្ខុ សេម រឿយ

៣-លោក ប៊ុន សុខផល

# សារបណ្ណ

**លំដាប់នៃមាតិកាធម៌** **ទំព័រ**

១-មហាសុបិនជាតក.............................................១
២-អដ្ឋកថាមហាសុបិនជាតក.................................២
៤-ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករនូវសុបិន ១៦ ប្រការ...............៨
៥-មហាសុបិនទី ១..................................................៩
៦- មហាសុបិនទី ២................................................១១
៧- មហាសុបិនទី ៣................................................១២
៨- មហាសុបិនទី ៤................................................១៤
៩- មហាសុបិនទី ៥................................................១៦
១០- មហាសុបិនទី ៦..............................................១៧
១១- មហាសុបិនទី ៧..............................................១៩
១២- មហាសុបិនទី ៨..............................................២០
១៣- មហាសុបិនទី ៩..............................................២២
១៤- មហាសុបិនទី ១០............................................២៤
១៥- មហាសុបិនទី ១១............................................២៦
១៦- មហាសុបិនទី ១២............................................២៨
១៧- មហាសុបិនទី ១៣............................................៣០

១៨- មហាសុបិនទី ១៤.........................................................៣១

១៩- មហាសុបិនទី ១៥.........................................................៣៣

២០- មហាសុបិនទី ១៦.........................................................៣៤

២១- ខ្លឹមសារធម៌គួរពិចារណា.................................................៤៥

២២- សតិប្បដ្ឋានវិបស្សនា.............................. ..............៦៦

២២-ព្រះដ៏មានព្រះភាគទ្រង់ព្យាករប្រស្នាព្រះ ឥន្ទ......................៩៤

២៣-សេចក្ដីពិស្ដារ ............................................................៩៨

២៤-កំណាព្យ ..................................................................១១៣

## ឯកនិបាត វរុណទី ៨

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

# មហាសុបិនជាតក

ឧសភា រុក្ខា គាវិយោ គវា ច
អស្សោ កំសោ សិគាលី ច កុម្ភោ
បោក្ខរណី ច អបាកចន្ទនំ
លាពូនិ សីទន្តិ សិលា ប្លវន្តិ
មណ្ឌូកិយោ កណ្ហសប្បេ គិលន្តិ
កាកំ សុវណ្ណា បរិវារយន្តិ
តសា វកា ឯឡកានំ ភយា ហិ
វិបរិយាសោ វត្តតិ នយិធមត្ថីតិ[១] ។

ព្រះរាជាទ្រង់ត្រាស់ថា មហាសុបិន ១៦ គឺ : គោឡើងកទាំងឡាយ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ ១ ភាជន៍( មាស) ១ មេ

---

១-អដ្ឋកថា ខុទ្ទកនិកាយ ឯកនិបាតជាតក ក្រុមទី ៣ ភាគ ទី ២

ឆ្កែចចក១ ក្អមទឹក ១ ស្រះបោក្ខណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយអណ្តែត ១ មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ ១ រាជហង្សមាសទាំងឡាយចោមរោមក្អែក ១ ខ្លាដំបងទាំងឡាយ(រត់ទៅ) ព្រោះ ភ្ញាក់ផ្អើលដោយសេចក្តីខ្លាចអំពីពពែទាំងឡាយ ១ បរិយាយដោយចំឡែកប្រព្រឹត្តទៅ ន័យទាំងឡាយមានក្នុងសុបិនទាំងនេះ ។

# អដ្ឋកថាមហាសុបិនជាតក

កាលព្រះបរមសាស្តា ទ្រង់ប្រថាប់នៅក្នុងព្រះមហាវិហារវត្ត **ជេត ពន** បានប្រារព្ធមហាសុបិន ១៦ ខ យកមកត្រាស់សម្តែង ធម្មទេសានា មានពាក្យជាដើមថា **ហទ្ធូសិនន្តិ** ដូច្នេះ ។

ដូចបានសណ្តាប់មក ថ្ងៃមួយព្រះបាទ **កោសលមហារាជ** ព្រះរាជាក្រុង **សាវត្ថី** រាជធានីនៃដែន **កោសល** ស្តេចទ្រង់ចូលទៅផ្ទំ ក្នុងវេលារាត្រីបច្ចឹមយាមជិតភ្លឺ ព្រះអង្គបានទតឃើញ

ព្រះសុបិននិមិត្ត ១៦ ប្រការដ៏ចំឡែកអស្ចារ្យ ។ ព្រះរាជាទ្រង់ស្លុតរន្ធត់ព្រះទ័យខ្លាំងណាស់ ទ្រង់ភ្ញាក់ឡើងពីព្រះបន្ទំត្រិះរិះថា ការឃើញសុបិននិមិត្តទាំងនេះនឹងមានហេតុអ្វីដល់យើងហ្ន៎ ជាមរណភ័យមកដល់ហើយឬ ? ទ្រង់ប្រថាប់លើព្រះទែនសេយ្យសន៍នោះរហូតរាត្រីកាល ។

លុះព្រឹកឡើង ពួកព្រាហ្មណ៍បុរោហិតចូលទៅក្រាបទូលសួរថា បពិត្រមហារាជជាម្ចាស់! ព្រះអង្គទ្រង់ផ្ទំជាសុខសប្បាយឬទេ ព្រះករុណាថ្លៃវិសេស ? ព្រះរាជាឆ្លើយថាលោកអាចារ្យទាំងឡាយ យើងនឹងមានសេចក្តីសុខយ៉ាងដូចម្តេច បើពេលជិតភ្លឺ យើងបានឃើញសុបិននិមិត្ត ១៦ ខ ។ តាំងតែពីឃើញសុបិននិមិត្តទាំងនោះហើយ មានសេចក្តីភ័យខ្លាចជាខ្លាំង ពួកព្រាហ្មណ៍បុរោហិតក្រាបទូលថា បពិត្រមហារាជជាម្ចាស់ សូមទ្រង់ត្រាស់ប្រទានវាចាមកចុះ ព្រះករុ-ណាថ្លៃវិសេស ពួកខ្ញុំម្ចាស់ទាំងឡាយប្រុងចាំស្តាប់ ហើយនឹងធ្វើការទស្សន៍ទាយ ។ ពេលនោះព្រះអង្គទ្រង់ត្រាស់និទានសុបិនដែលទ្រង់ឃើញឱ្យពួកព្រាហ្មណ៍ស្តាប់ ព្រោះហេតុឃើញសុបិនទាំងនោះ តើនឹងមានអ្វីកើតមានដល់ យើងខ្លះ ?

ព្រាហ្មណ៍នាំគ្នាធ្វើការទស្សន៍ទាយ រួចក៏ក្រាបទូលថា បពិត្រព្រះរាជា ព្រះសុបិនទាំងឡាយនោះ មិនល្អទេ! ព្រះរាជាសួរថា ព្រះសុបិននោះនឹងឱ្យផលប្រការយ៉ាងណា ? ពួកព្រាហ្មណ៍នាំគ្នាក្រាបទូលថា នឹងមានអន្តរាយ ៣ យ៉ាង គឺ.

១-អន្តរាយដល់រាជសម្បត្តិ

២-អន្តរាយ គឺរោគនឹងបៀតបៀន

៣-អន្តរាយដល់ព្រះជន្មយ៉ាងណាមួយ ។

ព្រះរាជាសួរថា តើល្អមអាចដោះស្រាយបានឬមិនបាន ពួកព្រាហ្មណ៍ទាំងឡាយក្រាបទូលថា សូមតេជះ ព្រះសុបិនទាំងនេះ ពិបាកដោះស្រាយណាស់ ព្រោះកាចសាហាវខ្លាំងក្លាបំផុត សូម្បីពួកខ្ញុំព្រះអង្គទាំងឡាយ ក៏មិនអាចនឹងដោះស្រាយបាន ពេលទូលព្រះបង្គំដោះស្រាយសុបិនទាំងនោះមិនបាន ឈ្មោះថា ជាអ្នកសំរេចការសិក្សាដើម្បីប្រយោជន៍អ្វី បើមិនអាចនឹងដោះស្រាយនូវរឿងហេតុទាំងនោះបាន ! ព្រះរាជាសួរថា លោកអាចារ្យទាំងឡាយ តើត្រូវធ្វើយ៉ាងដូចម្តេចឱ្យបានស្រាកស្រាន្តស្រួល ពួកព្រាហ្មណ៍នាំគ្នាក្រាបទូលព្រះរាជាថា បពិត្រមហារាជជាម្ចាស់ ពួកខ្ញុំព្រះអង្គយល់ថា ត្រូវ

ធ្វើពិធី **បូជាយញ្ញ** ដោយវត្ថុនិមួយៗមាន ៤ មុខគ្រប់យ៉ាង ព្រះករុណាថ្លៃវិសេស ។ ព្រះរាជាទ្រង់ញ័ររន្ធត់ព្រះទ័យ ក៏ត្រាស់ថា លោកអាចារ្យទាំងឡាយឆ្លើយដូច្នេះ យើងសូមប្រគល់ជីវិតទុកនៅក្នុងដៃរបស់ពួកលោក ពួកលោកផ្ដើមធ្វើសិរីសួស្ដីដល់យើងឆាប់ៗចុះ។ ពួកព្រាហ្មណ៍នាំគ្នារីករាយត្រេកអរថា នឹងត្រូវបានទ្រព្យច្រើន ព្រមទាំងលាភសក្ការៈ មានគ្រឿងបរិភោគដ៏ច្រើនៗ ហើយក៏នាំគ្នាក្រាបទូល ព្រះរាជាថា បពិត្រមហារាជជាម្ចាស់ សូមព្រះអង្គកុំព្រួយគិតអ្វីឡើយ ព្រះករុណាថ្លៃវិសេស ។ រួចនាំគ្នាចេញ ចាករាជនិវេសន៍ រៀបចំធ្វើពិធីបូជាយញ្ញនៅខាងក្រៅព្រះនគរ ដោយចាប់ពួកសត្វមានជើង ១ ក្រុមៗ ៤ ទុកនៅកន្លែងបូជាយញ្ញ ប្រមូលហ្វូងសត្វពីក្រៅទុកស្រេចហើយ ក៏ប្រទាក់គ្នាទៅវិញទៅមកថា យើងនិងត្រូវបានវត្ថុនេះជាមិនខាន ។

គ្រានោះហើយ ព្រះនាង **មល្លិកាទេវី** ទ្រង់ជ្រាបហេតុនោះ ក៏ចូលទៅគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ ពួកព្រាហ្មណ៍នាំគ្នាទំនាក់ទំនងទៅវិញទៅមក តើមានរឿងអ្វីទៅព្រះករុណា ? ព្រះរាជាទ្រង់ត្រាស់ថា នែនាងដ៏ចំរើន

ឯងមិនជ្រាបដល់សេចក្តីសុខសប្បាយទេឬ ? ទើបមិនដឹងថា អសិរពិសមកតាំងមាំនៅជិត១ត្រចៀកយើង ។ ព្រះនាងទូលសួរថា បពិត្រមហារាជ រឿងនោះគឺអ្វីទៅ មែ ? ព្រះរាជាប្រាប់ថា យើងមានការយល់សប្តិអាក្រក់ ដូច្នេះពួកព្រាហ្មណ៍នាំគ្នាទាយថា មានអន្តរាយ ៣ យ៉ាងមិនប្រាកដណាមួយទេ ដើម្បីបំបាត់អន្តរាយទាំងនោះ ត្រូវធ្វើបូជាយញ្ញ ដូច្នេះបានជាត្រូវទាក់ទងគ្នាទៅមកញឹកញាប់ ។ ព្រះនាងមល្លិកាក្រាបទូលថា បពិត្រមហារាជ អ្នកដែលជាកំពូលលើពួកព្រាហ្មណ៍ក្នុងលោក ព្រមទាំងទេវលោក តើព្រះអង្គបានទូលសួរដល់ការដោះស្រាយព្រះមហាសុបិនហើយឬ មែ ? ទ្រង់សួរថា ព្រះនាងដ៏ចំរើន ព្រះ ជាកំពូលលើពួកព្រាហ្មណ៍ក្នុងលោក ព្រមទាំងទេវលោកនោះ តើជានរណា ?

ព្រះនាងក្រាបទូលថា ព្រះអង្គមិនទ្រង់ជ្រាបទេឬ ! មហាព្រាហ្មណ៍នោះគឺ **ព្រះ គោតម** ជាតថាគតអស់កិលេស បរិសុទ្ធហើយជាសព្វញ្ញូ ជាបុគ្គលប្រសើរលើសក្នុងលោក ព្រមទាំងទេវលោក ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គនោះគង់



ព្រះនាងមល្លិកាទេវី ទូលព្រះរាជាសូមកុំឱ្យជឿពាក្យ ព្រហ្មណ៍បុរោហិត
ដែលនិយាយខុសពីការពិត សូមស្ដេចយាងទៅទូលសួរព្រះសម្មាសម្ពុទ្ធដើម្បីព្យាករ ។

នឹងទ្រង់ជ្រាបហេតុនោះពិតប្រាកដ ខ្ញុំម្ចាស់សូមយាងព្រះអង្គ សូមស្តេចព្រះរាជដំណើរយាងទៅក្រាបទូលសួរចុះ ម៉ែ ! ។

ព្រះរាជាទ្រង់ពោលពាក្យថា ល្អណាស់ទេវី ។ រួចហើយស្តេចក៏យាងទៅកាន់ព្រះវិហារ ក្រាបថ្វាយបង្គំព្រះបរមសាស្តា ដែលប្រថាប់នៅមួយកន្លែងដ៏សមគួរ ។ ព្រះសាស្តាទ្រង់បន្លឺព្រះសូរសៀងដ៏ពិរោះត្រាស់សួរថា មហាបពិត្រ ហេតុអ្វីបានជាមហាបពិត្រស្តេចយាងមកដូច្នេះ ? ដូចមានរាជកិច្ចជាបន្ទាន់ឬ ? ។

ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពេលទៀបភ្លឺទូលព្រះបង្គំបានឃើញមហាសុបិន ១៦ ប្រការ មានសេចក្តីភ័យញ័ររន្ធត់ ទ្រង់ប្រាប់ដល់ពួកព្រាហ្មណ៍ ចំណែកពួកព្រាហ្មណ៍ទាយថា បពិត្រមហារាជជាម្ចាស់! ព្រះសុបិនអាក្រក់ខ្លាំងណាស់ ដើម្បីរម្ងាប់សុបិនទាំងនេះត្រូវធ្វើពិធីបូជាយញ្ញ ដោយយកវត្ថុក្នុងមួយមុខៗមាន ៤ គ្រប់យ៉ាង ហើយនាំគ្នាត្រៀមដើម្បីធ្វើការបូជាយញ្ញ ។ ហ្វូងសត្វទាំងឡាយ កំពុងត្រូវមរណភ័យ សំលុតគម្រាម បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គជាបុគ្គលប្រសើរលើស

ក្នុងលោក ពេញយ្យធមិដែលចូលទៅកំណត់អតីតៈ អនាគត បច្ចុប្បន្ន ដែលឈ្មោះថាមិនមកដល់ញាណ ចំពោះមុខព្រះអង្គនោះ មិនមានឡើយ ។

បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ សូមព្រះអង្គទ្រង់ព្រះករុណាប្រោស ព្យាករផលនៃសុបិនរបស់ទូលព្រះបង្គំទាំងនោះដោយមេត្តា ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា សូមថ្វាយព្រះពរ សភាពដូច្នោះមានរឿងតែមួយ មហាបពិត្រ ក្នុងលោក ទាំងទេវលោកវៀរតែតថាគតចេញ អ្នកដទៃនឹងបានឈ្មោះថាដឹងហេតុផលរបស់សុបិននេះមិនមានឡើយ តថាគតនឹងព្យាករថ្វាយមហាបពិត្រ ប៉ុន្តែសូមមហាបពិត្រ ទ្រង់ត្រាស់ប្រាប់ព្រះសុបិនតាមទំនងដែលទ្រង់ធ្លាប់ឃើញនោះមកចុះ ។

ព្រះរាជាទ្រង់ទទួលព្រះពុទ្ធតម្រាស់ថា ល្អណាស់ព្រះអង្គ ខ្ញុំព្រះករុណាផ្តើមក្រាបទូលព្រះសុបិនតាមទំនងយ៉ាងប្រុងប្រយត្ន័ ដោយទ្រង់ដាក់ ខ ទុកដូច្នេះថា :

"គោឧសភរាជទាំងឡាយ ១ ដើមឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ



ព្រះសម្មាសម្ពុទ្ធកំពុងព្យាករនូវព្រះសុបិន ១៦ ប្រការរបស់ព្រះបាទបសេនទិកោសល

ទាំងឡាយ ១ ថាសមាស ១ មេឆ្កែចចកទាំងឡាយ ១ ក្អមទឹកទាំងឡាយ ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទ័ ១ ផ្លែឃ្លោកទាំងឡាយលិចទឹក ១ ថ្មទាំងឡាយអណ្តែត ១ មេកង្កែបទាំងឡាយខាំពស់វែក ១ រាជហង្សទាំងឡាយចោមរោមក្អែក ១ ខ្លាដំបងទាំងឡាយភ្ញាក់ផ្អើល ព្រោះខ្លាចពពែទាំងឡាយ ១ ។

## មហាសុបិនទី ១

**ព្រះរាជា** ត្រាស់ថា បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំឃើញសុបិន ខ ទី ១ យ៉ាងនេះ មុនដំបូងថា គោឧសភ ៤ ពណ៌ដូចផ្កាអញ្ចាន គិតថានឹងជល់គ្នា នាំគ្នារត់មកពីផ្ទៃព្រះលានហ្លួង អំពីទិសទាំង ៤ ពេលមហាជនប្រជុំគ្នាគិតថា ពួកយើងចូរ មើលគោជល់គ្នា ក៏បន្លឺសម្លេងឮលាន់គម្រាមដាក់គ្នារកជល់ ហើយមិនជល់គ្នាទៅវិញ នាំគ្នាថយចេញទៅ ទូលព្រះបង្គំឃើញសុបិននេះជាបឋម តើអ្វីជាផលរបស់ព្រះសុបិននេះ ព្រះករុណាជាម្ចាស់ ?

ព្រះសម្មាសម្ពុទ្ធ មហាបពិត្រ ផលរបស់សុបិន ខ នេះនឹងមិនមានក្នុងជួររជ្ជកាលរបស់មហាបពិត្រទេ គឺក្នុងជួររបស់សាសនាតថាគត ប៉ុន្តែនៅក្នុងអនាគត ពេលលោកវិលចុះទៅដល់ចំណុចអន់ថយ ក្នុងរជ្ជកាលរបស់ព្រះរាជាអ្នកកំព្រា អ្នកមិនបានគ្រប់គ្រងរាជ្យដោយធម៌ និងក្នុងកាលក្រុមមនុស្សមិនតាំងនៅក្នុងធម៌ ពេលកុសលធម៌ចុះខ្សោយ អកុសលធម៌ចំរើនឡើង ក្នុងពេលដែលលោកត្រូវអាប់ឱន ភ្លៀងនឹងរាំងឯមេឃនឹងអួរអាប់ សំណាបនឹងស្ងួតក្រៀម ទុរ្ភិក្សភ័យនឹងកើតឡើង មេឃទាំងឡាយតាំងនៅងងឹតពីទិសទាំង ៤ ហាក់បីដូចជាធ្លាក់គ្រាប់ភ្លៀងចុះ ពួកស្រីៗប្រមូលស្រូវជាដើមដែលដាក់ហាលថ្ងៃចូលក្នុងម្លប់ ព្រោះខ្លាចទទឹកខូច ។ លុះពេលពួកប្រុសៗម្នាក់ៗកាន់ចប កាន់ភាជនៈនាំគ្នាចេញទៅដើម្បីទប់ទឹក ក៏ហាក់ដូចជាមានភ្លៀងធ្លាក់ មេឃថ្ងូរគ្រហឹមក៏មិនមានភ្លៀងធ្លាក់ ពពករសាត់បាត់សូន្យទៅ ដូចគោធ្វើអាកប្បកិរិយានឹងរកជល់គ្នា បែរជាមិនជល់ទៅវិញដូច្នោះ នេះជាផលរបស់សុបិន។ ប៉ុន្តែមិនមានអន្តរាយអ្វីដល់មហាបពិត្រ ព្រោះរឿងនេះជាបច្ច័យ ។ មហាបពិត្រឃើញសុបិននេះប្រារព្ធ

ទៅអនាគត ចំណែកពួកព្រាហ្មណ៍ អាស្រ័យការចិញ្ចឹមជីវិតរបស់ខ្លួន ទើបទាយដូច្នេះ ។ ព្រះបរមសាស្តា ត្រាត្រាស់ប្រាប់ផលនៃសុបិន ដោយប្រការដូច្នេះហើយ ទ្រង់ត្រាស់ថា សូមព្រះរាជា មានព្រះបន្ទូលនូវ ខ សុបិនទី ២ ទៀតចុះមហាបពិត្រ !

## មហាសុបិនទី ២

**ព្រះរាជា**=បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបានឃើញសុបិន ខ ទី ២ យ៉ាងនេះថា ដើមឈើតូចៗនិងគុម្ពឬស្សីដុះចេញនៅលើផែនដីមួយធ្លាប់ខ្លះ មួយហត្ថខ្លះ ហាក់ដូចជាផលិតចេញផលខាងក្រោយៗ នេះជាសុបិនទី ២ ដែលទូលព្រះបង្គំបានឃើញ តើអ្វីទៅជាផលរបស់សុបិននេះ ព្រះករុណាព្រះអង្គ ?

**ព្រះសម្មាសម្ពុទ្ធ**=ទ្រង់ត្រាស់ថា មហាបពិត្រ ផលសុបិន ខ នេះ ក៏នឹងមានក្នុងកាលដែលលោកថយចុះអាប់ឱនវេលាមនុស្សមានអាយុតិច ដោយថា សត្វទាំងឡាយនៅក្នុង

អនាគតមានភាគៈច្រើន(ខ្លាំង)កុមារី មានវ័យមិនទាន់សម្បូណ៌ នឹងសមល្មមដល់បុរសដទៃ ជាស្ត្រីមានរដូវ មានគភ៌ នាំគ្នាចម្រើនដោយបុត្រនិងធីតា សភាពដែលកុមារីពួកនោះមានរដូវ ប្រៀបដូចដើមឈើតូចៗមានផ្កា កុមារីពួកនោះចំរើនដោយបុត្រនិងធីតាក៏ហាក់បីដូចជាដើមឈើតូចៗមានផល ។ ភ័យមានពិតប្រាកដនូវនិមិត្តនេះជាហេតុ ពុំមានដល់មហាបពិត្រទេ សូមព្រះរាជាមានព្រះបន្ទូលនូវសុបិន ខ ទី. ៣ តទៅទៀតចុះមហាបពិត្រ !

## មហាសុបិនទី ៣

__ព្រះរាជា__ បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបានឃើញមេគោធំៗ នាំគ្នារត់ទៅបៅដោះរបស់កូនគោ ដែលទើបនឹងកើតក្នុងថ្ងៃនោះ នេះជាសុបិនទី ៣ របស់ទូលព្រះបង្គំ តើអ្វីទៅជាផលរបស់សុបិននោះ ព្រះករុណាព្រះអង្គ ?

__ព្រះសម្មាសម្ពុទ្ធ__ មហាបពិត្រ សូម្បីផលរបស់សុបិននេះ ក៏នឹងមានក្នុងអនាគតដូចគ្នា ក្នុងវេលាដែលមនុស្ស

ទាំងឡាយ នាំគ្នាលះបង់ជេដ្ឋាបចាយិកកម្ម ( កម្មនៃបុគ្គលអ្នកប្រព្រឹត្តកោតក្រែងដល់បុគ្គលរៀមច្បង ឬអ្នកចំរើនបំផុត កម្មនៃបុគ្គលអ្នកប្រព្រឹត្ត គោរពដល់បុគ្គលអ្នកជាច្បង ឬអ្នកប្រសើរបំផុត ) គឺភាពជាអ្នកប្រព្រឹត្តឱនលំទោនចំពោះអ្នកធំព្រោះក្នុងអនាគតពួកសត្វឬក្មេងៗ នឹងមិនបានតាំងចិត្តទុកគោរពកោតក្រែងដល់មាតាបិតា ឬ ជីដូនជីតា ម្នាក់ៗស្វែងរកទ្រព្យសម្បត្តិដោយខ្លួនឯង ពេលប្រាថ្នានឹងផ្តល់គ្រឿងបរិភោគ ឬ របស់ប្រើប្រាស់ដល់មាតាបិតាចាស់ៗ ចង់ជូនឬមិនចង់ជូនក៏បាន ឯមាតាបិតាចាស់ៗ នាំគ្នាទីពឹងការរកចិញ្ចឹមជីវិតតែលើខ្លួនឯងស្ទើរមិនបាន ត្រូវលួងលោមកូនដើម្បីចិញ្ចឹមជីវិតទៅវិញ ដូចមេគោធំៗ នាំគ្នារកបៅដោះកូនគោដែលទើបនឹងកើតក្នុងថ្ងៃនោះឯង។ សូម្បីសុបិននេះមានភ័យជាហេតុ ក៏មិនមានដល់មហាបពិត្រដែរ សូមស្តេចទ្រង់មានព្រះបន្ទូលនូវសុបិន ខ ទី ៤ តទៅទៀតចុះ មហាបពិត្រ !

# មហាសុបិនទី ៤

**ព្រះរាជា**-បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំធ្លាប់ឃើញហ្វូងមនុស្សទឹមគោធំៗដែលធ្លាប់នាំនឹមទៅ មានរាងកាយនិងកម្លាំងខ្លាំងក្លាចូលក្នុងនឹម គេត្រឡប់ទៅទឹមគោកម្លោះស្រាងៗ ដែលមានកំលាំងមិនទាន់ហ្វឹកហាត់ចូលក្នុងនឹមឯគោកម្លោះស្រាងៗទាំងនោះមិនអាចនាំនឹមទៅរួច ក៏នាំគ្នារលាស់ចេញពីនឹម ឈរធ្វើព្រងើយ ។ រទេះទាំងឡាយទៅមុខមិនរួច នេះជាសុបិនទី ៤ របស់ទូលបង្គំ តើអ្វីជាផលរបស់សុបិននេះ ព្រះអង្គ ?

**ព្រះសម្មាសម្ពុទ្ធ**-មហាបពិត្រ ផលរបស់សុបិន ខនេះ ក៏នឹងមានរាជសម័យរបស់ព្រះរាជា អ្នកមិនតាំងនៅក្នុងធមិ ក្នុងអនាគតដូចគ្នា ដោយថាក្នុងកាលខាងមុខព្រះរាជានឹងព្រះរាជទានយសដល់អាមាត្យអ្នកធំ ចំណែកបណ្ឌិតឆ្លាតក្នុងព្រះពេណីមានវោហារ អាចនឹងញ៉ាំងសព្វកិច្ចការឱ្យសំរេចសព្វគ្រប់ ទ្រង់មិនតែងតាំងធ្វើជាអ្នកធំ ទុកក្នុងកន្លែងវិនិច្ឆ័យក្តីក្នុងរង្គសាលក្តី ទ្រង់ព្រះរាជទានយសដល់អ្នកហែហាម ជិតស្និទ្ធ

គឺមនុស្សកម្លោះជំទង់ៗ ដែលបានពោលមកហើយនោះ រួចតែងតាំងបុគ្គលនោះទុកក្នុងតំណែង ជាអ្នកវិនិច្ឆ័យកាត់ក្ដី មនុស្សពួកនោះមិនចេះធ្វើរាជកិច្ច និងអ្វីដែលគួរមិនគួរ មិនសមបើនឹងទួលយសនោះបាន ទាំងមិនអាចធ្វើរាជកិច្ចឱ្យចប់សព្វគ្រប់ទៅបាន ក៏នាំគ្នាធ្វើទាំងកិច្ចការងារខុស ។ ចំណែកអាមាត្យដែលជាបណ្ឌិតជាអ្នកមានគុណសម្បត្តិ កាលមិនបានយស ក៏មិនព្រមធ្វើឱ្យកិច្ចការទាំងឡាយចប់បាន ដោយនាំគ្នាពោលថា កិច្ចការទាំងនោះ រឿងទាំងនោះ មិនជាភារៈពួកយើងទេ ព្រោះថាពួកយើងជាមនុស្សក្រៅផ្លូវការ ឯពួកក្មេងៗកម្លោះ គេជាពួកអាស្រ័យនៅក្នុងមុខតំណែងធំ គួរតែជាអ្នកចេះដឹង មិនគួរថាមិនចេះធ្វើការងារឡើយ ។ កាលបើដូច្នេះសេចក្ដីអាប់ឱនទាំងនោះនឹងមានដល់ព្រះរាជា ដោយប្រការទាំងពួង ប្រៀបដូចជាមនុស្សចាប់គោកម្លោះៗ កំពង់ហ្វឹកហាត់មិនអាចប្រព្រឹត្តធ្វើនឹងនាំនឹមទៅបានទឹមទុកក្នុងនឹម និងជាវេលាដែលមិនយកគោធំៗធ្លាប់នាំនឹមទៅបាន មកទឹមក្នុងនឹមដូច្នោះ។ សូម្បីភ័យមានសុបិននេះជាហេតុ ក៏រមែងមិនមាន

ដល់មហាបពិត្រ សូមស្ដេចទ្រង់ត្រាស់សុបិនទី ៥ មកទៀត ចុះមហា បពិត្រ !

• • • • •

## មហាសុបិនទី ៥

**ព្រះរាជា**=បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបាន ឃើញសេះមួយមានមាត់ពីរ ប្រជាជនឱ្យស្មៅនូវមាត់ទាំងពីរ របស់វា បរិភោគតែម្ដង នេះជាសុបិន ខ ទី ៥ តើអ្វីជាផល របស់សុបិននេះ ព្រះករុណាព្រះអង្គ ?

**ព្រះសម្មាសម្ពុទ្ធ**=មហាបពិត្រ ! ផលរបស់សុបិន នេះ ក៏នឹងមានក្នុងរជ្ជកាលរបស់ព្រះរាជាអ្នកមិនតាំងនៅក្នុង ធម៌ តទៅក្នុងអនាគតដូចគ្នា ដោយថាក្នុងកាលខាងមុខ ពួកព្រះរាជាល្ងង់ខ្លៅ មិនមានធម៌ នឹងទ្រង់តែងតាំងមនុស្ស សាវ៉ាមិនប្រកបដោយធម៌ ទុកក្នុងតំណែង វិនិច្ឆ័យក្ដី ជាពួក មនុស្សពាលមិនមានចិត្តជឿបុណ្យបាប នាំគ្នាអង្គុយក្នុង រង្គ- សាល តែងពោលពាក្យថាខ្វះខាតប្រាក់ ចូលចិត្តទទួលសំណូក

ពីគូរក្តីទាំងសងខាង (គឺទទួលពីដើមចោទនិងចុងចោទ) ដូច សេះបរិភោគស្មៅដោយមាត់ទាំងពីរដូច្នោះ។ ភ័យសូម្បីមាន សុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រឡើយ ។ សូម ស្តេចទ្រង់ត្រាស់ប្រាប់សុបិន ខ ទី ៦ មកទៀតមហាបពិត្រ !

## មហាសុបិនទី ៦

**ព្រះរាជា**-បពិត្រព្រះអង្គអ្នកដ៏ចំរើន ទូលព្រះបង្គំបាន ឃើញមហាជនខាត់ជូតថាសមាសមានតម្លៃរាប់សែនកហាបណ ហើយនាំគ្នាយកទៅឱ្យឆ្កែចចកមួយ ដោយពោលពាក្យថា ចូរនោមដាក់ក្នុងថាសមាសនោះចុះ ឆ្កែចចកនោះវាក៏បន្ទោបង់ ទឹកនោមដាក់ក្នុងថាសមាសនោះ នេះជាសុបិន ខ ទី ៦ របស់ទូលព្រះបង្គំ តើអ្វីជាផលនៃហេតុសុបិន ខ នេះ ព្រះករុណា ព្រះអង្គ ?

ព្រះសម្មាសម្ពុទ្ធ-មហាបពិត្រ ផលរបស់សុបិននេះ ក៏នឹងមានក្នុងអនាគតដូចគ្នា ដោយថាកាលខាងមុខ ពួកព្រះរាជាមិនតាំងនៅក្នុងធម៌ ទ្រង់មិនតែងតាំងកុលបុត្រអ្នកសម្បូណ៌ដោយជាតិល្អ ហើយមិនព្រះរាជទានយស ត្រឡប់ជាព្រះរាជទានយសនោះដល់មនុស្ស ដែលមិនមែនជាវង្សត្រកូលល្អទៅវិញ ។ កាលបើដូច្នោះ ពួកត្រកូលធំៗទ្រូវធ្លាក់ខ្លួនក្រលំបាក មិនអាចចិញ្ចឹមជីវិត ទើបគិតថាបើដូច្នោះ យើងត្រូវពឹងពាក់អាស្រ័យ ពួកទាំងនេះ នឹងអាចចិញ្ចឹមជីវិតបន្តទៅមុខ ក៏នាំគ្នាយកធិតារបស់ខ្លួនឱ្យដល់អ្នកមានត្រកូលទាបៗ ។ ការនៅរួមរស់ជាមួយ ត្រកូលថោកទាបរបស់ត្រកូលធិតាទាំងនោះ ក៏ដូចគ្នាជាមួយនឹងថាសមាស ដែលឱ្យឆ្កែចចកបន្ទោបង់ទឹកនោមដាក់ដូច្នោះ។ ភ័យសូម្បីមានសុបិននេះជាហេតុ ក៏រមែងមិនមានដល់មហាបពិត្រ សូមទ្រង់ត្រាស់ប្រាប់សុបិន ខ ទី ៧ មកទៀតចុះមហាបពិត្រ !

# មហាសុបិនទី ៧

<u>**ព្រះរាជា**</u>-បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបាន ឃើញយ៉ាងនេះថា បុរសម្នាក់វេញខ្សែ ហើយធ្លាក់ចុះទៅជិតជើង មេឆ្កែចចកមួយដេកនៅក្រោមជើងម៉ាដែលបុរសអង្គុយ មេឆ្កែចចកអង្កៀមស៊ីខ្សែនោះ គេក៏មិនបានដឹងឡើយ ។ នេះជាសុបិន ខ ទី ៧ របស់ទូលព្រះបង្គំ តើអ្វីជាផល របស់សុបិននេះ ព្រះករុណាព្រះអង្គ ?

<u>**ព្រះសម្មាសម្ពុទ្ធ**</u>-មហាបពិត្រ ផលរបស់សុបិន ខ នេះ នឹងមានក្នុងអនាគតដូចគ្នា ដោយថាក្នុងកាលខាងមុខ ពួកស្ត្រីៗនឹងនាំគ្នាឡេះឡោះសាវ៉ាចំពោះបុរស វង្វេងក្នុងសុរា តុបតែងខ្លួន ចូលចិត្តដើរលេងកំសាន្តតាមផ្លូវ ឃើញតែអាមិស ជាស្ត្រីទ្រុស្តសីល មានការប្រព្រឹត្តខុស ពួកនាងនឹងចោមរោម ដល់ពួកប្រុសៗរឹករវ បែងចែកយកទ្រព្យដែលស្វាមីធ្វើការងារ មានកសិកម្ម និងគោរុក្ខកម្មជាដើម សន្សំទុកដោយលំបាក យកទៅទិញសុរាផឹកជាមួយសាហាយ ទិញផ្កាក្រអូបនិង គ្រឿងលាបស្រលាប មកតែងខ្លួនសំឡឹងរកមើល ហើយរង់ចាំ

មើលពាងដែលទំនេរៗឡើយ នេះជាសុបិន ខ ទី ៨ របស់ទូលព្រះបង្គំ តើអ្វីជាផលរបស់សុបិននេះ ព្រះករុណាព្រះអង្គ ?

ព្រះសម្មាសម្ពុទ្ធ-មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងអនាគតដូចគ្នា ដោយថា ក្នុងកាលខាងមុខលោក នឹងអាប់ឱនប្រទេសជាតិទាំងឡាយនឹងក្រខ្សត់អត់ឃ្លាន ព្រះរាជាមានសេចក្តីទុក្ខលំបាក កំព្រា ស្តេចអង្គណាធំជាងគេ ស្តេចអង្គនោះ នឹងមានព្រះរាជទ្រព្យរាប់សែនកហាបណៈនៅ ក្នុងព្រះឃ្លាំង ព្រះរាជាក្រក្សត់ទាំងនោះ ត្រូវកេណ្ឌប្រជាជនគ្រប់គ្នាឱ្យធ្វើការដាំដំណាំឱ្យខ្លួន ។ ពួកប្រជានុរាស្ត្រដែលត្រូវអំពើបៀតបៀនយ៉ាងនេះ លះបង់ការងាររបស់ខ្លួន នាំគ្នាព្រួសបណ្តុះសាបបុព្វណពិជ[១] និងអបរណពិជ[២] ថ្វាយដល់ព្រះរាជានោះ ហើយនាំគ្នាចាំយាមការពារថែរក្សាដោយប្រុង

---

១-អាហារ មានស្រូវសាលីជាដើម

២-របស់ទំនេរក្រោយអាហារមានសណ្តែក ល្ង ជាដើម

ប្រយត្ន័ជួយស្រោចទឹក ជួយច្រូតកាត់ ជួយបោកបែន ជួយដឹកជញ្ជូនផល និងជួយធ្វើសួនផ្កា សួនបន្លែ រួចនាំគ្នាដឹកជញ្ជូនបុព្វណពីជទាំងនោះ យកមកបញ្ចូលទុកក្នុងឃ្លាំងរបស់ព្រះរាជា ឯជម្រុកនៅផ្ទះរបស់ខ្លួនទទេគ្មានអ្វីឡើយ ។ ដូចគ្នានឹងការដងទឹកដាក់ពាងពេញហើយ មិនក្រលេកមើលពាងទទេៗខ្លះនោះឯង ។ ភ័យសូម្បីមានសុបិននេះ ជាហេតុមិនមានដល់មហាបពិត្រ សូមទ្រង់ត្រាស់និទានសុបិន ខ ទី ៩ មកទៀតចុះមហាបពិត្រ !

## មហាសុបិនទី ៩

**ព្រះរាជា** - បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបានឃើញស្រះបោក្ខរណីមួយដេរដាសពេញទៅដោយផ្កាឈូក ៥ ពណ៌ មានទឹកជ្រៅត្រង់កណ្តាល ហ្វូងសត្វទ្វេរបាទ ចតុប្បាទនាំគ្នាចុះផឹកទឹកស្រះនោះដោយជុំវិញ ទឹកដែលជ្រៅចំកណ្តាល

ស្រះនោះ ត្រឡប់ទៅជាល្អក់ ត្រង់កន្លែងដែលសត្វទ្វេបាទ និងចតុប្បាទនាំគ្នាជាន់ទន្ទ្រាន ត្រឡប់ទៅជាថ្លាស្អាតមិនល្អក់ ។ ទូលព្រះបង្គំបានឃើញយ៉ាងនេះ ជាហេតុនៃសុបិន ខ ទី ៩ របស់ទូលព្រះបង្គំ តើអ្វីជាផលរបស់សុបិននេះ ព្រះករុណាព្រះអង្គ ?

<u>**ព្រះសម្មាសម្ពុទ្ធ**</u>-មហាបពិត្រ ផលរបស់សុបិននេះ នឹងមានក្នុងអនាគតដូចគ្នា ដោយថាក្នុងកាលខាងមុខ ព្រះរាជាទាំងឡាយនឹងមិនតាំងនៅក្នុងធម៌ លុះអគតិដោយអំណាចពេញចិត្តក្នុងកិច្ចការសោយរាជសម្បត្តិ និងមិនប្រទានការវិនិច្ឆ័យក្តីដោយធម៌ មានព្រះរាជហឫទ័យសំដៅចំពោះតែសំណូក សាវ៉ាក្នុងទ្រព្យសម្បត្តិ ដែលឈ្មោះថាគុណធម៌ គឺការអត់ធន សេចក្តីមេត្តា និងការស្រឡាញ់ពេញចិត្តរបស់ព្រះរាជា និងមិនមានក្នុងពួកប្រជាពលករ ខេត្តខ័ណ្ឌ និងជាអ្នកកូឡះ(រឹងរូស) អាសគ្រាម ធ្លាប់បៀតបៀនពួកមនុស្ស ដូចគាបអំពៅដោយគ្នាបយន្ត និងកំណត់ប្រាក់ពន្ធអាករផ្សេងៗ បង្កើតឡើងដើម្បីប្រមូលយកទ្រព្យ ។ ពួកមនុស្សត្រូវរិបយកពន្ធអាករធ្ងន់ មិនអាចនឹងមានអ្វីឱ្យបាន ត្រូវនាំគ្នារត់ទៅ

នៅតាមនិគម ឆ្ពោះទៅជាយដែន តាំងមូលដ្ឋាននៅទីកន្លែងនោះអស់ ។ ប្រទេសជាទីប្រជុំជនសូន្យកណ្តាលនឹងទំនេរ ឯជនបទជាយដែននឹងមានមនុស្សរស់នៅកុះករ ដូចទឹកស្រះបោក្ខរណីល្អក់កណ្តាល នៅខាង១ថ្លាយ៉ាងណា ក៏ដូច្នោះ ។ ភ័យសូម្បីមានសុបិននេះជាហេតុក៏រមែងមិនមានដល់មហាបពិត្រ សូមទ្រង់ត្រាស់ប្រាប់ព្រះសុបិន ខ ទី ១០ មកចុះមហាបពិត្រ !

## មហាសុបិនទី ១០

__ព្រះរាជា__=បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបានឃើញបាយឆ្អិនដែលគេចំហុយដោយខ្ទះនៅក្នុងឆ្នាំងតែមួយជាមួយគ្នាសុទ្ធ១ មិនឆ្អិនទាំងអស់ទេ ដោយអ្នកដាំចំហុយត្រួតពិនិត្យមើលទៅឃើញថាមិនឆ្អិនសព្វឡើយ មួយចំណែកជាបាយខ្លោច មួយចំណែកជាបាយឆៅ មួយចំណែកទៀតជាបាយឆ្អិន នេះជាសុបិនទី ១០ របស់ទូលព្រះបង្គំ តើអ្វីជាផលនៃសុបិន ខ នេះ ព្រះករុណាព្រះអង្គ ?

**ព្រះសម្មាសម្ពុទ្ធ**-មហាបពិត្រ ផលសូម្បីរបស់សុបិន ខ នេះនឹងមានក្នុងអនាគតដូចគ្នា ដោយថា ក្នុងអនាគតកាលខាងមុខ ព្រះរាជាទាំងឡាយនឹងមិនតាំងនៅក្នុងធម៌ ពេលព្រះរាជាទាំងនោះមិនតាំងនៅក្នុងធម៌ហើយ ខ្ញុំរាជការក្តីព្រាហ្មណ៍និងគ្រហស្ថក្តី ប្រជាពលរដ្ឋនិគម ប្រជាពលករជនបទក្តី រួមដល់មនុស្សទាំងអស់ រាប់តាំងពីសមណៈ និងព្រាហ្មណ៍នាំគ្នាមិនតាំងនៅក្នុងធម៌ សូម្បីទេវតាទាំងឡាយក៏មិនតាំងនៅក្នុងធម៌ ព្រោះជាស្តេចអធម្មិករាជ ខ្យល់ទាំងឡាយបក់ផាត់មិនស្មើ ផាត់ខ្លាំងធ្វើឱ្យវិមានក្នុងអាកាសរបស់ទេវតាញាប់ញ័រ ពេលវិមានទាំងនោះត្រូវខ្យល់ផាត់ញាប់ញ័រ ហើយពួកទេវតាក៏នាំគ្នាក្រោធ នឹងមិនឱ្យមានភ្លៀងធ្លាក់ថែមហើយថែមទៀតឱ្យកាន់តែខ្លាំងទៅតាមខេត្តខ័ណ្ឌ បើមិនដូច្នោះ ភ្លៀងនឹងមិនធ្លាក់ឱ្យជាឧបការៈ ដល់ការសាបព្រួសក្នុងទីទាំងពួង នឹងមិនធ្លាក់គ្រាប់ភ្លៀងទៅដល់សូម្បីជនបទសូម្បីក្នុងភូមិ សូម្បីក្នុងត្រពាំងមួយ សូម្បីក្នុងស្រះតូចមួយដូចគ្នាក្នុងដែនដូច្នោះ ។ ពេលធ្លាក់ភ្លៀងពីលើត្រពាំងក៏នឹងមិនធ្លាក់ក្នុងកន្លែងក្រោម ពេលធ្លាក់ក្នុងទីកន្លែងខាង

ក្រោម នឹងមិនធ្លាក់ក្នុងកន្លែងខាងលើ សន្ទូង ស្រូវនឹងក្រៀមក្រស់ ពេលភ្លៀងធ្លាក់ល្អក្នុងកន្លែងណាមួយ សន្ទូងនឹងសម្បូរណ៍ សន្ទូងដែលសាបព្រួសហើយក្នុងខ័ណ្ឌសីមារបស់ព្រះរាជាមាន ៣ ស្ថាន ដោយប្រការដូច្នេះ ។ ភ័យសូម្បីមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រ សូមព្រះរាជាទ្រង់ត្រាស់ប្រាប់សុបិនទី ១១ តទៅទៀតចុះមហាបពិត្រ !

## មហាសុបិនទី ១១

**ព្រះរាជា**-បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបានឃើញមនុស្សទាំងឡាយ យកខ្លឹមចន្ទមានតម្លៃរាប់សែន កហាបណៈទៅដូរយកខ្លាញ់ស្អុយ នេះជាសុបិនទី ១១ របស់ទូលព្រះបង្គំ តើអ្វីជាផលនៃសុបិននេះ ព្រះករុណាព្រះអង្គ ?

**ព្រះសម្មាសម្ពុទ្ធ**-មហាបពិត្រ សូម្បីផលនៃសុបិននេះក៏នឹងមានក្នុងអនាគត ក្នុងពេលសាសនារបស់តថាគតចុះ

ឱនថយទ្រោមនោះឯង ដោយថាក្នុងកាលខាងមុខ ពួកភិក្ខុអលជ្ជីឃើញតែបច្ច័យ ៤ ។ ពួកទាំងនោះនឹងនាំគ្នាសម្ដែងធម្មទេសនាដែលតថាគតពោលតិះដៀលក្នុងការលោភ នូវបច្ច័យទុកដល់ពួកជនដទៃ ព្រោះហេតុតែបច្ច័យ ៤ មានចីវរប្បច្ច័យជាដើម នឹងមិនអាចសម្ដែងឱ្យផុតពីបច្ច័យទាំងឡាយ ហើយតាំងនៅក្នុងធម៌នាំសត្វឱ្យផុតចាកទុក្ខ តំរង់ចំពោះព្រះនិព្វាន ។ ជនទាំងឡាយនឹងស្ដាប់នូវសេចក្ដីសម្បូរណ៌នៃបទ និងព្យញ្ជនៈ និងសំនៀងដែលពិរោះតែម៉្យាងទាំងនោះហើយ នឹងបូជាឯងហើយញ៉ាំងជនដទៃឱ្យថ្វាយនូវបច្ច័យទាំងឡាយ មានចីវរជាដើម ដែលមានតម្លៃច្រើន ភិក្ខុទាំងឡាយពួកខ្លះទៀតនាំគ្នាអង្គុយក្នុងទីផ្សេងៗ មាននៅតាមផ្លូវថ្នល់បែក ជា ៤ និងមាត់ទ្វារព្រះបរមរាជវាំងជាដើម ហើយសម្ដែងធម៌ដូរយករូបិយៈ មានរៀល កហាបណៈ កន្លះកហាបណៈ រៀលបាតរៀលមាសកៈជាដើម ដោយប្រការដូច្នោះ ។ យកធម៌ដែលតថាគតសម្ដែងទុក មានតម្លៃរាប់ប្រមាណមិនបាន គួរដល់ព្រះនិព្វាន បែរជាទៅសម្ដែងដូរយកបច្ច័យ ៤ និងរូបិយៈមានរៀលកហាបណៈ និងរៀលកន្លះកហាបណៈជាដើម នឹង

ដូចជាហ្វូងមនុស្ស យកខ្លឹមច័ន្ទមានតម្លៃរាប់សែនកហាបណៈ ទៅដូរយកខ្លាញ់ស្អុយដូច្នោះ ។ ភ័យសូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រ សូមស្តេចទ្រង់ត្រាស់ប្រាប់សុបិន ខ ទី ១២ តទៅទៀតចុះ មហាបពិត្រ !

## មហាសុបិនទី ១២

**ព្រះរាជា**-បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបានឃើញ ផ្លែឃ្លោកដែលគេយកបណ្តូលចេញអណ្តែតទឹក ប៉ុន្តែវាត្រឡប់ជាលិចចុះទៅក្នុងទឹកទៅវិញ តើអ្វីទៅជាផលនៃសុបិននេះ ព្រះករុណាព្រះអង្គ ?

**ព្រះសម្មាសម្ពុទ្ធ** - មហាបពិត្រផលនៃសុបិន្តនេះក៏នឹងមានក្នុងអនាគតកាល ពេលលោកចុះឱនថយដល់ទីបំផុតក្នុងរជ្ជកាលរបស់ព្រះរាជា អ្នកមិនតាំងនៅក្នុងធមិ ដោយថាក្នុងគ្រានោះព្រះរាជាទាំងឡាយ នឹងមិនព្រះរាជទានយសដល់

កុលបុត្រអ្នកសម្បូណ៌ដោយជាតិ នឹងព្រះរាជទានដល់អ្នកមិនមានវង្សត្រកូលល្អទាំងនោះ ពួកនោះនឹងជាធំ ឯពួកម្ខាងទៀតនឹងលំបាករហូត ។ ពាក្យសំដីរបស់ពួកមិនមានវង្សត្រកូលល្អ ដូចឃ្លោកអណ្តែតទឹក ប្រដូចនឹងការស្ទង់សម្លឹងចុះមើលក្នុងទីចំពោះព្រះភ័ក្ត្រព្រះរាជាក្តី នៅមាត់ទ្វាររាំងក្តី ទីប្រជុំអាមាត្យក្តី កន្លែងរង្គសាលក្តី មានពាក្យនិយាយចំអកឡកឡឺយ សូម្បីក្នុងសង្ឃសន្និបាត (ទីប្រជុំសង្ឃ) ពោលក្នុងកិច្ចកម្មដែលសង្ឃគប្បីធ្វើ និងគណៈគប្បីធ្វើក្តី ទាំងក្នុងទីស្ថានដំណើរអធិការទាក់ទងជាមួយនឹងបាត្រចីវរ និងបរិវេណជាដើមក្តី ពាក្យសំដីរបស់មនុស្សទ្រុស្តសីលទាំងនោះ នឹងជាពាក្យនាំសត្វចេញចាកពីទុក្ខម្តេចបាន ព្រោះមិនមែនជាពាក្យសំដីរបស់ភិក្ខុលជ្ជី ។ កាលបើដូច្នេះ ក៏នឹងដូចជាកាលដែលលិចចុះនៃឃ្លោកអណ្តែតទឹក សូម្បីដោយប្រការទាំងពួង ។ ភ័យមានសុបិននេះជាហេតុក៏មិនមានដល់មហាបពិត្រ សូមស្តេចទ្រង់ត្រាស់ប្រាប់ សុបិន ខទី ១៣ មកទៀតចុះមហាបពិត្រ !

# មហាសុបិនទី ១៣

**ព្រះរាជា**-បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបាន ឃើញដុំសិលាមួយធំខ្នាតស្មើប៉ុនកំពូលប្រាសាទអណ្តែតទឹកដូច ទូក តើអ្វីជាផលនៃសុបិននេះព្រះករុណាព្រះអង្គ ?

**ព្រះសម្មាសម្ពុទ្ធ**-មហាបពិត្រផលនៃសុបិននេះ ក៏ នឹងមានក្នុងកាលដូច្នោះ ដូចគ្នាដោយថាក្នុងគ្រានោះ ព្រះរាជា អ្នកមិនតាំងនៅក្នុងធមិទាំងឡាយ នឹងព្រះរាជទានយសដល់ មនុស្សមិនមានត្រកូលល្អ ពួកនោះនឹងជាធំ ពួកមានវង្ស ត្រកូលល្អនឹងត្រូវព្រួយលំបាក ព្រោះមិនគោរពដល់ពួកមានវង្ស ត្រកូលមិនល្អនោះ ។ ពាក្យសំដីរបស់ពួកវង្សត្រកូលអ្នកឆ្លាត ក្នុងការវិនិច្ឆ័យ អ្នកចូទ់ណែនដូចជាដុំសិលា នឹងមិនលិចចុះ តាំងមាំក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ឬក្នុងទីប្រជុំអាមាត្យ ឬ ក្នុងរង្គសាល ។ កាលពួកនោះកំពុងនិយាយ ពួកខាងវង្ស ត្រកូលមិនល្អនេះនឹងរង់ចាំតិះដៀលទិទៀនថា ពួកនេះនិយាយ ធ្វើជាប្រកាន់ចាំចាប់ថ្នាក់ សូម្បីក្នុងទីប្រជុំភិក្ខុ ពួកភិក្ខុនឹងមិន មានឃើញភិក្ខុដែលមានសីលជាទីស្រឡាញ់ គួរធ្វើការគោរព

សំគាល់ថា ក្នុងឋានះផ្សេងៗ ដូចពោលមកហើយ ទាំងពាក្យសំដីរបស់ភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងនោះ ក៏នឹងមិនធ្ងន់ណែន ឋិតថេរ នឹងដូចជាវេលាដែលអណ្តែតនៃដុំសិលាដូច្នោះ ។ ភ័យ សូម្បីមានក្នុងសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រ សូមព្រះរាជាទ្រង់ត្រាស់ព្រះសុបិន ខ ទី ១៤ មកទៀតចុះមហាបពិត្រ !

## មហាសុបិនទី ១៤

__ព្រះរាជា__-បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបានឃើញហ្វូងមេក្អាត់តូចៗដូចកូនកង្កែប ដេញតាមខាំហ្វូងពស់វែកធំៗ ខាំសាច់ដាច់ដូចជាគេកាត់ទងផ្កាឈូក ហើយបរិភោគ នេះជាសុបិនទី១៤ តើអ្វីជាផលនៃសុបិននេះព្រះករុណាម្ចាស់ ?

__ព្រះសម្មាសម្ពុទ្ធ__- មហាបពិត្រ ផលនៃសុបិន ខ នេះ ក៏នឹងមានក្នុងអនាគត ក្នុងពេលលោកអាប់ឱនទ្រោមដូចគ្នា

ដោយថាក្នុងគ្រានោះ ពួកមនុស្សនឹងមានរាគៈច្រើនខ្លាំងក្លា កំណើតអាក្រក់បណ្តែតបណ្តោយខ្លួនទៅតាមចិត្តដោយអំណាចនៃកិលេស ដែលនឹងប្រព្រឹត្តទៅក្នុងអំណាចនៃភរិយាក្មេងៗរបស់ខ្លួន ។ អ្នកមានទាសៈ (អ្នកបំរើ) និងកម្មករជាដើមក្តី សត្វពាហនៈ មានគោក្របីជាដើមក្តី ប្រាក់មាសក្តី ក្នុងបណ្តាមានអ្វីៗគ្រប់យ៉ាងក្នុងផ្ទះ នឹងត្រូវនៅក្នុងការគ្រប់គ្រងរបស់ពួកនាងស្ត្រីៗទាំងអស់ កាលបើស្វាមីសួររកប្រាក់មាស ថានៅទីណា ឬសួរដល់ចំនួនវត្ថុ ថាមាននៅទីកន្លែងណា ពួកនាងស្ត្រីៗក៏នាំគ្នាឆ្លើយថា ចាស់ ខ្ញុំមិនដឹងនៅទីណាៗ ជួនណាថានៅលើជាង ។ គ្រោងការណ៍អ្វីៗដែលស្វាមីត្រូវ ត្រួតពិនិត្យគ្មានបានការណ៍អ្វីសោះ ព្រោះគេចង់ដឹងទ្រព្យសម្បត្តិដែលមាន ឬនឹងមិនមាននៅក្នុងផ្ទះរបស់គេនីមួយៗ។ កាលបើមិនឃើញមាន ស្វាមីក៏ជេរប្រទេចដោយប្រការផ្សេងៗ មានពាក្យដាល់តប់ដោយលំពែងគឺមាត់ បង្ខំក្នុងអំណាច ដូចអ្នកបំរើរបស់ខ្លួន តាំងភាពម្ចាស់ជាធំ ។ កាលបើដូច្នេះ ក៏នឹងដូចវេលាហ្វូងមេក្អាត់តូចៗ នាំគ្នាលេបស៊ីពួកហ្វូងពស់ពិស ដែលមានពិសយ៉ាងរហ័សដូច្នោះ ។ ភ័យសូម្បីមានសុបិននេះជាហេតុ

ក៏នឹងមិនមានដល់មហាបពិត្រទេ សូមស្ដេចទ្រង់ត្រាស់ប្រាប់នូវនិមិត្ត ខ ទី ១៥ មកទៀតចុះ !

## មហាសុបិនទី១៥

**ព្រះរាជា**-បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំបានឃើញហ្វូងស្ដេចហង្សមាសដែលមាននាមថា "មាស" ព្រោះមានរោមជាពណ៌មាសនាំគ្នាចោមរោមសត្វក្អែក ជាអ្នកប្រកបដោយអសទ្ធម្ម ១០ ប្រការ ហើយរកបរិភោគតាមផ្ទះ តើអ្វីជាផលនៃព្រះសុបិននេះ ព្រះករុណាព្រះអង្គ ?

**ព្រះសម្មាសម្ពុទ្ធ** - មហាបពិត្រ ផលនៃសុបិននេះក៏នឹងមានក្នុងអនាគត ក្នុងរជ្ជកាលរបស់ព្រះរាជាអ្នកទុព្វលនោះ ហើយដោយថា ក្នុងចំណោកខាងមុខព្រះរាជាទាំងឡាយ នឹងមិនឆ្លាតក្នុងសិល្បៈមានការសើចញញឹមជាដើម មិនក្លៀវក្លាក្នុងការប្រយុទ្ធ មិនប្រទានភាពជាធំឱ្យដល់ពួកកុលបុត្រដែលមានជាតិស្មើគ្នា មិនពេញចិត្តការវិបត្តិនៃរាជសម្បត្តិរបស់

ព្រះអង្គទ្រង់ព្រះរាជទាន ដល់ពួកភ្នាក់ងារគ្រឿងស្រវ៉ឹងនិងពួកជាងកាត់សក់ កោរសក់ជាដើម ដែលនៅជិតបាទ ឬសគល់របស់ព្រះអង្គ។ ពួកកុលបុត្រអ្នកសម្បូរណ៍ដោយជាតិល្អ និងគោត្រ កាលមិនបានទីពឹងក្នុងរាជវង្ស ក៏មិនអាចមានការចិញ្ចឹមជីវិតរស់នៅបាន នាំគ្នាប្រណិបត្តិទំនុកបំរុងពួកជនដែលមិនមានវង្សត្រកូលល្អ មានជាតិនិងគោត្រថោកទាប ជាអ្នកតាំងនៅមានឥស្សរិយយស និងដូចជាហ្វូងរាជហង្សមាសហែហមជាបរិវារសត្វក្អែកដូច្នោះ។ ភ័យសូម្បីមានសុបិននេះជាហេតុក៏មិនមានដល់មហាបពិត្រ សូមព្រះរាជាទ្រង់ត្រាស់ពោលសុបិន ខ ទី ១៦ តទៅចុះ មហាបពិត្រ !

## មហាសុបិនទី ១៦

**ព្រះរាជា**-បពិត្រព្រះអង្គដ៏ចំរើន ក្នុងកាលមុនៗ ខ្លាដំបងនាំគ្នាចាប់ស៊ីសត្វពពែ ប៉ុន្តែទូលព្រះបង្គំបានឃើញហ្វូង

សត្វពាំពែនាំគ្នាប្រដេញហ្វូងសត្វខ្លាដំបង ចាប់បរិភោគនៅទីនោះ ខ្លាដទៃៗ គឺខ្លារខិន ខ្លាធំ ឃើញហ្វូងពាំពែនៅឆ្ងាយក៏ភ័យញ័រ ខ្លាចដល់ភាពស្លុតរន្ធត់ នាំគ្នារត់គេចសំរាកក្នុងព្រៃលាក់លៀមព្រោះខ្លាចហ្វូងពាំពែ ទូលបង្គំបានឃើញយ៉ាងនេះតើអ្វីជាហេតុផលនៃសុបិននេះព្រះករុណាព្រះអង្គ ?

<u>ព្រះសម្មាសម្ពុទ្ធ</u>–មហាបពិត្រ ផលនៃសុបិននេះក៏នឹងមានក្នុងរជ្ជកាលនៃព្រះរាជាអ្នកមិនតាំងនៅក្នុងធម៌ ក្នុងអនាគតដូចគ្នា ដោយថាក្នុងគ្រានោះ ពួកមិនមានត្រកូលល្អជាទីចូលចិត្តរបស់ព្រះរាជាបានធ្វើជាអ្នកធំ ពួកមនុស្សមានត្រកូលល្អនឹងអាប់ឱនឆោតលំបាក អ្នកបំរើព្រះរាជាគឺអ្នកស្និទ្ធស្នាលទាំងនោះ នាំគ្នាទូលព្រះរាជាឱ្យទ្រង់កាន់យកពាក្យសំដីរបស់ខ្លួន មាននៅក្នុងរាជាការ មានក្នុងសាលជាដើម នាំគ្នារុករានយកដីស្រែ ចំការ ហៅថាសួនជាដើម ហើយរាតត្បាតបន្តមកកដល់ដីស្រែចំការរបស់ពួកមានត្រកូលល្អទាំងឡាយថាទីកន្លែងទាំងនោះជារបស់ពួកយើង ។ ពេលពួកមានត្រកូលល្អទាំងនោះប្រកែកថា មិនមែនរបស់ពួកលោកទេ ជារបស់ពួកយើង គេបាននាំគ្នាមកស្រែកដល់ទីកន្លែង ហើយចាប់ពួក

ត្រកូលល្អអួសទាញចេញ ព្រមទាំងសំឡុតគំរាមដោយពោលពាក្យថា អ្នកមិនដឹងប្រមាណខ្លួន មករករឿងជាមួយពួកយើង ឥឡូវពួកយើងនឹងទៅទូលព្រះរាជា ឱ្យដាក់ព្រះរាជអាជ្ញាផ្សេងៗមានកាត់ជើង កាត់ដៃ ជាដើម ។ ពួកអ្នកមានត្រកូលល្អខ្លាចពួករាជស្និទ្ធស្នាល ក៏នាំគ្នាសុខចិត្តព្រមព្រៀងប្រគល់ដីធ្លីរបស់ខ្លួនថា កន្លែងទាំងនេះ បើសិនជារបស់លោក ក៏សូមអញ្ជើញគ្រប់គ្រងចុះ រួចក៏នាំគ្នាទៅផ្ទះរបស់ខ្លួន ខ្លាចញញើតតៗតាមៗគ្នា ។ សូម្បីភិក្ខុអាក្រក់អ្វីទីនួទាំងឡាយ ក៏នឹងនាំគ្នាបៀតបៀនភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ភិក្ខុអ្នកមានសីលទាំងនោះ ពុំមានទីពំនាក់ ត្រូវនាំគ្នារត់ចូលព្រៃលាក់កំបាំងនៅក្នុងកន្លែងរាត់រាយៗ ។ ខ ដែលកុលបុត្រអ្នកមានជាតិក្នុងវង្សត្រកូលទាំងឡាយ ភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងឡាយ ត្រូវមនុស្សជាតិអាក្រក់ និងភិក្ខុលាមកទាំងឡាយចូលទៅប្រទូសរាយយ៉ាងនេះ និងកាលដែលពួកខ្លារខិន ខ្លាធំទាំងឡាយនាំគ្នារត់គេចពីហ្វូងចៀមដូច្នោះ ។ ភ័យសូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រដោយសុបិននេះ មហាបពិត្រឃើញហើយប្រារព្ធទៅអនាគត ប៉ុន្តែពួកព្រាហ្មណ៍

មិនបានទាយសុបិននោះ ដោយភាពស្រឡាញ់ភក្តីចំពោះព្រះអង្គ បានត្រូវរូវគ្នាទាយ ព្រោះអាស្រ័យលាភសក្ការៈការចិញ្ចឹមជីវិត ឃើញដល់អាមិស ថាពួកយើងនឹងបានទ្រព្យសម្បត្តិបរិភោគច្រើនៗ ។ ពេលទ្រង់ទាយផលនៃសុបិនធំៗ ១៦ ខ យ៉ាងនេះហើយ ព្រះសម្មាសម្ពុទ្ធត្រាស់ថា ម្នាលមហាបពិត្រ មិនមែនត្រឹមតែពេលនេះទេ ដែលមហាបពិត្របានឃើញសុបិនទាំងនេះ សូម្បីព្រះរាជាទាំងឡាយមុនៗ ក៏បានទ្រង់ឃើញរួចហើយដូចគ្នា ។ ពួកព្រាហ្មណ៍កាន់យកសុបិនទាំងនោះរាប់ចូលភាពប្រសើរបញ្ចូពិធីនេះដូចគ្នា ។ ខាងក្រោយមកអាស្រ័យពាក្យណែនាំដែលពួកបណ្ឌិតនាំគ្នាក្រាបទូល ទើបសួរព្រះពោធិសត្វ សូម្បីបុរាណបណ្ឌិតទាំងឡាយ ពេលទាយសុបិនទាំងនេះដល់ព្រះរាជាទាំងនោះៗ នាំគ្នាទាយតាមទំនងនេះ ហើយដែលព្រះបាទបសេនទិកោសល ទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីត មកសាធកៈ( ជួយធ្វើឱ្យកើតផលប្រយោជន៍) ដូចតទៅនេះៈ-

ក្នុងអតីតកាល គ្រាព្រះបាទ **ព្រហ្មទត្ត** សោយរាជសម្បត្តិនៅក្នុងក្រុងពារាណសី ព្រះពោធិសត្វយោនយក

កំណើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍។ ចំរើនវ័យហើយចូលបួសជាតាបសឥសី បានសំរេចអភិញ្ញា សំរេចឈានសមាបត្តិនៅហេមវន្តប្រទេស ។ ក្នុងគ្រានោះ នៅនគរពារាណសីព្រះបាទព្រហ្មទ័ត ទ្រង់ឃើញព្រះសុបិនដោយទំនងនេះដូចគ្នាទ្រង់មានព្រះតម្រាស់ សួរពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ប្រាប់ថានឹងត្រូវបូជាយ័ញ្ញ យ៉ាងនេះដូចគ្នា ។ បណ្តាព្រាហ្មណ៍ទាំងនោះពួកបុរោហិតមានសិស្សជាបណ្ឌិតឆ្លាតនិយាយ និងលួងលោមអាចារ្យថា លោកអាចារ្យប្រុងស្តាប់ គម្ពីរព្រះវេទទាំង ៣លោកអាចារ្យ ឱ្យខ្ញុំរៀនចប់ហើយក្នុងព្រះវេទទាំង ៣ គម្ពីរនោះ ខ ដែលថា ការសម្លាប់មនុស្សម្នាក់ហើយ ធ្វើឱ្យមានសិរីសួស្តីដល់អ្នកដទៃម្នាក់ទៀត មិនមានឡើយ មែនទេឬ ?ប្រពៃហើយ ! លោកអាចារ្យឆ្លើយថា បិតាគុណ ដោយឧបាយនេះទ្រព្យ ចំនួនច្រើននឹងកើតដល់ពួកយើង មាណពពោលថាលោកអាចារ្យ បើសិនដូច្នោះ សូមលោកចាត់ចែងធ្វើការងាររបស់លោកចុះ ខ្ញុំបាទនឹងចាត់ចែង ធ្វើការងារអ្វីៗរបស់លោកតាមក្រោយ រួចក៏ដើរប្រាប់គ្នារៀងដរាប រហូតដល់ព្រះរាជឧទ្យាន ។ ក្នុងថ្ងៃនោះឯង ព្រះពោធិសត្វបានទ្រង់ជ្រាបហេតុ

នោះដែរ គិតថា ថ្ងៃនេះពេលយើងទៅដល់កន្លែងនោះ ត្រូវគេចចេញឱ្យផុតពីការកំណត់រង់ចាំនៃមហាជន។ ដូច្នេះហើយទើបហោះមកតាមផ្លូវអាកាស ចុះនៅក្នុងឧទ្យានអង្គុយលើផែនសិលាមង្គល (ចំរើន) ដូចរូបដែលធ្វើដោយមាសដូច្នោះ។ ចំណែកមាណពក៏ចូលទៅរកព្រះពោធិសត្វថ្វាយបង្គំ រួចអង្គុយនៅកន្លែងមួយ បានស្វាគមន៍ដល់ព្រះពោធិសត្វ សូម្បីព្រះពោធិសត្វបានធ្វើបដិសណ្ឋារយ៉ាងគោរពជាមួយគេហើយសួរថា ានហេតុការណ៍អ្វីហ្ន៎ បិតាមាណព ព្រះរាជាសោយរាជសម្បត្តិដោយធម៌ឬ ? មាណពក្រាបសំពះទូលថា បពិត្រព្រះតាបសជាម្ចាស់ដ៏ចំរើន ព្រះរាជាមានព្រះនាមថា **ធម្មិករាជ** ប្រថាប់នៅប្រុងចាំស្តាប់ពួកព្រាហ្មណ៍ដែលកំពុងទូលព្រះអង្គឱ្យដើរទៅរកផ្លូវខុស ព្រះរាជាទ្រង់ឃើញព្រះសុបិន ១៦ ខ បានត្រាស់ដល់ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ពោលថា ពួកយើងនឹងធ្វើពិធីបូជាយញ្ញ ហើយត្រៀមធ្វើការងារនោះជាបន្ទាន់ ។ បពិត្រអ្នកដ៏ចំរើន សូមព្រះគុណម្ចាស់ធ្វើឱ្យព្រះរាជាយល់ជឿជាក់ពិតប្រាកដថាផលនៃសុបិនទាំងនេះយ៉ាងណា ហើយជួយឱ្យមហាជនរួចផុតពីភ័យ ? ព្រះពោធិសត្វពោលថា បិតាមាណព

យើងក៏មិនដឹងព្រះរាជា ឯព្រះរាជាក៏មិនបានទ្រង់ដឹងយើង បើសិនព្រះអង្គស្តេចមកសួរនៅទីកន្លែងនេះ យើងគប្បីទូល ដល់ព្រះអង្គបាន ។ មាណពក្រាបថ្វាយបង្គំទៀតថា បពិត្រ ព្រះគុណម្ចាស់អ្នកចំរើន ខ្ញុំព្រះករុណានឹងនាំ ព្រះអង្គស្តេចយាង មកឥឡូវ សូមព្រះគុណម្ចាស់ស្តេចបានប្រោស គង់រង់ចាំការ មកដល់របស់ខ្ញុំព្រះករុណាមួយភ្លែត សាធុ! ប្រពៃហើយ ព្រះពោធិសត្វ ក៏ទ្រង់បញ្ជាក់យ៉ាងច្បាស់ មាណពរត់តម្រង់ ឆ្ពោះទៅព្រះរាជដំណាក់ ក្រាបទូលព្រះរាជា បពិត្រមហារាជ ជាម្ចាស់ តាបសធ្វើដំណើរមកតាមផ្លូវអាកាសមួយព្រះអង្គ ឯង បានចុះក្នុងឧទ្យានរបស់ព្រះអង្គ ដោយពោលថានឹង ទាយផលរបស់សុបិនដែលព្រះអង្គទ្រង់ឃើញ ដែលកំពុងរង់ចាំ ព្រះអង្គ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់មាណពនោះ ស្តេចក៏ ស្រូតរូតប្រញាប់ទៅព្រះរាជឧទ្យាន ជាមួយនឹងបរិវារយ៉ាង ច្រើនជាបន្ទាន់ ពេលយាងទៅដល់ភ្លាម ទ្រង់សំពះព្រះតាបស ហើយប្រថាប់គង់នៅទីដ៏សមគួរស្ងួនម្ខាង ។ ទ្រង់ព្រះតម្រាស់ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន បានឮថាព្រះគុណម្ចាស់ជ្រាប ផលនៃសុបិនដែលខ្ញុំព្រះករុណាឃើញឬ ? ។

ព្រះពោធិសត្វត្រាស់ថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពជ្រាប !

ព្រះរាជាទ្រង់ទូលថា បើសិនដូច្នោះសូមនិមន្តព្រះគុណម្ចាស់ ព្រះរាជទានព្យាករណ៍ ។ ព្រះពោធិសត្វពោលថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពនឹងព្យាករថ្វាយ សូមមហាបពិត្រទ្រង់ពោលព្រះសុបិន តាមដែលទ្រង់បានឃើញឱ្យអាត្មាភាពស្តាប់មកចុះ ។

ព្រះរាជាត្រាស់ថា ល្អណាស់ព្រះគុណម្ចាស់ដ៏ចំរើន ពោលទូលដូចគ្រាមុន ថា :

គោឧសុភរាជ ១ ដើមឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ ១ ថាសមាស ១ មេឆ្កែចចក ១ ក្អមទឹក ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ឃ្លោកលិចទឹក ១ សិលាអណ្តែតទឹក ១ មេកង្កែបទាំងឡាយ ខាំស៊ីលេបពស់វែក ១ ហង្សមាសហែហមសត្វក្អែក ១ ខ្លារខិន ខ្លាធំខ្លាចសត្វពពែពិត១ ១ ដូច្នេះ ។ ហើយទូលប្រាប់សុបិនតាមនិយម ដែលព្រះបាទ**បសេនទិកោសល** បានប្រាប់នោះឯង សូម្បីព្រះពោធិសត្វ

ក៏ទាយផលសុបិនទាំងនោះ ដោយពិស្តារតាមទំនងដែលព្រះសាស្តាទ្រង់ទាយទុកក្នុងពេលនោះភ្លាមដែរ ។ ក្នុងទីបំផុតថ្វាយព្រះពរដោយខ្លួនឯងដូច្នេះថា នឹងប្រព្រឹត្តិទៅដល់ពេលលោកចុះអាប់ឱន នឹងមិនមានក្នុងយុគ្គសម័យនេះទេ ។ អត្ថាធិប្បាយក្នុងពាក្យនោះមានដូច្នេះគឺ ម្នាលមហាបពិត្រ ផលនៃព្រះសុបិនទាំងនោះ រមែងដំណើរទៅខុសក្រិត្យក្រម លោកអធិប្បាយថារមែងប្រព្រឹត្តទៅមិនត្រង់ ជាភាពខុសពីការពិត ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ផលនៃសុបិនទាំងនោះ នឹងមានក្នុងលោកដែលចុះអន់ថយ គឺក្នុងកាលដែលម្នាក់ៗកាន់យក ខ ដែលមិនមែនហេតុថាជាហេតុ ក្នុងកាលដែលគេបោះបង់ចោលហេតុថាមិនមែនហេតុ ក្នុងកាលដែលកាន់យក ខ ដែលមិនពិតថាពិត ក្នុងកាលដែលលះបង់ ខ ដែលចំរើនថាមិនចំរើន ក្នុងកាលដែលពួកភិក្ខុអលជ្ជីកាន់តែមានច្រើនឡើង និងក្នុងកាលដែលពួកលជ្ជីភិក្ខុថយចុះនៅតិច នាំឱ្យមិនមានក្នុងយុគ្គសម័យនេះ ។ កំណាត់សេចក្តីថា ផលរបស់ព្រះសុបិនទាំងនេះនឹងមិនមានក្នុងពេលនេះ គឺក្នុងរជ្ជកាលរបស់មហាបពិត្រ ឬក្នុងសាសនារបស់តថាគត ក្នុងយុគ្គសម័យនេះ គឺក្នុងជួរ

បច្ចុប្បន្ននេះ ព្រោះហេតុនោះការបូជាយញ្ញក៏កំពុងដំណើរទៅ ដើម្បីបិទបាំងផលនៃព្រះសុបិនទាំងនេះ ទើបប្រព្រឹត្តទៅដោយឃ្លៀងឃ្លាត ដោយលើកយកការបូជាយញ្ញនោះចេញចុះ ។ ភ័យឬសេចក្ដីញាប់ញ័រ ដែលមានព្រះសុបិននេះជាហេតុ មិនមានដល់មហាពិត្រ ។ ព្រះមហាបុរសធ្វើព្រះរាជាឱ្យធូរស្រាលព្រះទ័យ ឱ្យមហាជនផុតពីការចាប់ចងហើយ ក៏ត្រឡប់ហោះឡើងទៅលើអាកាសថ្វាយឱវាទដល់ព្រះរាជា ទូន្មានឱ្យតាំងនៅក្នុងសីល ៥ ហើយថ្វាយព្រះពរថា តាំងតែពីពេលនេះតទៅសូមមហាបពិត្រ កុំចូលរួមគំនិតជាមួយពួកព្រាហ្មណ៍បូជាយញ្ញដែលមានឈ្មោះថា បសុឃាតយញ្ញ (យញ្ញសម្លាប់សត្វ) តទៅទៀត ។ គ្រាសម្ដែងព្រះធម៌ចប់ ក៏ត្រឡប់ទៅទីកន្លែងសំរាករបស់លោកតាមផ្លូវអាកាសនោះឯង ។ ចំណែកព្រះរាជាតាំងនៅក្នុងធម៌តាមឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យមានការធ្វើទានជាដើម ហើយស្ដេចរស់នៅតាមយថាកម្ម ។

ព្រះបរមសាស្ដា គ្រានាំព្រះធម៌ទេសនាមកសម្ដែងរួចហើយ ត្រាស់ឱ្យព្រះបាទបសេនទិកោសល លើកការបូជាយញ្ញចេញ ទ្រង់មានព្រះពុទ្ធតម្រាស់ថា ព្រះសុបិននេះជា

ហេតុប្បច្ច័យ ភ័យនឹងមិនមានដល់មហាបពិត្រ សូមមហាបពិត្រលើកការបូជាយញ្ញចេញ ដើម្បីព្រះរាជទានជីវិតដល់មហាជន រួចទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាព្រះអានន្ទក្នុងពេលនេះ មាណពបានមកជាព្រះសារីបុត្រ ចំណែកព្រះតាបសបានមកជាយើងតថាគតដូច្នេះឯង ។

ក៏កាលគ្រានោះហើយ ពេលព្រះមានព្រះភាគជាម្ចាស់ស្ដេចបរិនិព្វានផុតទៅ ព្រះ សង្គីតិការចារ្យ ទាំងឡាយលើកបទទាំង ៣ មានអសុភាជាអាទិ៍ឡើងចំពោះអដ្ឋកថា ពោលបទទាំង ៥ មាន **លាភូនិជាអាទិ** លើកឡើងចំពោះ **បាលីឯកនិបាត** ដោយប្រការដូច្នេះ ។

# ខ្លឹមសារធម៌គួរពិចារណា

នៅក្នុងមហាសុបិន ១៦ ខ នេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្យាករទុកជាមុន នៅពេលដែលព្រះអង្គកំពង់និមន្ត សម្តែងធម៌ប្រោសវេនេយ្យសត្វ ក្នុងកំឡុងព្រះជន្មាយុគង់នៅ ចាប់តាំងពីបានត្រាស់ដឹងធម៌នៅក្រោមដើមមហាពោធិព្រឹក្ស គំរប់ ៤៥ ព្រះវស្សាបរិបូណ៌ ។ ការព្យាករណ៍សុបិននេះ សម្រាប់អនាគត ពេលលោកឬសកលលោក គឺមិនសំដៅចំពោះ ទៅលើប្រទេសណានិមួយៗ ដែលលោកត្រូវចុះអន់ថយ រវាង សាសនារបស់ព្រះទសពលនោះឯង ។ ចាប់ពីពេលនោះរហូត មកដល់ឥឡូវនេះ មានចំនួនជាង **២៥៤៦** ឆ្នាំហើយដែល ស្របទៅតាមផែនដី និងអាយុមនុស្សកំពុងខែចុះជិតដល់ទី បំផុតផង ។ ព្រោះថា ផែនដីដែលកើតឡើងមាន ៤ កប្បតូច ស្មើនឹងមួយមហាកប្ប (កប្បធំ) មួយកប្បតូចទី ១[១] ផែនដីចាប់ផ្តើមកើតឡើង និងកំពុងលូតលាស់រីកចំរើន មាន

---

១- វិវដ្តកប្ប គិតតាំងពីពេលដែលកប្បកើតឡើងទៅទល់នឹងពេល ដែលព្រះអាទិត្យព្រះចន្ទ័កើតមាន ។

៦៤ អន្តរកប្ប ។ មួយកប្បតូចទី ២[១] ផែនដីកំពុងរីកចំរើនដល់កំពូល មាន ៦៤ អន្តរកប្ប ។ កប្បតូចទី ៣[២] ផែនដីចាប់វិនាសទៅវិញពីកំពូលចុះមកក្រោមមានចំនួន ៦៤ អន្តរ-កប្ប ។ កប្បតូចទី ៤[៣] ផែនដីកំពុងវិនាសចុះដល់សូន្យមាន ៦៤ អន្តរកប្ប ។ សរុបទាំងអស់ត្រូវជា ២៥៦ អន្តរកប្ប ។

**អ្វីទៅអន្តរកប្ប** ? អន្តរកប្បគឺជាចន្លោះមួយកប្បតូចទៅមួយកប្បតូច ហើយមានថេរវេលាខែចុះ ខែឡើងរបស់អាយុមនុស្ស ៦៤ ដងនៃអន្តរកប្ប ។ ឯមួយអន្តរកប្បអាយុមនុស្សខែចុះ ចាប់ពីមួយអសង្ខេយ្យឆ្នាំ ចុះមកត្រឹម១០ ឆ្នាំហើយខែឡើងទៅវិញរហូតទៅដល់មួយអង្ខេយ្យឆ្នាំ ឯមួយអង្ខេយ្យស្មើនឹងលេខ ១ មានសូន្យមួយរយសែសិប ។ មួយចំណែកទៀត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងឡើងក្នុងរវាង

---

(១) -វិវដ្ដាយិកប្ប គិតតាំងពីពេលដែលព្រះអាទិត្យព្រះចន្ទ័កើតមានទៅទល់នឹងពេលដែលកប្បវិនាសទៅវិញ ។

(២) -សំវដ្ដកប្ប គិតតាំងពីពេលដែលកប្បកំពុងវិនាសទៅ និងវិនាសអស់រលីង ។

(៣) -សំវដ្ដដ្ឋាយិកប្ប គិតតាំងពីពេលដែលកប្បវិនាសអស់រលីងទៅទល់នឹងពេលដែលកប្បកកើតឡើងថ្មីទៀត ។

ចន្លោះអាយុមនុស្សយើងចាប់ពីមួយសែនឆ្នាំចុះមកត្រឹម ១០០ ឆ្នាំ ព្រោះថា បើលើសពីមួយសែនឆ្នាំ មនុស្សយើងស្តាប់ធម៌មិនបាន ដោយមានសេចក្តីប្រមាទនៅក្នុងវ័យរបស់ខ្លួន ។ ចំពោះមនុស្សអាយុក្រោម ១០០ វិញ រឹងរិតកាន់តែមានសេចក្តីប្រមាទខ្លាំងជាងនេះទៅទៀត ដោយកិលេសតណ្ហា មានអកុសលធម៌ជាច្រើនគ្របសង្កត់ ធ្វើឱ្យសត្វលោកវង្វេងវិលវល់ យល់អាក្រក់ថាល្អ យល់សថាខ្មៅ យល់ទុក្ខថាជាសុខ យល់អំពើថោកទាបថាជា អំពើថ្លៃថ្នូរ មិនទុកចិត្តគ្នា ប្រកាន់គ្នាពោលចាក់ដោតពាក្យសំដី ព្រោះមានការកេងប្រវ័ញ្ចលួចលាក់ទ្រព្យសម្បត្តិគ្នាទៅវិញទៅមក ដូចជាប្រពន្ធបោកបញ្ឆោតលួចលាក់ពីប្តីទៅមានប្រុសសាហាយដទៃ ដូចមាននៅក្នុងមហាសុបិនទី ១៤ នេះស្រាប់ ។

អកុសលធម៌ទាំងឡាយចំរើន បណ្តាលឱ្យមនុស្សចូលចិត្តតែប្រព្រឹត្តធ្វើអំពើបាប មិនចូលចិត្តធ្វើអំពើបុណ្យ ព្រះរាជាមិនតាំងនៅក្នុងធម៌ ពេលមានអន្តរាយអ្វីៗកើតឡើង ភ័យញាប់ញ័រតក់ស្លុត ពុំមានមធ្យោបាយដោះស្រាយ ដើររទៅស្វែងរកទីពឹងតែពីខាងក្រៅ ពុំមានទីពឹងខ្លួនឯង វិនិច្ឆ័យទៅ

តាមហេតុផល ល្ងិតល្ងង់ជឿតាមតែពាក្យគេថា ដូចព្រះរាជាទៅរកពួកព្រាហ្មណ៍ឱ្យទោះទាយជាដើម ម្លោះហើយផលអាក្រក់ដែលជាភាពអពមង្គល(ការមិនចំរើន)តែងមានដល់សត្វលោក ។

នៅក្នុងមហាសុបិនទី ១ ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករទុករួចហើយថា តទៅអនាគតនឹងមានភាពមិនទៀងទាត់ទៅតាមរដូវកាល ដូចជាមានមេឃងងិត ផ្គរលាន់គ្រប់ទិសទាំង ៤ ដូចគោឧសុភរាជរកជល់គ្នាបែរទៅជាមិនជល់គ្នាវិញ ។ បើតាមធម្មតាគោឧសុភរាជត្រូវតែជល់គ្នា ព្រោះមេឃងងិតអួរអព្វរកកល់នឹងភ្លៀង ត្រឡប់ទៅជាមិនភ្លៀង ប្រជាកសិករទាំងឡាយមានការខកចិត្តអស់សង្ឃឹម ក្នុងការប្រកបមុខរបរកសិកម្ម ដែលជាទីពំនាក់ក្នុងការរកទទួលទាន ។ បើជួនជាមានភ្លៀងវិញ ក៏ធ្លាក់មិនស្មើ ភ្លៀងធ្លាក់កន្លែងនេះបន្តិចភ្លៀងធ្លាក់កន្លែងនោះបន្តិច ឬភ្លៀងខ្លាំងពេក នាំឱ្យខូចសន្ទូងសំណាបស្រូវអស់ ។ មហាសុបិនដែលព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករទុក គ្មានអ្នកណាអាចជ្រាបដូចព្រះអង្គ ទោះបីមនុស្សក្នុងលោកព្រមទាំងទេវលោកនិងមនុស្សដ៏សេស ព្រោះសត្វទាំងនោះ ពុំមានសព្វញ្ញុតញ្ញាណជ្រាបហេតុនិងផលដូច

ព្រះអង្គ សូម្បីសាវ័កទាំងឡាយ មានព្រះសារីបុត្រ ព្រះមហាមោគ្គល្លានជាដើម ក៏ពុំមានញាណដូចព្រះសម្ពុទ្ធដែរ ។ អ្វីណាដែលព្រះអង្គបានព្យាករឬសម្តែងទុកបញ្ញត្តិហើយ អ្វីនោះសុទ្ធតែជាពាក្យពិតទាំងអស់ គ្មានពាក្យណាមួយមិនពិតឡើយ ។ នៅក្នុងលោកនេះ មានតែព្រះពុទ្ធមួយព្រះអង្គឯង ឧប្បត្តិឡើងសម្រាប់ជួយស្រោចស្រង់សត្វឱ្យរួចពីទុក្ខភ័យមាន ជាតិ ជរា ព្យាធិ និង មរណៈជាដើម ។ ព្រះអង្គជាអគ្គបុគ្គលកំពូលលើលោកទាំងមូល មានកាមលោក រូបលោកនិងអរូបលោក ។ ព្រះអង្គទ្រង់នមស្សការថ្វាយបង្គំព្រះធម៌ ឯមនុស្សដទៃគ្មាននរណាម្នាក់អាចឱ្យព្រះតថាគតថ្វាយបង្គំបានឡើយ ។ បើសិនជាអ្នកណា ត្រូវតថាគតថ្វាយបង្គំ នឹងពិតជាក្បាលអ្នកនោះធ្លាក់ពីលើស្មាជាមិនខាន ព្រោះដោយអនុភាពនៃព្រះធម៌ ។ ដឹងទេនៅពេលដែលសាវ័កទាំងឡាយធ្វើសង្គាយនារួច ក្រោយពីព្រះសមណគោតម ព្រះបរមគ្រូនៃយើងបរិនិព្វានទៅ មហាប្រថពីកំរើកញាប់ញ័រដោយភាពអស្ចារ្យនៃអំណាចព្រះធម៌ ឯព្រះសម្មាសម្ពុទ្ធក៏ដូច្នោះដែរ ព្រោះព្រះអង្គជាស្តេចនៃអ្នកប្រាជ្ញ គឺជាស្តេចនៃព្រះធម៌ អាចជ្រាបហេតុនិងផលដែលមាននៅក្នុង

លោកទាំង ៣ រហូតច្រើនលានចក្កវាឡ មិនត្រឹមតែមួយចក្កវាឡយើង ដែលមានឈ្មោះថា **មជ្ឈិមចក្កវាឡ** ជាផែនដីសម្រាប់ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ត្រាស់ដឹងឡើយ ។ ***ព្រះពុទ្ធោវាទ*** ណាដែលព្រះអង្គទ្រង់ត្រាស់សម្ដែង ដើម្បីឱ្យសត្វលោកប្រតិបត្តិតាម ព្រោះព្រះអង្គយល់អធ្យាស្រ័យទៅតាមហេតុរបស់ធម្មជាតិ ហើយក៏គ្មានអ្នកណាអាចគេចរួចពីព្រះពុទ្ធដិកា ជាសច្ចៈវាចានៃធម្មជាតិ ត្រូវតែប្រតិបត្តិតាមគោរពតាម ធ្វើតាម ទើបទទួលបាននូវសេចក្ដីសុខចំរើនតែបើមិនធ្វើតាម ប្រតិបត្តិតាម នឹងមិនរួចចាកទុក្ខទាំងពួងទាំងក្នុងបច្ចុប្បន្នសម័យ និងបរលោក ។

សូមយើងទាំងអស់គ្នាជួយពិចារណាថា តើសព្វថ្ងៃនេះមានរឿងរ៉ាវទាំងឡាយដែលកើតឡើង សមដូចផលនៃមហាសុបិននោះដែរឬទេ ? បើសិនជាមានគួរយើងត្រូវកំណត់ដឹងព្រោះផលមិនដែលប្រាសចាកហេតុ ផលល្អឬអាក្រក់កើតឡើងមិនមែនចៃដន្យ ដូចពាក្យគេនិយាយតៗគ្នានោះទេគឺទៅតាមយថាហេតុ (ផលនៃហេតុត្រូវតែកើតឡើង) ជាទោសនៃកិលេសក្នុងវដ្តៈ ទោះបីមានអ្វីមកជួយដោះស្រាយ

យ៉ាងណាក៏មិនអាចគេចផុតពីអព្វមង្គលបានឡើយ មានតែការស្វែងរកទីពឹង បានដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃប៉ុណ្ណោះទើបអាចទទួលសុខបាន ទ្រព្យសម្បត្តិទាំងឡាយយើងទីពឹងបានត្រឹមតែមួយគ្រាកំពុងរស់នៅប៉ុណ្ណោះ លុះដល់ស្លាប់ទៅពុំអាចនាំយកទៅជាមួយផងបានឡើយ ។

ក្នុងមហាសុបិនទី ២ ថាដើមឫស្សីឬដើមឈើតូចៗដុះចេញលើផែនដីប្រវែងមួយធ្នាប់ខ្លះ មួយហត្ថខ្លះ ស្រាប់តែមានផ្លែ។ ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករថា តទៅអនាគតក្មេងស្រីៗមានអាយុតិចមិនទាន់គ្រប់វ័យសមល្មមគួរមានប្តី ត្រឡប់ជាមានប្តីហើយមិនថាប្តីក្មេងៗដូចគ្នា ថែមទាំងមានស្វាមីអាយុច្រើនៗទៅទៀត នេះជាសេចក្តីវិនាសមួយ ដែលមាននៅក្នុងបរាភវសូត្រ ព្រោះមនុស្សអាយុច្រើន ឬមនុស្សចាស់ទៅយកប្រពន្ធក្មេង ដោយថា ណាមួយវាមិនស្មោះត្រង់អាចមានប្រុសសាហាយដទៃ មួយទៀតខ្លាចវាលួចលាក់ទ្រព្យសម្បត្តិ យកទៅចិញ្ចឹមពួកប្រុសដទៃ រឿងនេះក៏មានក្នុងមហាសុបិនទី ៧ ដែរ ។ សួរថា តើអ្នកណាដឹកនាំចិត្តឱ្យធ្វើយ៉ាងដូច្នេះ គឺតណ្ហាដែលមាន លោកធម៌ ៨ ប្រការចំរើនកាន់តែខ្លាំង

នៅពេលអាយុមនុស្សកំពុងខែចុះនេះឯង ។ អកុសលធម៌ទាំងឡាយសម្បូរណ៍ឡើងៗ ធ្វើឱ្យមនុស្សមានរាគៈ ទោសៈ មោហៈ គ្របសង្កត់ធ្ងន់ទ្វេ ដូចធ្លាប់ អធិប្បាយតាមអដ្ឋកថា ដែលព្រះអង្គទ្រង់ត្រាស់សម្តែងទុក ។

មួយទៀតក្នុងមហាសុបិនទី ៣ បានឃើញថា មេគោធំៗនាំគ្នាទៅបៅដោះកូនគោតូចៗដែលទើបនិងកើតក្នុងថ្ងៃនោះឯង។ ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករថា មាតាបិតាចាស់ៗត្រូវរស់នៅដោយសុំជំនួយពីកូនឬក្មេងៗទៅវិញ ។ បើតាមធម្មតាកូនគោត្រូវបៅដោះមេគោ ឯក្មេងៗត្រូវរស់នៅក្នុងការគ្រប់គ្រងបីបាច់ថែរក្សាចិញ្ចឹមពីមាតាបិតា ប៉ុន្តែមិនដូច្នោះ បែរជាមាតាបិតាចាស់ៗរស់នៅក្នុងការឧបត្ថម្ភពីកូន ដែលជាហេតុឱ្យក្មេងៗមិនខ្លាចកោតក្រែងគោរពមាតាបិតា មិនគោរពរៀមច្បង ធ្វើអំពើអ្វី តាមទំនើងចិត្តរបស់ខ្លួន នាំទៅរកសេចក្តីវិនាស ។

មហាសុបិនទី ៤ វិញ គួរពិចារណាថា ព្រះរាជាមិនតាំងនៅក្នុងធម៌ យកតែមនុស្សមិនចេះមិនដឹងឱ្យចូលធ្វើការក្នុងរាជការ មានក្នុងក្រសួងតុលាការជាដើម ហើយប្រទាន

យសសក្តិដល់ពួកនោះ ឯមនុស្សអ្នកចេះដឹងមិនឱ្យចូលធ្វើការក្នុងរាជការ មានក្នុងក្រសួងតុលាការជាដើម ហើយមិនប្រទានយសសក្តិដល់ពួកនោះ ។ មនុស្សចេះដឹងមិនសូវរាប់អាននិយមយកមកប្រើប្រាស់បំរើការងារ ដូចជាចូលធ្វើការក្នុងក្រសួងធំៗ។ លុះអ្នកនោះមិនចេះដឹងធ្វើការមិនបានសំរេច មិនប្រកបដោយគតិ យុត្តិធម៌ ធ្វើអ្វីទាំងខុស ពុំចេះពិចារណារកការពិតឱ្យបានត្រឹមត្រូវល្អ ធ្វើឱ្យប្រទេសជាតិនីមួយៗ មិនអាចប្រព្រឹត្តបានល្អ ប្រសើរ បណ្តាលឱ្យមានគ្រោះថ្នាក់ច្រើនប្រការដល់ប្រជាពលករស់នៅក្រោមអំណាចការគ្រប់គ្រងរបស់ព្រះរាជ ។ ការលំបាកលំបិន ភាពក្រីក្រតោកយ៉ាក ដូចជាកើតទុរ្ភិក្សជាដើម ធ្វើឱ្យមនុស្សប្រព្រឹត្តិអំពើខុសឆ្គងផ្សេងៗ បណ្តាឱ្យមានចោរឆក់ ប្លន់ ខ្លះទៀតរហូតដល់ទៅហ៊ានធ្វើអំពើឃាតកម្មព្រោះតែទ្រព្យសម្បត្តិ ។

មហាសុបិនទី ៩ ស្រះបោក្ខរណីមានទឹកជ្រៅត្រង់កណ្តាល ដេរដាសដុះពេញទៅដោយផ្កាឈូក ៥ ពណ៌ សត្វទេ្វបាទ សត្វចតុប្បាទ ទន្ទ្រានចុះផឹកទឹកនៅមាត់ស្រះដោយជុំវិញ ប៉ុន្តែ ត្រង់កណ្តាលទៅជាល្អក់ ឯនៅមាត់ស្រះខាងៗ

បែរជាថ្លា ។ ក្នុងរឿងនេះ តាមធម្មតាត្រូវតែល្អក់ឯខាងៗ នៅចំកន្លែងដែលសត្វចុះផឹកទឹក ចំណែកកណ្តាលស្រះទឹកជ្រៅ ត្រូវតែថ្លាទើបសម នេះជារឿងហេតុផលពិតនៅក្នុងលោក ដែលអ្នកបុថុជ្ជនអ្នកមានកិលេសរួបរិតច្រើនមិនយល់ដឹងបាន ។

ព្រះអង្គទ្រង់ព្យាករថា ចំនេរចិរកាលទៅខាងមុខ ក្នុងសាសនាព្រះអង្គ ប្រជាជនទូទាំងសាកលលោក តាមប្រទេសនិមួយៗ ត្រូវរត់រកទីតាំងរស់នៅតាមជនបទ ត្រង់កណ្តាលមិនសូវមានមនុស្សច្រើនព្រោះហេតុតែអំពើអយុត្តិធម៌ ចំរើនដោយអគតិ បង្កើតឱ្យមានភ្នាក់ងាររាជការដើរទារពន្ធអាករផ្សេងៗ រិបជាន់កេងប្រវ័ញ្ចដោយបទអាជ្ញា ។ មានការជនុំជំរះក្តីមិនត្រឹមត្រូវ ។ ធ្វើឱ្យប្រជាជនអត់ទ្រាំរស់នៅមិនបាន មិនសប្បាយក្តៅក្រហាយចិត្តដោយគ្មានប្រាក់ទប់ទល់នឹងពន្ធអាករទាំងនោះ មានព្រះភិក្ខុសង្ឃលជ្ជីនាំគ្នារត់គេចខ្លួន(គេចខ្លួន) មកជ្រកតាំងទីលំនៅតាមជនបទក្នុងព្រៃ ដែលជាកន្លែងស្ងប់ចិត្ត គឺសុខសប្បាយគ្មានអ្វីបៀតបៀនពីបទអាជ្ញារបស់ព្រះរាជា ដែលពុំមានសប្បុរសធម៌ មករកទីលាក់ខ្លួនពួនសម្ងំនៅកន្លែងមានសប្បុរសធម៌ ប្រកបដោយមេត្តាព្រហ្មវិហារធម៌ជាដើម ។

នេះជាចំណុចមួយបញ្ជាក់ថា សុខសន្តិភាពនៅក្នុងលោក មនុស្សទាំងអស់ត្រូវការអំពើល្អ(គឺកុសលធម៌) ទើបនាំមកនូវសេចក្តីសុខ ទាំងសុខកាយ ទាំងសុខផ្លូវចិត្ត ។ បើបានសុខហើយ ភោគសម្បត្តិទាំងឡាយទាំងពួងក៏រីកចំរើនរុងរឿង បើមានភោគសម្បត្តិប្រកបដោយធម៌ហើយ ជំហានមួយទៀតអាចស្វែងរកសុខធំឃើញ ព្រោះថាសុខត្រឹមមានទ្រព្យសម្បត្តិប៉ុណ្ណោះនៅមិនទាន់ថាសុខនៅឡើយ គ្រាន់តែជួយសំរួលយើងទទួលបានសុខត្រឹមផ្លូវលោក គឺបានសុខត្រឹមមួយរយៈខ្លីមួយភ្លែត លុះអស់អាយុសង្ខារ គ្មានបានអ្វីទាល់តែសោះ ទ្រព្យសម្បត្តិទាំងឡាយមិនអាចវេចខ្ចប់យកទៅបាន ឬជួយយើងកុំឱ្យចាស់ ជរា ស្លាប់ បានឡើយ ។

តាមព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង មនុស្សយើងគួរមានការឆ្លាតឈ្លាស ឆាប់យកទ្រព្យសម្បត្តិទាំងនោះទៅដូរយកសម្បត្តិធំ គឺធ្វើទាន ទើបនាំមកនូវសម្បត្តិទេវលោក (សម្បរាយិកត្ថប្រយោជន៍ ) សម្បត្តិព្រះនិញ្វន (បរមត្ថ-ប្រយោជន៍) ជាប្រយោជន៍មួយដែលកម្រក្នុងសង្សារវដ្ត ជាប្រយោជន៍មួយកើតពីការអប់រំសន្ទុំផ្លូវចិត្ត ឱ្យបានចូលទៅក្នុង

អរិយសីល អរិយសមាធិ អរិយបញ្ញា មានការអប់រំចំរើនសតិប្បដ្ឋាន វិបស្សនា ជាដើម ។

ផ្ទុយទៅវិញ កន្លែងណាពុំមានធម៌វិន័យ គឺកន្លែងនោះពុំសូវបានទទួលសេចក្តីសុខប៉ុន្មានទេ ពិតមែនតែមានការរីកចំរើនខាងសម្ភារៈ សំរាប់ជួយមនុស្សលោក ប៉ុន្តែសំភារៈសំរាប់ប្រល័យលោកក៏មានច្រើនណាស់ដែរ នេះជាវិទ្យាសាស្ត្រទំនើបដែលមានការជឿនលឿនខ្លាំងក្នុងសម័យបច្ចុប្បន្ន ជាបច្ច័យមួយនាំលោកទៅរកសេចក្តីវិនាស ដែលជាអន្តរកប្បរបស់អាយុមនុស្សកំពុងខែចុះ។ ដូច្នេះក្នុងមហាសុបិនទាំង ១៦ ខ ព្រះសម្មាសម្ពុទ្ធបានព្យាករទៅតាមហេតុ ហើយបញ្ជាក់តទៅខាងមុខ គឺជាពេលវេលាដ៏យូរអង្វែង ចាប់តាំងពីព្រះសម្មាសម្ពុទ្ធគង់ធម្មានៅឡើយរហូតមកដល់សព្វថ្ងៃ ហើយ **ពុំមាន ខ ណាមួយព្រះអង្គព្យាករថាល្អ គឺសុទ្ធតែជាផលអាក្រក់ ចំរើនតែអកុសលធម៌**។ សេចក្តីនេះជាព្រឹត្តិការណ៍មួយ ត្រូវគិតពិចារណា ព្រោះថាព្រះធម៌ជាឧបការៈជួយអភិសេកដល់សត្វនិងសាវ័កទាំងឡាយ ឱ្យបានសំរេចប្រយោជន៍ គ្រាន់តែថាសព្វថ្ងៃនេះ ព្រះអរហន្តបដិសម្ភិទា

និងព្រះអរហន្ត សុក្ខវិបស្សកៈពុំមាន ឯព្រះអនាគាមិ ព្រះសគទាមិ ព្រះសោតាបន្ន នៅមានក្នុងរវាងព្រះពុទ្ធបរិនិញ្វន ទៅកន្លងបាន**២០០០ឆ្នាំ** ទៅដល់ត្រឹម **៣០០០ ឆ្នាំ**[១] ។ តើយើងគួរធ្វើអ្វី ត្រូវស្វែងរកអ្វី បើប្រយោជន៍ទាំង ៣ នៅមានចំពោះមុខ នេះជាលាភដ៏ប្រសើរខ្លាំងណាស់ កម្រកបាន ដែលយើងកំពុងជួបនូវ **គតិសម្បត្តិ ឧបធិសម្បត្តិ កាលសម្បត្តិ** និង **បយោគសម្បត្តិ**[២] ។ ទាំង ៤ នេះ ជាសម្បត្តិរបស់មនុស្ស មិនមែនសម្បត្តិរបស់សត្វដទៃណា ក្រៅពីមនុស្ស សូម្បីព្រះសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងក៏ត្រូវមកកើតក្នុងឋានមនុស្សនេះដែរ ទោះបីឋិតនៅទេវលោកក៏ដោយ ឯការត្រាស់ដឹងត្រូវតែវិលមកឋានមនុស្ស( មានអធិប្បាយនៅខាងដើមហើយ) ។ តែបើយើងនៅស្ទាក់ស្ទើរ តំអក់រង់ចាំអ្វីណាមួយ នេះជាការខាតបង់នូវលាភដ៏ធំ ព្រោះអាយុសង្ខារ មិនឋិតនៅរង់ចាំយើងទេ បន្តិចទៀតនឹងបែកធ្លាយរាងកាយ ចាកចោលលោកនេះទៅបាត់ រួចបន្តភពថ្មី នៅ

១-មាននៅក្នុងព្រះវិន័យបិដក ចុល្លវគ្គអដ្ឋកថា ភិក្ខុនីខន្ធកៈ

២-មាននៅក្នុងបរមត្ថស ង្ខេប និង ចិត្តសង្ខេប

ក្នុងវដ្តៈ (សមុទ្រសង្សារទុក្ខ) គឺមានតែព្រះសម្មាសម្ពុទ្ធ និងសាវ័កទាំងឡាយ មានព្រះខីណាស្រព ទើបព្រះអង្គរួចខ្លួនផុតពីទុក្ខនេះបាន ។

រឿងសុបិន មិនមែនតែចំពោះព្រះរាជាពេលនេះទេ សូម្បីព្រះសម្មាសម្ពុទ្ធ កាលនៅជាព្រះពោធិសត្វ មិនទាន់បានត្រាស់ដឹងធមិក៏មានមហាសុបិន ៥ ប្រការដែរ :

**មហាសុបិនទី ១** – មហាប្រថពីដ៏ធំនេះជាទីសំណឹងដ៏ធំ ស្តេចភ្នំហិមពាន្តជាខ្នើយ ព្រះហស្តខាងឆ្វេងសណ្តូកចុះក្នុងសមុទ្រខាងកើត ព្រះហស្តខាងស្តាំសណ្តូកចុះក្នុងសមុទ្រខាងលិច ព្រះបាទទាំងគូ សណ្តូកចុះក្នុងសមុទ្រខាងត្បូង ។ ព្រះពោធិសត្វទ្រង់ព្យាករដោយព្រះអង្គឯងថា ការបានឃើញមហាសុបិនទី ១ យ៉ាងនេះ ជានិមិត្តនៃការបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ។

**មហាសុបិនទី២** – មានស្មៅចិញ្ចៀនមួយសរសៃដុះលេចចេញអំពីផ្ចិតព្រះអង្គទៅទល់នឹងអាកាស ។ ព្រះពោធិសត្វទ្រង់ព្យាករដោយព្រះអង្គឯងថា ការបានឃើញមហាសុបិនទី ២ យ៉ាងនេះ ជានិមិត្តនៃការបានត្រាស់ដឹងនូវ

មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រកាសផ្សាយដល់មនុស្ស និងទេវតាទាំងឡាយ ។

**មហាសុបិនទី ៣** មានពួកសត្វដង្កូវខ្លួនពណ៌ស ក្បាលខ្មៅ វារចេញពីព្រះបាទទាំងគូ ចោមរោមជិតដរាប ដល់មណ្ឌលនៃជង្គង់ ។ ព្រះពោធិសត្វទ្រង់ព្យាករដោយខ្លួនឯងថា ការបានឃើញមហាសុបិនទី ៣ យ៉ាងនេះ ជានិមិត្តថា ពួកគ្រហស្ថជាច្រើន ស្លៀកពាក់ពណ៌ស ដល់នូវតថាគតជាសមណៈស្មើដោយជីវិត ។

**មហាសុបិនទី ៤** សត្វបក្សាបក្សី ៤ ពួកមានសម្បុរផ្សេងគ្នា ហើរមកអំពីទិសទាំង ៤ ក្រាបទៀបបាទមូលមានខ្លួនត្រឡប់ជាពណ៌សទាំងអស់ ។ព្រះពោធិសត្វទ្រង់ព្យាករដោយខ្លួនឯងថា ការបានឃើញមហាសុបិនទី ៤ យ៉ាងនេះ ជានិមិត្តនៃវណ្ណៈទាំង ៤ គឺ ខត្តិយៈ ១ ព្រាហ្មណ៍ ១ វេស្ស ១ សូទ្រៈ ១ ចេញចាកផ្ទះមកបួសក្នុងធម្មវិន័យ ដែលតថាគតសម្តែង ហើយបានធ្វើឱ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ ។

**មហាសុបិនទី ៥** ព្រះអង្គទ្រង់ចង្ក្រមលើភ្នំលាមកដ៏ធំមិនប្រឡាក់ដោយលាមកឡើយ ។ ព្រះពោធិសត្វ

ទ្រង់ព្យាករដោយខ្លួនឯងថា ការបានឃើញមហាសុបិនទី ៥ យ៉ាងនេះ ជានិមិត្តថា ព្រះតថាគតជាមនុស្សមានលាភ គឺ ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈច្រើន តែព្រះតថាគត មិនបានជាប់ជំពាក់ មិនបានជ្រប់ងប់ក្នុងលាភសក្ការៈនោះ ឡើយ ជាបុគ្គលឃើញនូវលាភនោះថាជាទោស មានបញ្ញាជា គ្រឿងរលាស់ខ្លួន ចេញហើយទើបបរិភោគ ។

ព្រះសម្មាសម្ពុទ្ធមិនត្រឹមតែព្យាករនូវមហាសុបិន ១៦ ប្រការនេះទេ ព្រះអង្គបានព្យាករប្រស្នាព្រះឥន្ទ[១] និងទ្រង់ ព្យាកររឿងហេតុផ្សេងៗជាច្រើនទៀត ដូចជាមានការ ព្យាករណ៍ក្នុងកំណើតនៃបញ្ញា និង គតិ និង បុណ្យ[២] ។

ម្យ៉ាងទៀត កាលព្រះសម្មាសម្ពុទ្ធ **ទីបង្ករ**ទ្រង់ព្យាករ **សុមេធតាបស** ថានៅ ៤ អសង្ខេយ្យកប្ប (ផែនដី)នឹងមួយ សែនកប្បទៀត ត្រូវបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធទ្រង់ ព្រះនាម **សមណគោតម** ក្នុងអាយុនៃមនុស្សលោកត្រឹម

---

១-សុត្តន្តបិដក ទីឃនិកាយ ចតុត្ថភាគ មហាវគ្គទំព័រ ២១៥។

២-សុត្តន្តបិដក ទីឃនិកាយ ចតុត្ថភាគ មហាវគ្គ ភាគ ១៧ទំព័រ៦១

១០០ ឆ្នាំ។ គ្រាន់តែបានឮពាក្យព្យាករណ៍ពីព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ សុមេធតាបស ត្រេកអរឥតឧបមា ហាក់បីដូចនៅជិតបង្កើយ រយៈពេល ៤ អសង្ខេយ្យ ១ សែនកប្បនេះ។ ព្រោះការសន្សំបញ្ញាមកយូរហើយ បានន័យថា គ្រាន់តែគិតទុកជាមុន ៧ អសង្ខេយ្យកប្ប ហើយចេញវាចា ៩ អសង្ខេយ្យកប្ប បានព្យាករណ៍ ៤ អសង្ខេយ្យកំរៃមួយសែនកប្ប ចំពោះបញ្ញាធិក ។ តាមពិតសុមេធតាបសនេះ បើកុំតែកសាងបារមីជាព្រះពុទ្ធ កុំអីត្រូវបានសម្រេចមគ្គផលក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ ទីបង្កររួចទៅហើយ ។ ចំពោះសទ្ធាធិក សរុបទាំងគិតទុកជាមុន និងចេញវាចា ព្រមទាំងបានព្យាករណ៍ ៤០ អសង្ខេយ្យ វិរិយាធិក ៨០ អសង្ខេយ្យ ។ គិតទៅការកសាងជាព្រះសម្មាសម្ពុទ្ធមួយអង្គៗ មានអាយុកាលនៃផែនដី(កប្ប) ច្រើនអសង្ខេយ្យណាស់ក្នុងការកសាងបារមី ជាការបញ្ជាក់ថា ការបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ជាការកម្រ ។ ប៉ុន្តែគ្រប់ៗព្រះពុទ្ធ ត្រូវតែបានទទួលការព្យាករណ៍ពីព្រះសម្មាសម្ពុទ្ធអង្គណាមួយ ទើបបានជា **និយតពោធិសត្វ** គឺព្រះពោធិសត្វទៀងតែពីបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ បើ

មិនទាន់បានព្យាករណ៍ ក៏នៅជា **អនិយតពោធិសត្វ** ។ សេចក្តីនេះគ្រាន់តែបង្ហាញឱ្យឃើញច្បាស់ទៅលើពាក្យព្យាករណ៍ របស់ព្រះសម្មាសម្ពុទ្ធថា ជាពាក្យពិត ឬទៀងប្រាកដ ។ ឯសម័យបច្ចុប្បន្ននេះ សត្វលោកកំពុងជឿទៅលើការទោះទាយរបស់ហោរាសាស្រ្ត ឬ ជំនឿផ្សេងៗក្រៅព្រះពុទ្ធសាសនាយ៉ាងច្រើន អ្នកណាគេសិក្សាពីអ្វី គេជឿទៅតាមអ្វីនោះទៅ តែទោះជាយ៉ាងណា ក៏នៅតែក្នុងការព្យាករណ៍នៃព្រះសម្មាសម្ពុទ្ធដដែល ព្រោះការទោះទាយទាំងនោះមានខ្លះពិត មានខ្លះទៀតមិនពិត

ការត្រាស់ដឹងរបស់ព្រះពុទ្ធដោយបញ្ញា ចំណែកសទ្ធាធិកវិញ ក៏ត្រាស់ដឹងដោយបញ្ញាដូចគ្នា គ្រាន់តែថា មានសទ្ធាជាអធិបតិ ឯវិរិយាធិក ក៏ដូច្នោះដែរ គ្រាន់តែមានវិរិយជាអធិបតិ ឯការត្រាស់ដឹងសច្ចធម៌ នៅតែបញ្ញាដដែល ។

ការសរុបបញ្ញាធិក កសាងបារមីរហ័សជាងសទ្ធាធិក និងវិរិយាធិក ។

មានសំណួរសួរថា ហេតុអ្វីក៏ព្រះសម្មាសម្ពុទ្ធសមណៈគោតម មិនឧប្បត្តិឡើងក្នុងលោកត្រាស់ដឹងនូវចតុរារិយសច្ចៈរវាងមនុស្សអាយុរាប់ម៉ឺនឆ្នាំដូចព្រះពុទ្ធមុនៗ ក្នុងភទ្ទកប្បតែ

មួយដូចគ្នា ចំណែកព្រះអរិយមេត្រីវិញ ឧប្បត្តិឡើងក្នុងលោកត្រាស់ដឹងធម៌ ក្នុងព្រះជន្មរវាងអាយុមនុស្ស៨ម៉ឺនឆ្នាំនៅខាងចុងបង្អស់ ។

ឆ្លើយថា = ព្រះសមណគោតមមិនឧប្បត្តិក្នុងលោករវាងមនុស្សអាយុ រាប់ម៉ឺនឆ្នាំដូចព្រះពុទ្ធមុនៗព្រោះៈ

១,ការសន្សំបារមីមិនទាន់គ្រប់គ្រាន់

២,ការបានព្យាករពីព្រះសម្ពុទ្ធទីបង្ករ

ដូច្នេះ ព្រះសម្មាសម្ពុទ្ធអង្គណាក៏ដោយ ក៏សុទ្ធតែបាន "ព្យាករណ៏ " នេះដូចគ្នា ដូចជាការព្យាករណ៏របស់សុបិន ១៦ ប្រការនេះរបស់ព្រះសមណៈគោតម ជាព្រះបរមគ្រូនៃយើង ដែលថាក្នុងសាសនារបស់ព្រះអង្គ នឹងកើតមានអកុសលធម៌ច្រើនដែលសុទ្ធតែអាក្រក់ទៅអនាគត គឺក្នុងរយៈពេលដ៏ខ្លីក្នុងភទ្ទកប្បនេះ គឺរវាងតែ **៥ ០០០ ឆ្នាំ** ប៉ុណ្ណោះ សូម្បីក្នុងកាលដ៏វែងរាប់អសង្ខេយ្យកប្ប ក៏ការព្យាករណ៏របស់ព្រះសម្មាសម្ពុទ្ធនៅតែជាពាក្យពិត ។ សូមកុំយកពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធអង្គណាមួយដែលទ្រង់បញ្ញត្តិហើយនូវសិក្ខាបទតូចធំ ឬជាធម្មទេសនាសំរាប់ប្រោសសត្វលោក

ឬក៏ពាក្យព្យាករណ៍មកនិយាយលេងធ្វើជាកំប្លុកកំប្លែង ព្រោះផ្តល់មកនូវទោសយ៉ាងច្រើនអនេកប្រការ យូរអង្វែងតទៅខាងមុខ ។

**នៅក្នុងខ្លឹមសារធម៌នេះ មានអារម្មណ៍ពីរយ៉ាង :**

I-អារម្មណ៍បញ្ញត្តិមាន :

១-ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករមហាសុបិន ១៦ ប្រការ

២-ព្រះបាទបសេនទិកោសល ទូលសួរព្រះសម្មាសម្ពុទ្ធ នូវមហាសុបិន ១៦ ប្រការ ។

៣-ព្រះនាងមល្លិកាជាអគ្គមហេសីនៃព្រះរាជាទ្រង់បានក្រាបទូលព្រះស្វាមី សូមស្តេចយាងទៅក្រាបទូលសួរព្រះសម្មាសម្ពុទ្ធវិញ កុំជឿតាមពាក្យទោះទាយរបស់ពួកព្រាហ្មណ៍បុរោ ហិតទាំងនោះ ។

៤-ពួកព្រាហ្មណ៍បុរោហិតជាអ្នកទោះទាយនូវមហាសុបិន ១៦ ប្រការប្រាសចាកពីការពិតដើម្បីលាភសក្ការៈ ។

ឯសាច់រឿង គឺមហាសុបិន ១៦ ប្រការ ។

ពាក្យថា ព្រះសម្មាសម្ពុទ្ធ ព្រះបាទបសេនទិកោសល ព្រះនាងមល្លិកា ព្រាហ្មណ៍បុរោហិត សាច់រឿងក្នុងមហាសុបិន ១៦ ប្រការ ទាំងអស់នេះត្រឹមតែជាការបញ្ញត្តិ គឺសម្មតិ-បញ្ញត្តិ ហៅថា អវិជ្ជមានេ អវិជ្ជមានបញ្ញត្តិ ។

**II- អារម្មណ៍បរមត្ថមាន :** ព្រះសម្មាសម្ពុទ្ធក្តី ព្រះបាទបសេនទិកោសលក្តី ព្រះនាងមល្លិកាក្តី ពួកព្រាហ្មណ៍ទាំងនោះក្តី ត្រឹមតែបញ្ចខន្ធ គឺ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណដូចគ្នា ឯការព្យាករណ៍របស់ព្រះសម្មាសម្ពុទ្ធ ពាក្យព្រះរាជាក្រាបទូលសួរដល់ព្រះសមណគោតម ពាក្យនិយាយឆ្លងឆ្លើយជាមួយព្រះនាងមល្លិកា និងព្រះរាជា ព្រមទាំងការទោះទាយរបស់ពួកព្រាហ្មណ៍ ត្រឹមតែវាចាគឺវចីវិញ្ញត្តិ ដែលមានចិត្តជាសមុដ្ឋាន។ ចំណែកសាច់រឿងក្នុងមហាសុបិននេះត្រឹមតែជាធម្មារម្មណ៍ គឺសុបិនមនោទ្វារវិថី ។ ការព្យាករណ៍របស់ព្រះសម្មាសម្ពុទ្ធ ជាកាមាវចរកុសល ប៉ុន្តែព្រះអង្គពុំមានផលវិបាកអ្វីតទៅទៀតទេ គឺមានត្រឹមតែមហាកិរិយាប៉ុណ្ណោះ ប្រៀបដូចផ្កាឈើពុំមានផ្លែដូច្នោះ ។ ពាក្យព្រាហ្មណ៍និយាយ

កុហកខុសពីការពិតថ្វាយព្រះរាជា គឺអកុសលធម៌ ( អកុសលា-ធម្មា ) ។

# សតិប្បដ្ឋានវិបស្សនា

ដូច្នោះ នៅក្នុងសាច់រឿងនៃមហាសុបិននេះ គ្មានអ្វីក្រៅពីបរមត្ថធម៌ គឺ ចិត្ត ចេតសិក រូប ពុំមានអ្វីនាំឱ្យយើងជាប់ជំពាក់ឡើយ ព្រោះជាកិច្ចរបស់មនោទ្វារវិថី មានអារម្មណ៍ជាបរមត្ថកើតឡើង ហើយរលត់ទៅវិញតាមហេតុបច្ច័យ គ្មានតួខ្លួន សត្វ បុគ្គល អ្នកធ្វើអ្វីឡើយ ។ ប៉ុន្តែដោយយើងខ្វះការសិក្សាពីបរមត្ថធម៌ គឺការអប់រំបញ្ញាឱ្យបានជ្រាបយល់សេចក្តីពិត ម្លោះហើយ ការសង្កេតពិនិត្យរាល់ថ្ងៃឃើញថាមានសត្វ បុគ្គល តាមពិតត្រឹមតែបញ្ចក្ខន្ធ និងរូប សម្លេង ក្លិនរស ផោដ្ឋព្វៈ ធម្មារម្មណ៍ ជាបរមត្ថប៉ុណ្ណោះ ។ ការឃើញនេះជាឃនសញ្ញា គឺការប្រជុំរួមនៃសភាវធម៌ ដែលកើតឡើងត្រឹមតែជាបរមត្ថធម៌មួយលក្ខណៈៗពិត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងទុក ។ ជម្រៅរបស់អត្ថ មានអវិជ្ជា

គ្របសង្កត់ ធ្វើឱ្យយើងភ័ន្តច្រឡំ បានន័យថា វាជាប្រធាននៃអកុសលធម៌ នាំឱ្យមានកិលេសតណ្ហា គឺបបញ្ចធម៌នេះឯងស្រោបបំបាំង ឱ្យឃើញត្រឹមតែបញ្ញត្តិ មិនឱ្យបុថុជ្ជនអ្នកគ្មានបញ្ញាចក្ខុ គឺ បញ្ញាលោកុត្តរជាបញ្ញាមិននៅក្នុងលោកមើលឃើញភាពជា បរមត្ថធម៌ គឺអារម្មណ៍ព្រះនិព្វាន ។

ផ្លូវនេះហើយ ធម៌នេះហើយ ដែលព្រះអរិយបុគ្គលទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើមធ្វើដំណើរទៅបានតែម្នាក់ឯង គឺត្រើយនៃកិលេស ឬទីបំផុតនៃកុសលធម៌ ដែលមានការអប់រំសន្សំបារមី រាប់អសង្ខេយ្យកប្បទំរាំបានសំរេចមគ្គផល គឺអរហត្តផល មានសតិប្បដ្ឋាន ៤ នេះឯង ។

ដូច្នេះនៅក្នុងលោកនេះ ដែលយើងដឹងរបស់អ្វីៗជុំវិញខ្លួនតាមអាយតនះទាំង ១២ ក្នុងទ្វារ ៦ ត្រឹមតែជា ខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ៍ សច្ចៈ និង បដិច្ចសមុប្បាទធម៌ ។ នេះជាការសម្តែងពីបរមត្ថធម៌ ប៉ុន្តែបើនិយាយពី បញ្ញត្តិវិញប្រាកដណាស់ថា ជាសត្វ បុគ្គល តួខ្លួន របស់នេះ របស់នោះ វត្ថុនេះ វត្ថុនោះ ដឹងបានតាមចក្ខុទ្វារវិថី សោតទ្វារវិថី ឃានទ្វារវិថី ជិវ្ហាទ្វារវិថី និងមនោទ្វារវិថី ព្រោះជាការឃើញ

នូវការកើតបន្តមិនដាច់ចេញពីគ្នា(ឃនសញ្ញា) នៃបរមត្ថធម៌ដែលកើតរលត់មួយលក្ខណៈៗ កម្រនឹងមានអ្នកណាដឹងបានលុះត្រាតែការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ទើបអាចសម្តែងទុកឱ្យយើងយល់បាន សិក្សារហូតសព្វថ្ងៃ ។

ការអប់រំចំរើនបញ្ញាតាមរបៀបនេះ នាំឱ្យរំលត់កិលេសបន្តិចម្តងៗជាតទង្គប្បហាន ឈ្មោះថាជាការកាត់បន្ថយនូវពេលវេលាឱ្យខ្លីនៅក្នុងសង្សារវដ្ត បានន័យថាយើងកំពុងរស់នៅសព្វថ្ងៃ **ពេលវេលាវាត្រូវបាក់ស៊ីយើងរាល់ថ្ងៃ បើដូច្នេះគួរយើងភ្ញាក់រលឹកគ្រប់គ្នាកុំដេកសម្ងំក្នុងលោភៈទោសៈមោហៈ យូរពេកត្រូវទំពារស៊ីពេលវេលាវិញ ដោយបំបាត់នូវអកុសលធម៌ គឺកិលេសមារមកជា ការកសាងបញ្ញា មានអលោភៈអទោសៈ អមោហៈ** ជាដើមវិញ ដើម្បីសន្សំបារមីឆ្លងអន្លង់ ៤ ជាទុក្ខវដ្ត គឺ **វដ្តគា មិនី** ឱ្យទៅ ជា **វិវដ្តគាមិនី** វិញ ។ នេះជាការប្រតិបត្តិបូជាចំពោះ ព្រះពុទ្ធសាសនា ប៉ុន្តែបើមិនប្រតិបត្តិយ៉ាងដូច្នេះ ឈ្មោះថា មិនដើរតាមផ្លូវមូលតែមួយគឺសតិប្បដ្ឋាន ៤ ឥទ្ធិបាទ ៤ សមប្បធាន ៤ ពលៈ ៥ ឥន្ទ្រិយ៍ ៥ ពោជ្ឈង្គ ៧

អរិយមគ្គប្រកបដោយអង្គ ៨ ជាធម៌ត្រាស់ដឹងមាន ៣៧ គឺឈ្មោះ **ពោធិបក្ខិយធម៌** របស់ព្រះពុទ្ធអង្គឡើយ ។

ពាក្យបញ្ញត្តិ គឺជាការប្រកាន់របស់អ្វីៗថាជារបស់ខ្លួនប្រកាន់បញ្ចក្ខន្ធ(ឧបាទានក្ខន្ធ) នេះឯង តែខណៈណាមានសតិបានដឹងថា បញ្ចក្ខន្ធ មិនមែនរបស់ខ្លួន ពេលនោះគឺជាការកើតឡើងនៃបញ្ញា ឯបញ្ញាបានមកពីការអប់រំចំរើន ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា :

**សុត្តាមយបញ្ញា**=បញ្ញាកើតពីការស្តាប់

**ចិន្តាមយបញ្ញា**=បញ្ញាកើតពីការត្រិះរិះ

**ភាវនាមយបញ្ញា**=បញ្ញាកើតពីការអប់រំចំរើន គឺធ្វើឱ្យច្រើនព្រោះមានការស្តាប់និងត្រិះរិះពិចារណារួចមកហើយ ។

ការវង្វេងស្មារតី (ពុំមានសតិ) មិនអាចអប់រំចំរើនបញ្ញាបានឡើយ ព្រោះបញ្ញាចេតសិកនេះ កើតនៅក្នុងសោភណចេតសិក ទីណាមានកុសលធម៌ ទីនោះជាការសន្សំបញ្ញា បញ្ញាកើតតាំងពីកុសលថ្នាក់ទាន (មានអារម្មណ៍បញ្ញត្តិ + បរមត្ថ) ហៅថាបញ្ញាកើតពីកុសលថ្នាក់ទាន បញ្ញា

កើតតាំងពីកុសលថ្នាក់សីល (មានអារម្មណ៍បញ្ញត្តិ +បរមត្ថ) ហៅថា បញ្ញាកើតពីកុសលថ្នាក់សីល បញ្ញាកើតតាំងពីកុសលថ្នាក់សមាធិ ឬពីសមថៈ (មានអារម្មណ៍បញ្ញត្តិ + បរមត្ថ) ហៅថា បញ្ញាកើតពីកុសលថ្នាក់សមាធិ ឬសមថៈ បញ្ញាកើតពីការអប់រំចំរើនសតិប្បដ្ឋាន មានអារម្មណ៍បរមត្ថតែម៉្យាង ហៅថាបញ្ញាថ្នាក់ សតិប្បដ្ឋាន គឺបញ្ញាដ៏កំពូលផុតលោក ដែលព្រះអរិយបុគ្គលទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម លោកអប់រំបញ្ញាចុងក្រោយនេះហៅថា បញ្ញាថ្នាក់វិបស្សនា ។

ក្នុងការអប់រំបញ្ញាថ្នាក់វិបស្សនា(ត្រូវមានសតិ) រលឹកត្រង់នូវសភាវៈកំពុងប្រាកដ ទោះបីពេលកំពុងធ្វើអ្វីក៏ដោយ កុំបណ្តោយចិត្តត្រេកត្រអាលចំពោះកាមគុណទាំងឡាយ មានបញ្ញត្តិជាអារម្មណ៍ តាមពាក្យគេនិយាយពោលពីអ្វីផ្សេងៗ ត្រូវមានយោនិសោមនសិការៈ ឆ្លាតឈ្លាសទាញយកអារម្មណ៍នោះឱ្យទៅជាបរមត្ថ[១] ដូចដែលខ្ញុំបានអធិប្បាយរួចមកហើយពីមុនមក ព្រោះទីណាក៏ដោយ សុទ្ធតែមានអារម្មណ៍បញ្ញត្តិ

---

១-បើកបញ្ញត្តិ ដោយបញ្ញា ទើបឃើញបរមត្ថ

ទាំងអស់ ឯអារម្មណ៍បរមត្ថ វាកប់ទុកក្នុងបញ្ញត្តិប្រកបដោយអាថិកំបាំង កម្រឱ្យយើងដឹងបាន ។ ដូចសំឡេងពោលឡើងឮធម្មទេសនា ជាដើម តាមវោហារទេសនា ឬពាក្យពោលដើម្បីឱ្យស្ដាប់គ្នាបាន ដូចមានបុគ្គលនេះ ឬដូចក្នុងរឿងសុបិន ១៦ ប្រការនេះជាដើម គ្រាន់តែបញ្ជាក់សាច់រឿងឱ្យដឹងសេចក្ដីស្ដាប់គ្នាបានប៉ុណ្ណោះ ឯការរលឹកដឹងនូវរូបធម៌នាមធម៌ សំរាប់កិច្ចរបស់សតិនិងបញ្ញា ។ ត្រង់កន្លែងនេះហើយ ដែលព្រះ-សម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងឡើង ព្រះអង្គទ្រង់មានព្រះបរិវិតក្កៈថា ធម៌ដែលតថាគតត្រាស់ដឹងនេះ សត្វលោកមិនអាចងាយ ១ យល់បានទេ បើដូច្នោះ តើតថាគតគួរសម្ដែងឬមិនសម្ដែង បើសត្វលោកកំពុងត្រេកត្រអាលនៅក្នុងតណ្ហាយ៉ាងនេះ គឺកំពុងហែលបណ្ដោយនៅក្នុងសង្សារទុក្ខហៅថា អនុសោតគាមី ចំណែកធម៌ត្រាស់ដឹងរបស់ព្រះអង្គ ជាការផ្ទុយបញ្ច្រាស់ពីលោក ហៅថា សោតគាមី ។ គ្រាន់តែព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះបរិវិតក្កៈយ៉ាងរូច្នេះ មហាព្រហ្ម បានចុះចាកពីព្រហ្ម-លោក មកអារាធនា[១] ព្រះអង្គឱ្យទ្រង់សម្ដែងធម៌ឡើងវិញ

(១) -ជាទំនៀមរបស់ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ

បើមិនដូច្នោះ សត្វលោកមុខជាលិចលង់អស់ហើយ ព្រោះ សត្វលោកខ្លះមានធូលីក្រាស់ គឺកិលេសក្រាស់ សត្វលោកខ្លះ មានធូលីតិច គឺរាគៈតិច ដោយហេតុនេះបានជាពេលមាន ធម្មកថិកសម្តែងធម៌ម្តងៗ ក៏ធ្វើតាមលំនាំសូត្របទមហាព្រហ្ម គឺថាពាក្យសូត្រអារាធនា ដូចព្រហ្មមុននឹងសម្តែងធម៌ បើមិន មានអារាធនាព្រហ្មទេ មិនអាចសម្តែងធម៌បានដែរ គ្រាន់ តែថា ព្រះធម៌មិនមានតម្លៃ ដែលជាហេតុធ្វើឱ្យព្រះធម៌ចុះ អាប់ឱន ។ បើព្រះធម៌មានតម្លៃកម្រយ៉ាងនេះ ក៏គួរយើង កុំប្រហែសធ្វេសធ្វើឱ្យថោក កុំយកព្រះធម៌មានតម្លៃទៅដូរ យកបច្ច័យ ៤ ដូចមានក្នុងមហាសុបិនទី ១១ នេះស្រាប់។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ សុទ្ធតែបង្ហាញប្រាប់ផ្លូវដល់ សត្វ ឱ្យបានសំរេចប្រយោជន៍ មិនសម្តែងធម៌នាំឱ្យសត្វជាប់ នៅក្នុងវដ្តៈ ដូចយ៉ាងទ្រង់សម្តែងពីអនុបុព្វិកថាជាដើម ។ ការសម្តែងធម៌របស់ព្រះអង្គមាន ៣ យ៉ាងដូចតទៅ :

**១-ទ្រង់ត្រាស់សម្តែងនូវពាក្យប្រៀនប្រដៅ ឱ្យអ្នកស្តាប់វែងវិតតែឃើញដឹងពិត ក្នុងរបស់ដែល មិនធ្លាប់ដឹង មិនធ្លាប់ឃើញ ធ្វើឱ្យដឹងឱ្យឃើញ ។**

**២-ទ្រង់សម្តែងធម៌ មានហេតុដែលអ្នកស្តាប់អាចត្រងឬយល់បាន ។**

**៣-ទ្រង់សម្តែងធម៌ជាអស្ចារ្យ គឺអ្នកបដិបត្តិតាម និង បានទទួលប្រយោជន៍តាមសមគួរដល់ការប្រព្រឹត្តបដិបត្តិ ។**

ព្រោះព្រះអង្គប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងព្រះធម៌ប្រោសសត្វណា ទ្រង់ត្រួតត្រាពិនិត្យមើលឧបនិស្ស័យសព្វគ្រប់របស់ពួកសត្វ ដោយព្រះប្រាជ្ញាញាណ ផលបានមកពីការស្តាប់ក្នុងសំណាក់ព្រះអង្គនឹងមិនមានបញ្ហាថា អ្នកស្តាប់នឹងមិនយល់ ឯផលដែលស្តាប់នោះទទួលយកទុកក្នុងចិត្តបាន ។

ការស្តាប់ព្រះធម៌នាំឱ្យមានការចំរើនស្មារតី ដែលមិនមានអ្វីមកប្រៀបប្រដូច ដូចក្នុងវោហារទេសនារបស់ព្រះសម្មាសម្ពុទ្ធ របស់ព្រះភិក្ខុសង្ឃអង្គណាមួយ ឬបុគ្គលណាក៏ដោយ ឱ្យតែយកធម៌នូវពាក្យប្រៀនប្រដៅរបស់ព្រះតថាគតពិតៗ សុទ្ធតែជម្រែទៅរកអមតធម៌ទាំងអស់ គ្រាន់តែថាវានៅលើឧបនិស្ស័យអ្នកស្តាប់ប៉ុណ្ណោះ ។ បើកាស្តោប់បានល្អ

គឺមានយោនិសោមនសិការៈ អាចសន្សំនូវមហាកុសលបន្តិចម្តងៗ ជ្រួតជ្រាបសព្វគ្រប់នូវខ្លឹមសារទាំងឡាយពីអ្នកសម្តែងនោះ នឹងបានផលល្អជាក់ជាមិនខាន ។ នេះជាការប្រតិបត្តិធម៌ក្នុងការស្តាប់ព្រោះការស្តាប់ធម៌ល្អ ⇒ មានសទ្ធា សទ្ធា⇒មានយោនិសោមនសិការៈ យោនិសោមនសិការៈ⇒មានសតិសម្បជញ្ញៈ សតិសម្បជញ្ញៈ⇒មានការសង្រួម ការសង្រួម⇒មានសុចរិត ៣ សុចរិត ៣ ⇒ មានសតិប្បដ្ឋាន ៤ សតិប្បដ្ឋាន ៤ ⇒មានពោជ្ឈង្គធម៌ ៧ ពោជ្ឈង្គធម៌ ៧⇒មានវិជ្ជានិងវិមុត្តិ គឺការរួចផុត កិលេសជាបរិយោសាន្ត ។ ដូចជាក្នុងសម័យព្រះសម្មាសម្ពុទ្ធគង់ធម្មា ពេលព្រះអង្គទ្រង់សម្តែងធម៌ម្តងៗ អ្នកស្តាប់ទាំងឡាយមានមនុស្ស និង ទេវតា សំរេចមគ្គផលយ៉ាងច្រើន ទៅតាមឧបនិស្ស័យរៀងៗខ្លួន ។ តើអ្នកស្តាប់នោះ គេបានសំរេចមគ្គផលព្រោះ ហេតុមកពីអ្វី ?

ឆ្លើយថា មកពី "**បញ្ញា**" ព្រោះការបានសំរេចមគ្គផលដោយបញ្ញាញាណ មិនមែនមកអំពីអ្វីក្រៅពីធ្វើអ្វីទេ ។ ឯបញ្ញា លុះណាតែមានការអប់រំចំរើនសតិប្បដ្ឋានវិបស្សនា

ដែលរលឹកនឹកឃើញនូវរូបធម៌ និងនាមធម៌មួយលក្ខណៈៗ រឿយៗ កើតគ្រប់ពេលតាមទ្វារទាំង ៦ ណាមួយ មានចក្ខុទ្វារជាដើមក្នុងជីវិតប្រចាំថ្ងៃ ។ ព្រោះរូបធម៌នាមធម៌ ជាសភាវៈធម៌ កើតរលត់ប្រក្រតិ គឺភវង្គចិត្តកើតរលត់ផ្លាស់ប្តូរនឹងវិថីចិត្ត កើតឡើងដឹងអារម្មណ៍តាមទ្វារផ្សេងៗ។ សភាវរូប ១ លក្ខណៈកើតរលត់ស្មើនឹងចិត្តកើត រលត់ ១៧ វិថីខណៈ ដូច្នេះចិត្តដែលកើតរលត់បន្តគ្នាយ៉ាងនេះគ្រប់ ១៧ ខណៈវិថីនេះមានចិត្តដល់ទៅ ៨៩ ដួង ឬ ១២១ដួង (ដោយពិស្តារ)។ បើគិតជាខណៈតូចថែមទៀតត្រូវជា ៥១ ខណៈចិត្តតាមបញ្ចទ្វារវិថី និងមនោទ្វារវិថី គឺ ឧប្បាទៈ ឋិតិ ភង្គៈ។ ក្នុង ២៤ ម៉ោង នាមធម៌កើតរលត់ ៦,៤០០,០០៩,៩៩៨ ខណៈចិត្ត។ ប៉ុន្តែបើតាមមនោវិថី មានត្រឹមតែ ១០ ខណៈចិត្តវិថីគ្រាន់តែវាច្រើនវារៈ គឺ ៤ វារៈចិត្តទើបអាចដឹង អារម្មណ៍បញ្ញត្តិថា រឿងរ៉ាវអ្វីបាន ដូចក្នុងមហាសុបិន ១៦ ប្រការនេះស្រាប់ ដែលមានសាច់រឿងទាំងអស់នេះ គឺជាកិច្ចមនោទ្វារវិថីចិត្តប៉ុណ្ណោះ ។ តាមការរំពៃកញ្ញែកឱ្យបានល្អិតទៅពុំមានសត្វ បុគ្គល តួខ្លួន ឬអ្នកធ្វើកម្មណាមួយទេ ត្រឹមតែ

ជាកិច្ចរបស់វិថីចិត្តប៉ុណ្ណោះ នេះតួបញ្ញាបានជាឧបការៈ ក្នុងការសន្សំបារមីធម៌ សំរាប់ការត្រាស់ដឹងកើតមកពីការសម្ដែងរបស់ព្រះសម្មាសម្ពុទ្ធ ឯបុថុជ្ជនមិនអាចមានអ្នកណាទៅដឹងដូច្នេះឡើយ ។

ការអប់រំបញ្ញាហៅថា វិបស្សនានោះ នាំឱ្យចំរើនកាន់តែដឹងច្បាស់ឡើងៗ នូវ អនិច្ចំ ទុក្ខំ អនត្តា ដែលជាលក្ខណៈរបស់សភាវធម៌ គឺបំបាត់នូវការមិនដឹងក្នុងសង្ខារទាំងឡាយថាជារបស់យើង ដែលតែងតែជាប់ប្រកាន់ស្អិតតាំងពីយូរយាណាស់មកហើយ មិនដឹងនូវរូបធម៌នាមធម៌តាមសេចក្ដីពិត ជាសភាវៈកើតឡើងពីហេតុបច្ច័យ ពុំមានតួខ្លួននៅក្នុងខន្ធទាំងឡាយ ។ **ការដឹងត្រឹមបញ្ញត្តិ មិនឃើញតំណនៃសង្ខារក្ខន្ធ ជាខន្ធបវត្តិនោះ តែងតែបិទបាំងនូវ អនិច្ចលក្ខណៈ មិនឱ្យឃើញការពិត នូវសភាវធម៌ក្នុងជីវិតប្រចាំថ្ងៃ ថាមិនទៀង ហើយការប្រព្រឹត្តិឥរិយាបថ៤ ក៏ជាការបិទបាំងនូវទុក្ខលក្ខណៈ ឯឃនៈសញ្ញា បិទបាំងនូវ អនត្តាធម៌ ។**

អារម្មណ៍តាមទ្វារ ៥ ដឹងបានដោយបញ្ចវិញ្ញាណ គឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ដែលឈ្មោះមនោធាតុដឹងអារម្មណ៍បរមត្ថសុទ្ធ។ ឯមនោទ្វារវិថីដឹងរឿងរ៉ាវអ្វីផ្សេងៗ ត្រឹមតែបញ្ញត្តិនិងបរមត្ថក៏មាន ដែលខណ្ឌជាចន្លោះៗ មួយលក្ខណៈៗ បន្តពីបញ្ចទ្វារម្លោះហើយ បញ្ចទ្វារដឹងអារមណ៍បរមត្ថតែម្យ៉ាង គ្រាន់តែថាពេលអារម្មណ៍មួយកើតឡើង អារម្មណ៍នោះលឿន រហ័សចូលដល់មនោទ្វារបាត់ មិនអាចអ្នកណាទៅញែកចែកអារម្មណ៍ ថានេះត្រឹមតែបញ្ចទ្វារ ឬថានោះត្រឹមតែជាមនោទ្វារ ។ មានតែព្រះសម្មាសម្ពុទ្ធត្រាស់ដឹង អាចចែកយ៉ាងដូច្នេះបាន ។

គ្រាន់តែថា ពេលណាយើងរលឹកដឹងត្រឹមតែ រូប សំលេង ខ្លិន រស ផោដ្ឋព្វៈនោះ យើងក៏មិនអាចរលឹកដឹងថាអារម្មណ៍ក្នុងមនោទ្វារនៅទីណាទេ ព្រោះនេះត្រឹមតែបរមត្ថធម៌ ជាបច្ច័យមួយមិនអាចយើងដឹងដល់មនោទ្វារ ដែលហៅថាបញ្ចទ្វារ បិតបាំងមនោទ្វារ[១] ។ ខណៈណាយើងបានដឹង

---

(១) -សំណួរចំឡើយរបស់ម៉ែ សុ ជិន ជាមួយលោកគ្រូអគ្គបណ្ឌិត ពីថ្ងៃ ទី ៦ -១២-២០០០នៅវត្តសំពៅមាស លើកទី ២ ដែលអ្នកម៉ែ សុ ជិន អញ្ជើញមកប្រទេសកម្ពុជា

រឿងអ្វីណាមួយ រឿងនោះហៅថា បញ្ញត្តិ មានធម្មារម្មណ៍ជាដើម គឺ លែងបានដឹងថាត្រឹមតែរូប ត្រឹមតែសំលេង ត្រឹមតែក្លិន ត្រឹមតែរស ត្រឹមតែផោដ្ឋព្វៈ ព្រោះមនោទ្វារបិទបាំងបញ្ចទ្វារម្តងវិញ ។ ចំណែកសតិប្បដ្ឋាន អាចកើតឡើងរលឹកដឹងសភាវធម៌ តាមបញ្ចទ្វារក៏មាន ហើយអាចរលឹកដឹងនូវរូបធម៌ នាមធម៌បាន តាមមនោទ្វារមួយខណៈៗ ទៅតាមឧបនិស្សយប្បច្ច័យ បន្តពីបញ្ចទ្វារជាអារម្មណ៍បរមត្ថ ព្រោះក្នុងមនោទ្វារវិថី អារម្មណ៍ណាក៏ដោយ កើតតាមបញ្ចទ្វារលឿនរហ័ស មកដល់មនោទ្វារជាកិច្ចនៃជវន ស៊ីសោយ៧ខណៈរួចក៏មនោទ្វារវិថីកើតច្រើនវារៈ រហ័សនឹងឯងជាយនសញ្ញា ។ ប៉ុន្តែ បើសតិប្បាដ្ឋានមានកម្លាំងច្រើនខ្លាំងឡើង ៗ អាចរលឹកដឹងអារម្មណ៍បរមត្ថបាន ព្រោះមួយខណៈនៃរូបធម៌ នាមធម៌កើតរលត់ទៅវិញដែលអាចដឹងបាន មានតែបញ្ញាថ្នាក់វិបស្សនាទើបប្រត្យក្សលក្ខណៈសភាវធម៌នោះ ហើយបើមិនធ្លាប់បានអប់រំចំរើនសតិប្បដ្ឋានច្រើនជាតិ ច្រើនអសង្ខេយ្យកប្បទេ នៅតែមិនដឹង មិនយល់នូវការបដិបត្តិយ៉ាងដូច្នេះឡើយ ។ នេះជាការវាស់ស្ទង់ដឹងខ្លួនឯង ថាតើជីវិតប្រចាំថ្ងៃនេះ យើងបាន

សន្សំការចេះដឹងបានក៏រិតណា បើបានដឹង ហ្នឹងជាតួបញ្ញា តែបើមិនបានដឹង ឃើញថាមានសត្វបុគ្គលតួខ្លួន នេះមិនមែនជាបញ្ញា ។ ការឃើញអារម្មណ៍បរមត្ថ អាស្រ័យពីការសិក្សាបរមត្ថធម៌ច្រើនៗ នេះជាសុត្តាមយបញ្ញា ព្រោះប្រកបជាមួយនិងយោនិសោមនសិការៈ ដែលជាអាហាររបស់សតិប្បដ្ឋានរុញច្រានឡើងរហូតទៅដល់ពោជ្ឈង្គធម៌ ( ធម៌ដ៏មានកំលាំងសំរាប់ការត្រាស់ដឹងនូវអរិយសច្ចធម៌ ) ក៏កំលាំងនេះរុញបានមួយក៏រិតទៀតទៅដល់វិជ្ជា និងវិមុត្តិ គឺការរួចផុតចាកកិលេសដោយវិបស្សនាញាណទាំង ១៦ ព្រោះអង្គធម៌មាន ៥ គឺៈ

១-សីល

២- សុត្តៈ

៣-ធម្មសាកច្ឆា

៤- សមថៈ

៥ -បញ្ញា គឺតួវិបស្សនា

នេះជាការសរុបនៅក្នុងធម៌ ១០ ប្រការ ។ ការឃើញរូបផង ការឮផង ដំណាលគ្នា តាមពិតមិនមែនដូច្នោះទេ ចិត្តមួយដួង ឬ មួយខណៈកើតឡើងរលត់ទៅវិញ រួចកើត

ចិត្តមួយខណៈថ្មីទៀត ។ ប្រៀបដូចជាអណ្តាតភ្លើងទៀន ឬពន្លឺអគ្គិសនី ដែលឆេះឡើងនោះ គឺជាការបន្តគ្នាមិនឈប់នៃអណ្តាតភ្លើងនោះដែលឆេះឡើងមានប្រឆេះ មានទៀន ។ ឯអណ្តាតភ្លើងដែលឆេះបន្តគ្នាវារលត់ញាប់ពេក យើងមើលមិនដឹងដោយមំសំចក្ខុ ឯពន្លឺអគ្គិសនីក៏ដូចតែគ្នា ។ ឧទាហរណ៍មួយទៀត យើងកាន់ធូប ១ សរសៃមានភ្លើងឆេះ ហើយគ្រវីឱ្យញាប់ទៅមើលឃើញរង្វង់មូលនៃពន្លឺភ្លើង ប៉ុន្តែតាមពិតភ្លើងធូបវាកើតរលត់បន្តគ្នាយ៉ាងរហ័ស ហាក់ដូចជាមានរង្វង់ភ្លើងមូល យ៉ាងណាមិញ ខណៈចិត្តកើតរលត់ជាមួយរូបធម៌ក៏យ៉ាងដូច្នោះ ។

យោងទៅលើការពិចារណាឃើញថា អ្វី១ទាំងអស់សុទ្ធតែសភាវធម៌កើតឡើងពីហេតុបច្ច័យ រលត់ទៅវិញព្រោះអស់ហេតុបច្ច័យដែលអ្វី១នោះជាបរមត្ថធម៌ ព្រោះបរមត្ថធម៌កើតរលត់ទៅវិញធម្មតា ការឃើញដូច្នេះជាតួបញ្ញា ។ ឯបញ្ញាក៏ជាសភាវធម៌ ឬសង្ខារធម៌មួយបែបដែរ ព្រោះជាចេតសិកដូច្នោះបញ្ញាគ្មានខ្លួនទេ វាបានដឹងរួចហើយក៏រលត់ទៅវិញធម្មតា ឯសតិក៏ដូច្នោះដែរ។ ចំណែកបញ្ញត្តិវិញ ពុំមានការ

កើតរលត់ដូចបរមត្ថធម៌ ព្រោះឃើញថាទៀងថិតថេរនៅដដែល ។ អាស្រ័យហេតុនេះហើយ បានជាបុថុជ្ជនតែងប្រកាន់ខ្ជាប់នៅក្នុងសង្ខារធម៌ថា ជារបស់ខ្លួន នេះគឺសក្កាយទិដ្ឋិ ។ ព្រះអរិយបុគ្គលទាំងឡាយ លោកមិនឃើញដូច្នោះ ព្រោះលោកបានលះផ្តាច់សក្កាយទិដ្ឋិចេញ ប្រៀបដូចសត្វគោគេពន្លះស្បែកចេញ រួចយកស្បែកនោះ មកគ្របពីលើតួខ្លួនវា ប៉ុន្តែមិនជាប់គ្នាដូចមុនឡើយ ព្រះអរិយបុគ្គល លោកឃើញអ្វីៗទាំងអស់សុទ្ធតែលក្ខណៈនៃសភាវធម៌ មិនជាប់ជំពាក់នៅក្នុងខន្ធ អាយតនៈ ធាតុ សច្ចៈឡើយ ព្រោះ ខន្ធ អាយតនៈ ធាតុ ជាសង្ខារធម៌ ពុំមានតួខ្លួនដែលកើតឡើងហើយត្រូវតែរលត់ធម្មតា ពុំមានអ្នកណាចាប់ យកនូវរូបធម៌នាមធម៌នោះទុកបាន មានតែបុថុជ្ជនប៉ុណ្ណោះ ជាប់ដោយសក្កាយទិដ្ឋិ ប្រកាន់រូបធម៌នាមធម៌នោះថារបស់ខ្លួន ថាតួខ្លួនថាយើង ថាអញ(គឺអស្មិមានៈ) ជាបបញ្ចធម៌ ទោះបីរឿងសុបិន ១៦ ប្រការនេះមានពិតប្រាកដមែនហើយ តែអារម្មណ៍នេះ បើគិតតាមបរមត្ថធម៌ ពុំមានអ្វីទាល់ តែសោះ **ត្រឹមតែជាមនោទ្វារវិថី ជាអនិច្ចលក្ខណៈ ទុក្ខ**

**លក្ខណៈ អនត្តលក្ខណៈ ដែលពុំមានខ្លឹមសារអ្វីគួរឱ្យយើង រន្ធៀសតក់ស្លុត ញាប់ញ័រ គឺជាភាពសូន្យចាកអត្តា ព្រោះមិនមែនរបស់ខ្លួនត្រឹមតែជាអនត្តាធម៌ប៉ុណ្ណោះ ៕**

ពាក្យអនត្តាធមិ ជាធមិមិនប្រកាន់អ្វីៗថារបស់ខ្លួន ឯពាក្យអត្តាប្រកាន់អ្វីៗថារបស់ខ្លួន បានន័យថាគិតតែពីខ្លួនឯង ឯអ្នកដទៃពុំសូវគិតទេ ទោះបីអ្នកនោះរងទុក្ខទោសគ្រោះថ្នាក់អន្តរាយអ្វីៗក៏ដោយ ឱ្យតែខ្លួនអញបានស្រណុកសុខស្រួលមួយដងមួយគ្រា គឺធ្វើយ៉ាងណាខ្លួនរបស់អញបានទទួលនូវមុខមាត់កិត្តិយសខ្ពង់ខ្ពស់ ។ ចំណែកអនត្តាធមិព្រះសម្មាសម្ពុទ្ធ ទ្រង់ឱ្យគិតប្រយោជន៍អ្នកដទៃផង ទើបនាំមកនូវសេចក្តីសុខរួម ព្រោះថា បើអ្នកដទៃទទួលបានសេចក្តីសុខ យើងក៏បានសុខដែរ ។

ការងារគ្រប់សព្វបែបយ៉ាងក្នុងលោក ត្រូវពឹងពាក់អាស្រ័យពីបច្ច័យខាងក្រៅខ្លះនិងខាងក្នុងខ្លួនខ្លះ ទើបអាចនាំមកនូវភាពរីកចំរើន ត្រូវមានធមិសង្គ្រោះគ្នាទៅវិញទៅមក ត្រូវគិតប្រយោជន៍សាធារណៈជាធំ ព្រោះថាអ្នករស់នៅជុំវិញ

យើងគេកំពុងត្រេកអរ ចង់រស់នៅដោយសុខសន្តិភាព តែបើយើងទៅបៀតបៀនគេ បំផ្លាញគេ នាំឱ្យគេមានទុក្ខទោស ពៀរវេរានឹងផ្តល់ផលមិនចេះចប់ ។ ព្រះសម្មាសម្ពុទ្ធត្រាស់ដឹងឡើងក្នុងលោក សំរាប់ជួយស្រោចស្រង់សត្វឱ្យជៀសផុតពីទុក្ខ បានន័យថាព្រះអង្គគិតប្រយោជន៍សត្វជាធំ (១) ទោះបីព្រះអង្គនឿយលំបាកព្រះកាយពលយ៉ាងណាក៏ដោយ ឱ្យតែអ្នកនោះអាចត្រូវព្រះអង្គប្រោសបាន ព្រះអង្គស្តេចនឹងយ៉ាងទៅប្រោស មិនថាអ្នកនោះនៅជិតឬនៅឆ្ងាយយ៉ាងណា ដូចយ៉ាងក្នុងរឿងមហាសុបិន ១៦ ប្រការជាដើម ។

ដើម្បីចូលរួមបដិបត្តិធម៌តាមព្រះសម្មាសម្ពុទ្ធ គួរយើងធ្វើតាមព្រះអង្គ ដោយយកធម៌អនត្តាមកបំភ្លឺជាកញ្ចក់សំរាប់បំពេញកាតព្វកិច្ចជាមនុស្ស( អ្នកមានសីល ៥ )មកបដិបត្តិក្នុងជីវិតប្រចាំថ្ងៃ ពោលគឺត្រូវជួយប្រយោជន៍អ្នកដទៃឱ្យបាន

---

(១) -ព្រះសម្មាសម្ពុទ្ធមានចរិយា ៣ : -

១-ពុទ្ធត្ថចរិយា =គិតប្រយោជន៍ខ្លួនឯង

២-ញាតត្ថចរិយា=គិតប្រយោជន៍ញាតិ

៣-លោកត្ថចរិយា=គិត ប្រយោជន៍សត្វលោកទាំងមូល

ច្រើនៗ មានការធ្វើទាន រក្សាសីល ប្រព្រឹត្តព្រហ្មចរិយធម៌ បំពេញមហាកុសលនាំទៅរកទីបំផុតទុក្ខ ។ ការរកទទួលទាន ចិញ្ចឹមជីវិត ជារឿងធម្មតារបស់មនុស្សយើង ប៉ុន្តែគ្រាន់តែថា កុំជ្រប់ងប់តែនឹងទ្រព្យសម្បត្តិនោះពេក ព្រោះទ្រព្យសម្បត្តិ នេះ( បច្ច័យ ៤ )អាចនាំយើងធ្លាក់ទៅក្នុងអបាយភូមិបាន បើ មិនចេះប្រើប្រាស់វា ។ ដូច្នោះបច្ច័យ ៤ ទាំងឡាយគួរចេះចែក រំលែកប្រើប្រាស់ឱ្យទៅជាកំណប់ទ្រព្យ សំរាប់ប្រយោជន៍គ្រប់ ពេល មានការចិញ្ចឹមបុត្រ ភរិយា មាតាបិតា ញាតិមិត្ត ឬ សមណព្រាហ្មណ៍ នេះជាមហាកុសលដ៏ខ្លាំងក្លាខ្ពស់បំផុត អាច រួចផុតចាកទុក្ខបាន ព្រោះមហាកុសលមិនងាយកើតមានដល់ សន្តានចិត្តរបស់សត្វទាំងឡាយក្នុងសម័យសព្វថ្ងៃនេះ ។

ឃើញទេនៅក្នុងសាកលលោក ប្រទេសធំៗដែលមាន ទ្រព្យសម្បត្តិច្រើន គេខំចំណាយរបស់ទាំងនោះ ជួយដល់ ប្រទេសក្រីក្រមួយចំនួន ។ នេះជាអនត្តាធម៌ ដែលជាកត្តា ដើម្បីរាំងទប់ស្កាត់កុំឱ្យអត្តា ( មានខ្លួន) ជ្រៀតចូលតាមទ្វារ ៦ ណាមួយ មកដល់ពួកកិលេស តណ្ហា មេអកុសល អវិជ្ជា

កំពុងចំរើន ដែលមាននៅក្នុងមហាសុបិន ១៦ ប្រការនេះ តាមពាក្យ ព្យាករពីព្រះសម្មាសម្ពុទ្ធ ។

ការជ្រប់ងប់នៅក្នុងទ្រព្យសម្បត្តិ មានលាភសក្ការៈច្រើនហួសហេតុពេក នាំឱ្យមានកត្តាអាក្រក់ច្រើន ដោយតណ្ហាវាទាញឱ្យចិត្ត ប្រព្រឹត្តិធ្វើអ្វីៗទៅរកតែប្រយោជន៍ខ្លួនឯង ដូចជាមហាសុបិនទី ៥ ដែលថាសត្វសេះមានមាត់ពីរ បានបរិភោគស្មៅនូវមាត់ពីរតែម្តង ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករទុកថា ទៅអនាគត មនុស្សធ្វើការងារអ្វីៗ លែងគិតពីការខុសត្រូវ គិតតែពីលាភសក្ការៈ និងសំណូកសូកប៉ាន់ ទោះបីខុសក៏ដោយ ក៏បំបែរមកថាជាត្រឹមត្រូវ ដូចពួកព្រាហ្មណ៍បុរោហិតទាយបង្វែរមហាសុបិន ១៦ ប្រការខុសពីការពិត ដើម្បីលាភសក្ការៈ ។

តណ្ហាមានមាត់មិនត្រឹមតែមួយទេ ក្នុងអរិយវិន័យបានសម្តែងថា មាន ៦ គឺតាមចក្ខុ តាមសោតៈ តាមឃានៈ តាមជិវ្ហា (អណ្តាត) តាមកាយ និងតាមមនោ (ចិត្ត) ហើយគ្មានថង់ឬក្រពះទៀត ដូច្នោះ ការទទួលអ្វីៗទាំងអស់មិនចេះគ្រប់គ្រាន់ឡើយ បាននេះថានៅខ្វះនោះទៀត ទោះបានច្រើន

យ៉ាងណាក៏ដោយក៏នៅតែមិនស្កប់ចិត្ត (តណ្ហា) ដែរ ដូចរឿងព្រះបាទមន្ធាតុ ជាដើម(បានរបស់អ្វីៗក្នុងលោកអស់ហើយក៏ចង់បានឋានតាវត្តិង្សព្រះឥន្ទទៀត) ព្រោះកាលនោះអាយុមនុស្សចំរើនឡើងដល់មួយអសង្ខេយ្យឆ្នាំ ។ គ្រាន់តែគិតពុំទាន់ចេញវាចាផង ស្រាប់តែធ្លាក់ខ្លួនមកដល់ប្រាសាទរបស់ព្រះអង្គ នាផែនដីយើងនេះវិញ គឺព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូនៃយើង កាលព្រះអង្គកំពុងត្រាច់រង្គត់ក្នុងវាលវដ្តសង្សារ ។

មួយទៀតតណ្ហាវាបណ្តាលចិត្តឱ្យសាវក័របស់ព្រះមានព្រះភាគ មានភិក្ខុអលជ្ជីជាដើម យកព្រះធម៌របស់ព្រះអង្គទៅដូរយកបច្ច័យ ៤ ដោយបោះបង់ចោលព្រះធម៌ដ៏មានតម្លៃសំរាប់ដឹកនាំសត្វឱ្យឆ្លងផុតទុក្ខ ។ បច្ច័យទាំងឡាយ ៤ បើគិតតាមផ្លូវលោក គេត្រូវការណាស់ ព្រោះជារបស់ប្រើប្រាស់ដើម្បីសំរួលក្នុងជីវិតប្រចាំថ្ងៃ ដោយហេតុនេះគេខំឆ្នៃប្រឌិតទៅតាមបែបវិទ្យាសាស្ត្រទំនើបជឿនលឿន។ គេខំសិក្សាស្រាវជ្រាវរិះរកមធ្យោបាយយ៉ាងណា ដើម្បីបង្កើតសំភារៈផ្សេងៗយ៉ាងច្រើន ធ្វើឱ្យសត្វលោកត្រេកអរីករាយជាប់ជំពាក់នៅក្នុងរបស់ទាំងនោះ(កាមគុណ ៥ )ដែលព្រះសម្មាសម្ពុទ្ធទ្រង់មិន

សរសើរឡើយ ព្រោះជាគ្រឿងទាញសត្វមិនឱ្យរួចខ្លួនទៅដល់បរមសុខដែលមាននៅក្នុងមហាសុបិន ១១ នេះស្រាប់ ។ បច្ច័យ ៤ ទាំងឡាយតាមព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថាជាមារនិមិត្ត ជាអាមិស(គ្រឿងបោកបញ្ឆោត) គឺកិលេសមារនេះឯង ជារបស់គួរខ្លាច គួរតក់ស្លុត គួរខ្មាស់ ជារបស់ពុកផុយរលួយស្អុយ ឬប្រៀបបាននឹងដុំលាមកដែលបណ្ឌិតស្អប់ខ្ពើមយ៉ាងខ្លាំង ដោយតណ្ហាវាដឹកនាំចិត្តឱ្យសប្បាយនៅក្នុងភពតូចនិងភពធំមិនចេះចប់ ។ ការបានរបស់អ្វីៗ ទាំងអស់នេះ គឺលោកធម៌ ៨ មានលាភ មានយស សរសើរ សុខទាំងនេះជាដើម ត្រឹមតែជាការបាននូវរបស់ទទេតែប៉ុណ្ណោះ ។ តាមការពិតប្រាកដត្រូវបាននោះ គឺការចំរើនតណ្ហា មានៈលោភៈ ជាដើមទៅវិញ ឯរបស់ទាំងអស់វាមិនទៀង បន្តិចទៀតត្រូវវិនាសសាបសូន្យជាមិនខាន ។ ពុទ្ធបរិស័ទទាំងឡាយអ្នកខ្លះគិតតែខ្វល់ខ្វាយនឹងរកទ្រព្យសម្បត្តិច្រើនពេក ស្មានថានេះជាទីពឹងដ៏ប្រសើរ រហូតដល់ទៅហ៊ានរកទទួលទានមិនគោរពតាមពាក្យប្រៀនប្រដៅព្រះបិតាវិវដ្ដៈ ប្រព្រឹត្តិអំពើខុសឆ្គងផ្សេងៗ មានការមិនវៀរចាកមិច្ឆាជីវៈគឺ ជំនួញ ៥

ប្រការ មានការជួញដូរនូវជីវិតសត្វជាដើម ។ តាមព្រះបិតាយើង ការរកទទួលទានត្រូវតែស្វះស្វែង ប៉ុន្តែការប្រព្រឹត្តិធ្វើក៏ឱ្យត្រឹមត្រូវតាមធម៌ទើបនាំមកនូវសេចក្តីចំរើន បើមិនដូច្នោះគ្រោះកាច អាសន្ន ការបៀតបៀនគឺ សេចក្តីទុក្ខប្រាកដជានឹងមានដល់ខ្លួនយើងជាក់ជាមិនខាន ។ ការរស់នៅរបស់មនុស្សម្នាក់ៗ មិនថាជាអ្នកណាៗ ឬសត្វណាទេដែលកំពុងតែជួបនូវវិបាកឱ្យផលគ្រប់ពេល លើកលែងតែគ្មានវិថីចិត្ត គឺ ភវង្គបានដល់កុសលវិបាកក៏មាន អកុសលវិបាកក៏មាន ក៏ប៉ុន្តែយើងគួរកុំបណ្តោយទៅតាមយថាហេតុពេក ត្រូវរកមធ្យោបាយ គឺបញ្ញាមកជួយដោះស្រាយទើបបានក្សេមក្សាន្ត ។ **ការត្រឡប់កើតមកជាមនុស្ស ជាការក្រ** នេះជាការសម្តែងរបស់ព្រះសម្មាសម្ពុទ្ធ ដូច្នេះដើម្បីឆ្លើយតបនូវប្រការខាងលើនេះមនុស្សចាំបាច់ត្រូវមានគុណធម៌ ព្រោះមនុស្សមានច្រើនប្រភេទ :

**១~មនុស្សទេវតា**=មានអត្តភាពជាមនុស្សតែចិត្តជាទេវតា ត្រូវមានធម៌៥ គឺ សទ្ធា សីល សត្តៈ ចាគៈ បញ្ញា ។

**២-មនុស្សមនុស្សោ**=មានអត្តភាពជាមនុស្សតែចិត្ត ជាមនុស្ស ត្រូវមាន : សីល៥ ។

**៣-មនុស្សតិរច្ឆានោ**= មានអត្តភាពជាមនុស្សតែចិត្ត ជាតិរច្ឆាន ។

**៤-មនុស្សនេរយិកោ**= មានអត្តភាពជាមនុស្សតែ ចិត្តជានរក ។

**៥-មនុស្សសបេតោ**= មានអត្តភាពជាមនុស្សតែចិត្ត ជាប្រេត ។

ប្រភេទមនុស្សប្រាំពួកនេះមាននៅក្នុងលោកយើងសព្វថ្ងៃ ដោយហេតុនេះ អ្នកត្រូវរក្សាអត្តភាពជាមនុស្សឱ្យបាន បំណាច់ពីអតីតកម្មរៀបចំតាក់តែងឱ្យមកកើតក្នុងទីដ៏សមគួរ បានន័យថា កុំបំផ្លាញខ្លួនឯងឱ្យវិនាសទៅតាមមនុស្ស ៣ ពួក ដូចខាងលើឡើយ បើមិនបានជាមនុស្សទេវតា ប៉ុន្តែបើមាន សីលប្រាំជានិច្ចប្រាកដថានឹងបានជាមនុស្សទេវតា ទាំងនៅក្នុង បច្ចុប្បន្ន នឹងបរលោក ។

ម្យ៉ាងទៀតការរស់នៅប្រចាំថ្ងៃ គឺជាការរស់នៅរត់រក វិបាករបស់ខ្លួនដែលជាបច្ច័យនៃខ្សែវដ្ត : ម្តងជួបនឹងសេចក្តីសុខ

ម្តងជួបនឹងសេចក្តីទុក្ខ វិលចុះវិលឡើងមិនចេះចប់ តើយើងយល់ថាមកពីអ្នកណា ? ដូច្នេះ ត្រូវចេះសេពគប់រកសប្បុរស (អ្នកមានធម៌) កុំសេពគប់មនុស្សពាល ហើយអ្វីណាគួរបូជាសឹមបូជា នេះជាមង្គលដ៏ឧត្តម (មានក្នុងមង្គលសូត្រ ព្រះគាថាខាងដើមបង្អស់) ។ ក្នុងមហាសុបិនទី ១៦ រឿងយកថាសមាសរាប់សែនកហាបណៈទៅឱ្យឆ្កែចចកបន្ទោបង់បស្សាវៈ (ទឹកនោម) តាមន័យដែលព្រះសម្ពុទ្ធទ្រង់ព្យាករទុកសំរាប់ អនាគតថា ពួកអ្នកមានត្រកូលល្អៗ យកកូនក្រមុំ (ធិតា) ទៅឱ្យមានប្តីដល់ពួកត្រកូលថោកទាប (ពួកត្រកូលអធម៌) ។ ចំណុចនេះ សួរថាបានសុខស្រួលជាមួយគ្នាដែរឬទេ ? ព្រោះត្រកូលល្អ គឺត្រកូលអ្នកមានពូជពង្សល្អត្រឹមត្រូវ ជាអ្នកមានធម៌ស (កុសល) ។ បញ្ហានេះមិនសូវបានសុខស្រួលនឹងគ្នាប៉ុន្មានទេ ព្រោះធម៌ជាកុសល និងធម៌ជាអកុសល នៅឆ្ងាយពីគ្នាដាច់ស្រយាល មិនអាចនៅរួមជាមួយគ្នាកើតឡើយ ។ ហេតុភេទអាក្រក់នេះ មានមកយូរយារដែរហើយនៅក្នុងលោក ដែលព្រះសម្មាសម្ពុទ្ធមានសម្តែងនៅក្នុងសុត្តន្តបិតកសំយុត្តនិកាយ ភាគ ៤២ ទំព័រ ១៤៥ ។

ការនៅរួមរស់ជាមួយស្វាមីភរិយាមាន ៤ យ៉ាង :

១-ខ្មោចប្រុស រស់នៅជាមួយ ខ្មោចស្រី

២-ខ្មោចប្រុស រស់នៅជាមួយ ទេវតាស្រី

៣-ទេវតាប្រុស រស់នៅជាមួយ ខ្មោចស្រី

៤-ទេវតាប្រុស រស់នៅជាមួយ ទេវតាស្រី

ពាក្យថាទេវតា តំណាងឱ្យធមិស ឯខ្មោចតំណាងធមិខ្មៅ ។ មនុស្សយើងគ្មានអ្នកណាម្នាក់ចង់លំបាក សុទ្ធតែចង់សុខគ្រប់គ្នា ប៉ុន្តែអាស្រ័យហេតុប្បច្ច័យពីអតីតនិងបច្ចុប្បន្នដែលយើងត្រូវចេះសេពគប់ដូចបានពោលមកហើយ ក្នុងមង្គលសូត្រខាងដើមនោះ ។ អាស្រ័យភរិយា ៤ ប្រការនេះហើយទើបការឈ្លោះទាស់ទែងខ្វែងយោបល់គ្នា ភាពច្របូកច្របល់នឹងមាននៅក្នុងអនាគត ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករទុក ។ ភាពមិនល្អជាអកុសលធមិចំរើនយ៉ាងនេះក្តី មានត្រឹមតែបញ្ចក្ខន្ធ គឺ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ឯភាពល្អឬមិនល្អ ត្រឹមតែជាកុសលធមិ និងអកុសលធមិប៉ុណ្ណោះ គឺកិច្ចរបស់មនោទ្វារវិថីចិត្តដែលមាននៅក្នុងមហាសុបិន ១៦ ប្រការនេះ ពុំមានតួខ្លួន សត្វ បុគ្គល អ្នកធ្វើកម្មនិងទទួលផលមានតែបរមត្ថធមិ ៤ គឺ រូបបរមត្ថ ចិត្តបរមត្ថ ចេតសិកបរមត្ថ

និងនិញ្វានបរមត្ថ ។ តែក្នុងទីនេះ លើកយកតែបរមត្ថ ៣ គឺ រូបបរមត្ថ ចិត្តបរមត្ថ ចេតសិកបរមត្ថ ជាបញ្ចក្ខន្ធ មាន រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ កើតនិងរលត់ធម្មតា (ធម្មជាតិ) ពុំមានអ្នកណាអាចចាប់ឬឃាត់ទុកបាន ។ បើ សភាវធម៌មានប្រាកដយ៉ាងនេះ សួរថា យើងនៅជាប់ការ ប្រកាន់ទៅលើអ្វី ? សភាវធម៌ទាំងនេះ ជារបស់កើតពីហេតុ បច្ច័យយ៉ាងនេះ បណ្តាលមកពីអវិជ្ជា ពុំមែនយើងអ្នកមិនដឹង ឡើយ ។ ដើម្បីជំរះការដឹង ត្រូវលះបង់អវិជ្ជា មានអាសវៈ៤ ជាអាហារ ដោយការអប់រំចំរើនសតិប្បដ្ឋានវិបស្សនា ព្រោះ សតិប្បដ្ឋានមានសុច្ចរិត ៣ ជាហេតុជិតសំរាប់អាហារប្រចាំថ្ងៃ ជាប់ជានិច្ច ។ ការមានទ្រព្យសម្បត្តិ មានសេចក្តីសុខស្រួលក្នុង ខ្លួន គឺបុណ្យធ្លាប់សន្សំពីមុនមក ទោះបីសព្វថ្ងៃនេះ យើង ធ្វើកម្មល្អ បុណ្យកុសលក៏បានចំរើនរុងរឿង ជួយទំនុកបំរុង យើងទាំងក្នុងបច្ចុប្បន្ននិងក្នុងអនាគត បើសន្សំកម្មអាក្រក់ ផលហុចឱ្យក៏អាក្រក់ គ្រាន់តែថាយើងមិនដឹង ព្រោះអំពើបាប មិនទាន់ឱ្យផលប្រាកដ ។ ដូចជាការធ្វើកម្មណាមួយមិនត្រឹម ត្រូវតាមធម៌ មានការកេងប្រវ័ញ្ច បោកបញ្ឆោត ទទួលសំណូក

ជាដើម ថាជាអំពើនាំឱ្យបានទ្រព្យសម្បត្តិច្រើន យើងក៏យល់ថា ការប្រព្រឹត្តអំពើអាក្រក់នោះ ផ្តល់មកនូវការរីកចំរើន ។

មួយទៀត ដូចជាពួកឃាតករសម្លាប់សត្វលក់ មាន មាន់ ទា ជ្រូក គោ ក្របី ជាដើម ហើយស្រាប់តែមាន ទ្រព្យសម្បត្តិ ដូច្នោះ កម្មដែលបុគ្គលប្រព្រឹត្តនោះ គេយល់ថា ត្រឹមត្រូវ ព្រោះគេរកទទួលទានធ្វើអំពើបែបនោះចំរើន ដោយ ពុំបានទៅលួច ឆក់ ប្លន់ពីអ្នកណា ។ តាមពិត ការបាន ទ្រព្យសម្បត្តិច្រើន ព្រោះបានសន្សំបុណ្យចាស់ទុកអំពីអតីត មកទេ មិនមែនអំពើបាបនោះហុចផលល្អឱ្យឡើយ ។ តាម ធម្មជាតិ អំពើល្អនាំមកនូវភាពរីកចំរើន ឯអំពើអាក្រក់មិន ដែលរីកចំរើនទេ តែងតែផ្តល់ផលអាក្រក់រហេមរហាមគ្រប់ ពេល គ្រាន់តែមិនទាន់ឱ្យផល ព្រោះបើធ្វើកម្មណា កម្មនោះ សន្សំសន្តានទុកក្នុងចិត្តស្រេចទៅហើយ មិនចេះភ្លេចបាត់ ទៅណា ទោះបីទៅរស់នៅទីកន្លែងផ្សេងៗក៏ដោយ ក៏មិនអាច គេចផុតបានដែរ ដូចជាព្រះបាទអជាតសត្តុបានសម្លាប់ព្រះបិតា ត្រូវទទួលអន្តរិយកម្មអកុសលវិបាក ធ្វើកិច្ចបដិសន្ធិសោយទុក្ខ ក្នុងនរក។ កុសលធម៌ដែលចំរើនរុងរឿងក្នុងលោកនេះ មិន

ត្រឹមតែមានសទ្ធាទៅលើព្រះពុទ្ធសាសនាមួយប៉ុណ្ណោះទេ ទោះបីសាសនាដទៃក្តី ឱ្យតែអ្នកប្រព្រឹត្តិត្រឹមត្រូវល្អ នឹងបានទទួលផលល្អដូចគ្នា គ្រាន់តែថា សមណ: ៤ ពួក មានតែក្នុងព្រះពុទ្ធសាសនា អាចឆ្លងផុតលោកនេះបាន ដល់ព្រះនិព្វានចំណែកសាសនាដទៃ គ្មានសមណ: ៤ ពួកនេះ ដូចក្នុងព្រះពុទ្ធសាសនា ។ ម្យ៉ាងទៀតត្រូវគិតពិចារណាជិតដល់ពេលស្លាប់ ពេលនោះត្រូវខំបង្ខឹកហាត់ចិត្តឱ្យខ្លាំងកុំឱ្យរវើរវាយព្រោះពេលរៀបស្លាប់ បើចិត្តជាប់ជំពាក់ និង ឧទ្ធច្ចៈ( ភាពរវើរវាយ )ទោះបីបានធ្វើកុសលច្រើនយ៉ាងណាក៏ដោយ ពិតជាធ្លាក់ទៅអបាយភូមិមិនខាន បើមិនរវើរវាយ ពិតជាទៅកាន់សុគ្គតិភូមិ នេះជាការសន្សំសន្តានក្នុងជវនវិថីចិត្ត ។

## ព្រះដ៏មានព្រះភាគ

## ទ្រង់ព្យាករប្រស្នាព្រះឥន្ទ

**នៅក្នុងសុត្តន្តបិតក ទីឃនិកាយមហាវគ្គ ( សក្កបញ្ហាសូត្រ ) ភាគ ១៧ ទំព័រ ២១៥**

**សក្កទេវរាជា**-បពិត្រព្រះអង្គទ្រង់និរទុក្ខ ពួកទេវតា មនុស្ស អសុរ នាគ និង គន្ធព្វ ទាំងពួកជនច្រើនដទៃៗ មានធមិអ្វី ជាគ្រឿងចងរួបរិតទុក បានជាពួកសត្វទាំងនោះ សូម្បីប្រាថ្នា ថា សូមឱ្យយើងទាំងឡាយជាអ្នកមិនមានពៀរ មិនមានអាជ្ញា មិនមានសត្រូវ មិនមានព្យាបាទ នៅដោយ មិនមាន ពៀរនិងគ្នា ពួកសត្វទាំងនោះ តែងមានសេចក្តី ប្រាថ្នាយ៉ាងនេះឯង ទោះបីមានសេចក្តីប្រាថ្នា ក៏គង់សត្វ ទាំងនោះនៅតែជា អ្នកមានពៀរ មានអាជ្ញា មានសត្រូវ មានព្យាបាទ នៅដោយមានពៀរនឹងគ្នាដដែល ។

**ព្រះមានព្រះភាគ**- ព្រោះពួកសត្វទាំងនោះ មាន ឥស្សា (សេចក្តីច្រណែន) និងមច្ឆរិយៈ (សេចក្តីកំណាញ់) ។

**សក្កទេវរាជ**- សេចក្តីច្រណែន និងសេចក្តីកំណាញ់ មានអ្វីជាហេតុ មានអ្វីនាំឱ្យកើត មានអ្វីជាកំណើត មានអ្វី បណ្តាលឱ្យកើត ?

**ព្រះមានព្រះភាគ**- សេចក្តីច្រណែន និងសេចក្តីកំណាញ់ មានសេចក្តីស្រលាញ់ មានសេចក្តីស្អប់ ជាដើមជាហេតុ ។

**សក្កទេវរាជ**- ចុះសេចក្តីស្រលាញ់និងសេចក្តីស្អប់មានអ្វីជាដើមហេតុ មានអ្វីជាកំណើត មានអ្វីបណ្តាលឱ្យកើត ?

**ព្រះមានព្រះភាគ** -សេចក្តីស្រលាញ់នឹងសេចក្តីស្អប់មានឆន្ទះ( សេចក្តីពេញចិត្ត ) ជាដើមហេតុ ។

**សក្កទេវរាជ** - ចុះឆន្ទះមានអ្វីជាដើមហេតុ ។ល។ ?

**ព្រះមានព្រះភាគ** -បពិត្រទេវានមិន្ទ ឆន្ទះមានវិតក្កៈ ( សេចក្តីត្រិះរិះ) ជាដើមហេតុ ។ល។

**សក្កទេវរាជ** -ចុះវិតក្កៈមានអ្វីជាដើមហេតុ ។ល។ ?

**ព្រះមានព្រះភាគ** -បពិត្រទេវានមិន្ទ វិតក្កៈ មានចំណែកនៃបបញ្ចសញ្ញា ( សេចក្តីសំគាល់ប្រកបដោយធមិជាគ្រឿងឃឺតយូរ [(១)] ) ជាដើមហេតុ ។

---

១-សំដៅយកតណ្ហាវិបរិតទាំង១០៨ គឺ តណ្ហា មានៈ ទិដ្ឋិ

**សក្កទេវរាជ** -ចុះភិក្ខុប្រតិបត្តិយ៉ាងណា ទើបឈ្មោះថា ជាអ្នកប្រតិបត្តិ នូវបដិបទា ជាដំណើរដ៏សមគួរដល់សេចក្តីរលត់ នូវបបញ្ចសញ្ញា ?

**ព្រះមានព្រះភាគ** -បពិត្រទេវានមិន្ទ តថាគត សម្តែងថា សោមនស្សមាន ២ យ៉ាងគឺ សោមនស្សគួរសេព គប់ក៏មាន មិនគួរសេពគប់ក៏មាន បពិត្រទេវានមិន្ទ តថាគត សម្តែងថា ទោមនស្សមាន ២ យ៉ាង ទោមនស្សគួរសេពក៏មាន មិនគួរសេពគប់ក៏មាន បពិត្រទេវានមិន្ទ តថាគតសម្តែងថា ឧបេក្ខា មាន ២ យ៉ាង គឺឧបេក្ខាគួរសេពគប់ក៏មាន មិនគួរសេពគប់ក៏មាន ។

# សេចក្តីពិស្តារ

I-ព្រោះបណ្តាសោមនស្សទាំងពីរ ប្រការនោះ ភិក្ខុដឹងច្បាស់នូវសោមនស្សថា កាលបើអាត្មាអញសេពគប់នូវសោមនស្សនេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ ដូច្នេះសោមនស្សបែបនេះ [១] ភិក្ខុមិនគួរសេពគប់ ។ ផ្ទុយទៅវិញបណ្តាសោមនស្សទាំងពីរប្រការ កាលអាត្មាអញសេពគប់នូវសោមនស្សនេះហើយ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌តែងចំរើនឡើង ដូច្នោះសោមនស្សបែបនេះ [២] ភិក្ខុគួរសេពគប់ ។ ក្នុងសោមនស្សគួរសេពគប់នោះ សោមនស្សដែលមានវិតក្កៈវិចារក៏មាន [៣] សោមនស្សដែលមិន មានវិតក្កៈ

---

១-សំដៅយកគេហសិតសោមនស្ស គឺសោមនស្សអាស្រ័យនៅផ្ទះ (កាមគុណ៥) ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦

២-សំដៅយកនេក្ខម្មសិតសោមនស្សគឺសេចក្តីត្រេកអរ អាស្រ័យនូវនេក្ខម្ម(គឺការចេញចាកកាមគុណ ៥) របស់បុគ្គលដែលប្រកបដោយវិបស្សនា ។

៣-បានដល់សោមនស្សដែលកើតដោយអំណាចនេក្ខម្មៈ វិបស្សនាអនុស្សតិ និង បឋមជ្ឈាន ។

មិនមានវិចារៈក៏មាន[១] សោមនស្សណាដែលមិនមានវិតក្កៈមិនមានវិចារៈ សោមនស្ស នោះប្រសើរជាង ។

**II**-ទោមនស្សមាន ២ ប្រការ ទោមនស្សគួរសេពក៏មាន មិនគួរសេពក៏មាន ដូច្នេះ។ បណ្តាទោមនស្សទាំងពីរនោះ ភិក្ខុដឹងច្បាស់នូវទោមនស្សថា កាលបើអាត្មាអញសេពនូវទោមនស្សនេះ អកុសលធម៌តែងចំរើនដុះដាលឡើង កុសលធម៌តែងសាបសូន្យទៅដូច្នេះ ទោមនស្សបែបនេះ[២] ភិក្ខុមិនគួរសេព។ ឯទោមនស្សណា កាលបើអាត្មាអញសេពនូវទោមនស្សនេះ កុសលធម៌តែងចំរើនដុះដាលឡើង ដូច្នេះ អកុសលធម៌តែងសាបសូន្យទៅ ទោមនស្សបែបនេះ[៣] ភិក្ខុគួរសេព ។ ក្នុងទោមនស្សដែលគួរសេពនោះ ទោមនស្សដែល

---

១-បានដល់សោមនស្សដែលកើតដោយអំណាចទុតិយជ្ឈាន ។

២-សំដៅយកគេហសិតទោមនស្ស គឺទោមនស្សអាស្រ័យនៅផ្ទះ( កាមគុណ ៥) ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ របស់បុគ្គលដែលមិនបានទទួលនូវអារម្មណ៍ ជាទីគាប់ចិត្ត ។

៣-សំដៅយកនេក្ខម្មទោមនស្ស គឺទោមនស្សដែលអាស្រ័យនូវនេក្ខម្មៈដែល កើតឡើងដល់បុគ្គលទទួលអន់ចិត្តព្រោះហេតុតែក្របានសម្រេចនូវអរិយភូមិ ។

មាន វិតក្ក វិចារៈ [១] ក៏មាន ទោមនស្សដែលមិនមានវិតក្កៈ វិចារៈ [២] ក៏មាន ទោមនស្សណាដែលមិនមានវិតក្កៈ វិចារៈ ទោមនស្សនោះប្រសើរជាង ។

**III**-ឧបេក្ខាមាន ២ យ៉ាង ឧបេក្ខាគួរសេពក៏មាន មិនគួរសេពក៏មាន ។ បណ្ដាឧបេក្ខាទាំងពីរ ភិក្ខុដឹងច្បាស់នូវឧបេក្ខាណាថា កាលបើអាត្មាអញ សេពនូវឧបេក្ខានេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌តែងសាបសូន្យទៅដូច្នេះឧបេក្ខាបែបនេះភិក្ខុមិនគួរសេព [៣] ។ ចំណែកឧបេក្ខាណា កាលបើអាត្មាអញសេពនូវឧបេក្ខានេះ អកុសលទាំងឡាយតែងសាបសូន្យទៅ កុសលធម៌តែងចំរើន

---

១-បានដល់ទោមនស្សដែលកើតដោយអំណាចនេក្ខម្មៈវិបស្សនា អនុស្សតិ និងបឋមជ្ឈាន ។

២-បានដល់ទោមនស្សដែលកើតឡើងដ ល់បុគ្គលដែលប្រកបដោយវិបស្សនា ប្រាថ្នានូវអរហត្តផល បើទុកជាប្រឹងប្រែងយ៉ាងណាក៏នៅតែមិនសម្រេច ។

៣-បានដល់គេហសិតឧបេក្ខា គឺឧបេក្ខាអាស្រ័យនៅផ្ទះ( កាមគុណកើតឡើងដល់បុគ្គលល្ងង់ខ្លៅ) ក៏ជាប់ស្អិតក្នុង ឥដ្ឋារម្មណ៍ មិនមានត្រឡប់ថយក្រោយវិញ ដូចរុយដែលជាប់ចិត្តនឹងស្ករអំពៅ ។

ដុះដាលឡើង ឧបេក្ខាបែបនេះភិក្ខុគួរសេព [១] ។ ក្នុងឧបេក្ខា ដែលគួរសេពនោះ ឧបេក្ខាដែលមាន វិតក្កៈ វិចារៈ [២] ក៏មាន ឧបេក្ខាមិនមានវិតក្កៈវិចារៈ [៣] ក៏មាន, ឧបេក្ខាដែលមិនមានវិតក្កៈវិចារៈ ឧបេក្ខានោះប្រសើរជាង។ បពិត្រទេវរាមិន្ទ ភិក្ខុលុះតែប្រតិបត្តិយ៉ាងនេះទើបឈ្មោះថា ជាអ្នកប្រតិបត្តិនូវបដិបទា ជាដំណើរដ៏សមគួរដល់សេចក្តីរលត់នូវចំណែកបបញ្ចធម៌ ។

**សក្កទេវរាជ** -ចុះភិក្ខុប្រតិបត្តិដូចម្តេច ឈ្មោះថាអ្នកប្រតិបត្តិដើម្បីសង្រួមក្នុងបាតិមោក្ខ ?

**ព្រះមានព្រះភាគ**-បពិត្រទេវានមិន្ទ តថាគតសម្តែងថា កាយសមាចារ( មារយាទផ្លូវកាយ) មាន ២ យ៉ាង គឺកាយសមាចារ គួសេពក៏មាន មិនគួរសេពក៏មាន ។

---

១-បានដល់គេហស្សិតឧបេក្ខា គឺឧបេក្ខាដែលសម្បយុត្តដោយវិបស្សនាញាណមិនត្រេកអរនឹងឥដ្ឋារម្មណ៍ក៏មិនស្អប់អនិដ្ឋារម្មណ៍ដែរ ។

២-បានដល់ឧបេក្ខា ដោយគេហស្សិតវិបស្សនា អនុស្សតិ និងបឋមជ្ឈានជាដើម ។

៣-បានដល់ឧបេក្ខាដែលកើតដោយអំណាចឈាន មានទុតិយជ្ឈានជាដើម ។

វចីសមាចារ (មារយាទផ្លូវវាចា) មាន ២ យ៉ាង គឺវិចីសមាចារ ដែលគួរសេពក៏មាន មិនគួរសេពក៏មាន ។ បរិយេសនា (ការស្វែងរក) មាន ២ យ៉ាងគឺ បរិយេសនា គួរសេពក៏មាន មិនគួរសេពក៏មាន ។

## I-កាយសមាចារៈ

១) កាយសមាចារ ណា កាលបើអាត្មាអញសេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ ដូច្នេះកាយសមាចារបែបនេះភិក្ខុមិនគួរសេព (១) ។

២) ភិក្ខុដឹងច្បាស់នូវកាយសមាចារណា កាលបើអាត្មាអញសេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង ដូច្នេះ កាយសមាចារបែបនេះភិក្ខុគួរសេព (២) ។

---

១-ការប្រព្រឹត្តិបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារនិង ការប្រព្រឹត្តិកន្លង សិក្ខាបទជាបណ្ណត្តិវជ្ជៈចំពោះកាយទ្វារហៅថាកាយសសមាចារ ដែលមិនគួរសេព។

២-ការវៀរចាកអំពើអំបាបនោះ មានបាណាតបាតជាដើម ចំពោះកាយទ្វារ ហៅថា កាយសមាចារគួរសេព ។

## II-វចីសមាចារៈ

១-ភិក្ខុដឹងច្បាស់នូវវចីសមាចារណា កាលបើអាត្មាអញសេពនូវវចីសមាចារណា អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌តែងសាបសូន្យទៅ ដូច្នេះវចីសមាចារបែបនេះ ភិក្ខុមិនគួរសេព(១) ។

២-ភិក្ខុដឹងច្បាស់ នូវវចីសមាចារណាថា កាលបើអាត្មាអញសេពនូវវចីសមាចារនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើងដូច្នេះវចីសមាចារបែបនេះភិក្ខុគួរសេព(២) ។

## III-បរិយេសនា

១-ភិក្ខុដឹងច្បាស់ នូវបរិយេសនាណាថា កាលបើអាត្មាអញ សេពនូវបរិយេសនានេះ អកុសលធម៌ទាំងឡាយតែង

---

១-វចីទុច្ចរិត ៤យ៉ាង មានមុសាវាទជាដើម និងការប្រព្រឹត្តិកន្លងសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តិហើយ ចំពោះវចីទ្វារ ហៅថា វចីសមាចារដែលមិន គួរសេព ។

២-ការវៀរចាកវចីទុច្ចរិត ៤ យ៉ាង មិនប្រ ព្រឹត្តិកន្លងសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តិហើយចំពោះវចីទ្វារ ហៅថាវចីសមាចារដែលគួរសេព ។

ចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ ដូច្នេះ បរិយេសនា ភិក្ខុមិនគួរសេព [១] ។

២-ភិក្ខុដឹងច្បាស់ នូវបរិយេសនាណាថា កាលបើអាត្មាអញសេពនូវបរិយេសនានេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌តែងចំរើនដុះដាលឡើងដូច្នោះ បរិយេសនាបែបនេះភិក្ខុគួរសេព [២] ។

បពិត្រទេវានមិន្ទ ភិក្ខុអ្នកប្រតិបត្តិយ៉ាងណានេះ ទើបឈ្មោះថា ជាអ្នកប្រតិបត្តិ ដើម្បីសេចក្តីសង្រួមក្នុងបាដិមោក្ខ ។

**សក្កទេវរាជ** - ចុះភិក្ខុប្រតិបត្តិដូចម្តេច ទើបឈ្មោះថាអ្នកប្រព្រឹត្តិដើម្បីសេចក្តីសង្រួមក្នុងឥន្ទ្រិយ៍ ?

**ព្រះមានព្រះភាគ** -បពិត្រទេវានមិន្ទ តថាគតសម្តែងថា រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារមណ៏ ដែលគួរដឹងមាន ២ យ៉ាង គឺ ១

១-បានដល់អនរិយបរិយេសនា ការស្វែងរកមិនប្រសើរ គឺការស្វែងរកបុត្រភរិយា ទ្រព្យជាដើម ។

២-អរិយបរិយេសនា ការរ្វែងរកដ៏ប្រសើរគឺការស្វែងរក ព្រះនិព្វាន ។

មិនគួរសេព ១ ទៀតគួរសេពក៏មាន ។ ធមិសង្ខេបនេះ សក្កទេវរាជ អាចដឹងដោយពិស្តារបាន ។

**សក្កទេវរាជ**- ចុះពួកសមណព្រាហ្មណ៍ទាំងអស់ សុទ្ធតែជាអ្នកមានវាទៈដូចគ្នា មានមារយាទដូចគ្នា មានឆន្ទៈនិងលទ្ធិដូចគ្នា មានសេចក្តីចូលចិត្តដូចគ្នា ឬ ?

**ព្រះមានព្រះភាគ**-បពិត្រទេវានមិន្ទ ពួកសមណព្រាហ្មណ៍ទាំងអស់មិនមែនមានវាទៈដូចគ្នាទេ មិនមែនមានមារយាទដូចគ្នាទេ មិនមែនមានឆន្ទៈគឺលទ្ធិដូចគ្នាទេ មិនមានសេចក្តីចូលចិត្តដូចគ្នាទេ ។

**សក្កទេវរាជ** - ចុះព្រោះហេតុអ្វី ?

**ព្រះមានព្រះភាគ**-លោកគឺពួកសត្វមានធាតុ គឺអធ្យាស្រ័យច្រើនពន់ពេក មានធាតុផ្សេងៗគ្នា ក្នុងលោកដែលមានច្រើនមានធាតុផ្សេងនោះ សត្វទាំងឡាយប្រកាន់មាំនូវធាតុ គឺ អធ្យាស្រ័យណាៗក៏ប្រកាន់មាំនូវធាតុ គឺអធ្យាស្រ័យនោះៗ ដោយកំលាំងចិត្ត និងការស្ទាបអង្អែលដែល ពោលនូវពាក្យ នេះថាជាពាក្យពិត ពាក្យដទៃជាមោឃៈ

ឥតប្រយោជន៍ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ទាំងអស់មានវាទៈមិនដូចគ្នា មានមារយាទមិនដូចគ្នា មានឆន្ទៈ គឺលទ្ធិមិនដូចគ្នា មានសេចក្តីចូលចិត្តមិនដូចគ្នា ។ល។

**សក្កទេវរាជ**-ចុះពួកសមណព្រាហ្មណ៍ទាំងអស់ សុទ្ធតែមានសេចក្តីសំរេចគឺនិព្វាន ទៀងប្រាកដ មានធម៌ជាគ្រឿងអស់ទៅនៃយោគៈពិតប្រាកដ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀងប្រាកដ ជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀងប្រាកដ ឬ ?

**ព្រះមានព្រះភាគ**-បពិត្រទេវានមិន្ទ សមណ-ព្រាហ្មណ៍ទាំងអស់ មិនដូចនេះទេ ភិក្ខុទាំងឡាយណាដែលមានចិត្តចុះស៊ប់ក្នុងព្រះនិព្វាន ជាទីអស់ទៅនៃតណ្ហា ភិក្ខុទាំងឡាយនោះ ឈ្មោះថាជាអ្នកមានសេចក្តីសម្រេច គឺព្រះនិព្វានទៀងប្រាកដ ជាអ្នកមានធម៌ជាគ្រឿងអស់ទៅនៃយោគៈ ទៀងប្រាកដ ជាអ្នកប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀងប្រាកដ ជាអ្នកមានទីបំផុតគឺព្រះនិព្វានទៀងប្រាកដ ព្រោះមានហេតុនោះឯងបានជាថា ពួកសមណ-ព្រាហ្មណ៍ទាំងនោះមិនមែនសុទ្ធ តែជាអ្នកមានសេចក្តីសំរេច



ព្រះដ៏មានព្រះភាគទ្រង់ព្យាករប្រស្នាព្រះឥន្ទ

គឺព្រះនិព្វានទៀងប្រាកដ មិនមែនជាអ្នកមានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀងប្រាកដ មិនមែនជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរទៀងប្រាកដ មិនមែនជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀងប្រាកដ ទាំងអស់គ្នាឡើយ ។

**សក្កទេវរាជ**-បពិត្រព្រះអង្គដ៏ចំរើន សេចក្តីញាប់ញ័រគឺតណ្ហាទុកដូចជារោគ ទុកដូចជាបូស ទុកដូចជាកូនសរ តែងដឹកទាញនូវបុរសនេះឱ្យកើតក្នុងភពនោះៗ ព្រោះហេតុនោះឯង បុរសនេះរមែងដល់នូវសេចក្តីខ្ពស់ទាប ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបាននៅឱកាសកម្មនៃប្រស្នាណា អំពីសំណាក់ព្រាហ្មណ៍ដទៃខាងក្រៅព្រះពុទ្ធសាសនានេះ ប្រស្នានោះ ព្រះមានព្រះភាគអ្នកឃើញនូវកាលដ៏វែង បានព្យាករដល់ខ្ញុំព្រះអង្គហើយ មួយទៀតព្រះមានព្រះភាគបានដកនូវសរគឺសេចក្តីសង្ស័យនិងសេចក្តីងឿងឆ្ងល់ ពីខ្ញុំព្រះអង្គចេញបានហើយ ។

**ព្រះមានព្រះភាគ**-បពិត្រទេវានមិន្ទ មហាបពិត្រធ្លាប់ យកប្រស្នានេះទៅសួរចំពោះពួកសមណព្រាហ្មណ៍ដទៃដែរឬទេ?

**<u>សក្កទេវរាជ</u>**-បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គធ្លាប់យកប្រស្នានេះទៅសួរចំពោះសមណព្រាហ្មណ៍ដទៃដែរ ប៉ុន្តែសមណព្រាហ្មណ៍ក៏មិនអាចដោះស្រាយបាន ហើយក៏ត្រឡប់សួរមកខ្ញុំព្រះអង្គវិញថា អ្នកដ៏មានអាយុ ឈ្មោះអ្វី ? ខ្ញុំនេះឯងជាសក្កទេវរាជ ជាធំជាងពួកទេវតា ។ ចុះព្រះអង្គសាងនូវអំពើដូម្តេច ? បានជាដល់នូវឋានៈដូច្នេះ ។ ខ្ញុំព្រះអង្គក៏សម្តែងធម៌ (វត្តបទ ៧ យ៉ាង) បានស្តាប់ធម៌នេះហើយ ពួកសមណព្រាហ្មណ៍នោះ ក៏ត្រឡប់ជាសាវ័ករបស់ខ្ញុំព្រះអង្គវិញ ឯខ្ញុំព្រះអង្គមិនមែនជាសាវ័ករបស់ពួកសមណព្រាហ្មណ៍នោះទេ ខ្ញុំព្រះអង្គជាសាវ័ករបស់ព្រះមានព្រះភាគ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានប្រាជ្ញាជាគ្រឿងត្រាស់ដឹង ប្រព្រឹត្តទៅក្នុងខាងមុខ ។

**<u>ព្រះមានព្រះភាគ</u>**-បពិត្រទេវានមិន្ទ ក្នុងកាលពីមុនអំពីកាលនេះ មហាបពិត្រ ធ្លាប់បានទទួលនូវសេចក្តីត្រេកអរ និងសោមនស្សបែបនេះដែរឬទេ ?

**សក្កទេវរាជ** -ខ្ញុំព្រះអង្គធ្លាប់បានទទួលនូវរឿងកើតសង្គ្រាមជាមួយពួកទេវតា និងអសុរបានតទល់គ្នាហើយ ។ ក៏

ក្នុងសង្គ្រាមនោះ ពួកទេវតាឈ្នះ ពួកអសុរចាញ់ ។ ពួកទេវតាទាំងឡាយ នឹងបរិភោគនូវឱជារសទាំងពីរ គឺឱជារសរបស់ទេវតានិងឱជារសរបស់អសុរ ក្នុងទេវលោកនេះ បពិត្រព្រះមានព្រះភាគដ៏ចំរើន ការបាននូវសេចក្ដីត្រេកអរ និងការបាននូវសេចក្ដីសោមនស្សរបស់ខ្ញុំព្រះអង្គនោះ សឹងប្រកបដោយគ្រឿងវាយដំ ប្រកបដោយគ្រឿងកាប់ចាក់ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ ដើម្បីការប្រាស់ចាកតម្រេក (រាគៈ) ដើម្បីការរំលត់ទុក្ខ ដើម្បីការស្ងប់ស្ងាត់ ដើម្បីការដឹងចំពោះ ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វានឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ចំណែកខាងការបាននូវសេចក្ដីត្រេកអរនិងការបាននូវសោមនស្សណារបស់ព្រះអង្គ ព្រោះស្ដាប់ធមិរបស់ព្រះមានព្រះភាគ ការបាននោះតែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ ដើម្បីការប្រាស់ចាករាគៈ ដើម្បីការរំលត់ទុក្ខ ដើម្បីការស្ងប់រម្ងាប់ ដើម្បីការដឹងចំពោះ ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វានតែម្យ៉ាង ។

**ព្រះមានព្រះភាគ**-បពិត្រទេវានមិន្ទ ចុះមហាបពិត្រ ទ្រង់ឃើញនូវអំណាចនៃប្រយោជន៍ដូចម្ដេច ទើបបាន

សម្តែងនូវការបាននូវសេចក្តីត្រេកអរ និងសោមនស្សមាន សភាព យ៉ាងនេះ ។

**សក្កទេវរាជ**-បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញ នូវអំណាចនៃប្រយោជន៍ ៦ យ៉ាងគឺៈ

១-អាត្មាភាពកើតជាទេវតា បាននូវអាយុថ្មី ។

២-ចិត្តរបស់ខ្ញុំព្រះអង្គត្រេកអរក្នុងត្រកូលណា ក៏ច្យុតទៅកាន់គភ៌ក្នុងត្រកូលនោះ ។

៣-ខ្ញុំព្រះអង្គជាអ្នកត្រេកអរក្នុងសាសនារបស់ព្រះពុទ្ធ ជាម្ចាស់ ។

៤-ការបាននូវសម្ពោធិញ្ញាណ (សំដៅយកសកទាគាមិ មគ្គ (អដ្ឋកថា)) ។

៥-ការបានទៅកើតនៅទេវលោក (មុខជាច្យុតពី មនុស្ស ទៅកើតជាទេវលោក) ។

៦-ច្យុតទៅកើតជាទេវតា ឧត្តមជាងទេវតាទាំងពួង (អដ្ឋកថា ព្រះឥន្ទមុខជានឹងបាននូវអនាគាមិមគ្គ ) លុះច្យុត ពីអត្តភាពនេះទៅ នឹងបានទៅកើតក្នុងសុទ្ធាវាសៈ មាន អវិហាអកនិដ្ឋភពជាទីបំផុត ។ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គជាអ្នករួច

ចាកភ័យហើយ ដោយបានចូលមកអង្គុយជិតព្រះសម្ពុទ្ធ ។ ខ្ញុំព្រះអង្គសូមថ្វាយ បង្គំនូវព្រះសម្ពុទ្ធ ទ្រង់ដកចោលនូវសរ គឺតណ្ហាចេញបានហើយ រកបុគ្គលប្រៀបផ្ទឹមគ្មាន ទ្រង់មានការ ព្យាយាមច្រើន ទ្រង់ត្រាស់ដឹងធម៌(នូវចតុរារិយសច្ច) ព្រះអង្គ ជាពូជពង្សនៃអទិច្ចគោត្រ ។ គ្រានោះសក្កទេវរាជ ទ្រង់យក ព្រះហត្ថទះផែនដី ហើយបន្លឺនូវឧទានអស់វារៈ ៣ ដង ថា:

*សូមនមស្ការ ថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធអង្គនោះ ។*

*សូមនមស្ការ ថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធអង្គនោះ ។*

*សូមនមស្ការ ថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធអង្គនោះ ។*

នេះជាការបញ្ជាក់នូវពាក្យព្យាករណ៍របស់ព្រះសម្ពុទ្ធ ដែលមានច្រើនទៀត ។ ដូចជាទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា និង គតិ និងបុណ្យជាដើម ។

រួមសេចក្ដីមកឃើញថា ក្រោយពីព្រះសម្ពុទ្ធបានព្យាករ សុមេធតាបសរួច ក៏បានសំរេចជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ក្នុងភទ្ទកប្បនេះ ចំណែកសក្កទេវរាបានជាព្រះអនាគាមិ ឯព្រះបាទបសេនកោសល បានតាំងនៅក្នុងសីល ៥ ។ ពាក្យព្យាករណ៍ ជាវិស័យនៃព្រះសម្មាសម្ពុទ្ធទើបសម្ដែងបាន អ្នកដទៃក្រៅពីនេះមិនងាយ ។ គួររក្សាតម្លៃពាក្យព្យាករណ៍ ដែលថា ក្នុងសម័យបច្ចុប្បន្ននេះ តើមាននរណាខ្លះព្រះពុទ្ធព្យាករ ? យើងមិនអាចដឹង ។

# ចប់

# អនុវាទអស់អស់

លោកនេះធំធេងល្វឹងល្វើយពេកក្រៃ ពុំមានតម្លៃពាក្យព្រះទ្រង់ញាណ
ចង្អៀតចង្អល់ឈឺចាប់ស្រែកឃ្លាន រាល់ពេលពុំមានស្រាកស្រាន្តត្រង់ណា ។
បានអ្វីមិនល្មមមិនចេះគ្រប់គ្រាន់ មានប្រាក់លានពាន់ចិត្តនៅសាវ៉ា
ប្រឹងត្រិះរិះគិតតាមចិត្តប្រាថ្នា បំពេញតណ្ហាជាធម៌ថោកទាប ។
ធម៌នេះទាំងអស់មានត្រឹមប្រាំបី បងប្អូនប្រុសស្រីខ្ញុំសូមជំរាប
លោកធម៌ទីមួយគេថាបានលាភ លោភៈចងគាបជាប់ក្នុងចំណង ។
លោកធម៌ទីពីរគេថាអត់លាភ ក្រីក្រមានភាពអួរអាប់កន្លង
ជ្រួលច្របល់ចិត្តដូចភ្លើងទាំងកង ដុតខ្លួនឯងផងវិនាសអន្តរាយ ។
លោកធម៌ទីបីគេថាមានយស ប្រសើរខ្ពង់ខ្ពស់លើសអ្នកទាំងឡាយ
ចង់ត្រូវការអ្វីគេជួយខ្វល់ខ្វាយ ជ្រោមជ្រែងដោះស្រាយទៅតាមបុណ្យស័ក្តិ ។
លោកធម៌ទី៤គេថាអត់យស ពាក្យមិនពិរោះមិនសូវរាក់ទាក់
ទាំងនិយាយស្តីខ្លួនប្រាណក៏ធ្លាក់ អន់ថយអស់លក្ខណ៍គ្មានអ្វីទីពឹង ។
លោកធម៌ទី៥គេថាបានសុខ បានស្រួលស្រណុកធ្វើចិត្តនឹងធឹង
មានញាតិមានមិត្តគេតែងសម្លឹង រាប់រកសញ្ជឹងមេត្តាដល់យើង ។
លោកធម៌ប្រាំមួយគេថាមានទុក្ខ ក្រៀមក្រំសំកុកដូចជាប់ឃ្នាស់ជើង
ចង់ដើរទៅណាដូចរងើកភ្លើង មិនតាមទំនើងចិត្តរបស់វា ។
លោកធម៌ប្រាំពីរមានគេសរសើរ ធ្វើឫកគ្រាន់បើនិយាយមិនរា
ផ្លូវចិត្តខាងក្នុងក៏មិនរងារ ខំប្រឹងស្មុះស្មារក្លាហានអស្ចារ្យ ។
លោកធម៌ប្រាំបីមានគេនិន្ទា ធ្វើអ្វីរួញរាមិនសូវបានការណ៍

ព្រោះតែតូចចិត្តខ្វះភាពសង្ខារ ដោយគ្មាននរណាជួយជំរុញចិត្ត ។
គួរជួយដាសតឿនជួយក្រើនរំលឹក រាល់ពេលយប់ព្រឹកបង្ខំបង្ខិត
ពាក្យល្អមានន័យពិរោះជាប់ចិត្ត ជួយផ្តល់គំនិតបានបុណ្យច្រើនណាស់ ។
លោកធម៌ទាំងនេះធ្វើឱ្យវង្វេង វិលវល់ទាំងក្មេងព្រមទាំងមនុស្សចាស់
ជ្រប់ងប់នឹងលោកភូតភរបោកប្រាស មិនរើបម្រាស់នាំតែចង្រៃ ។
ទិដ្ឋិយល់ខុសថាមានតួខ្លួន ប្រកាន់មាំមួនមិនដាច់អាល័យ
ទៅលើបញ្ចក្ខន្ធដូចពេជ្រចរណៃ ខំគិតកែឆ្នៃគ្រប់ពេលវេលា ។
ខន្ធ៥ជាទុក្ខព្រះទ្រង់សម្តែង ដូចជាសូរ្យសែងបំភ្លឺគ្រប់គ្នា
ឱ្យរត់គេចចេញអំពីខន្ធមារ កុំនៅវេរានេបនិត្យគៀកកើយ ។
ខន្ធ៥សម្លាប់មិនដែលបានសុខ ពិតជាសំបុក្រមេរោគត្រាំត្រើយ
ឱ្យឈឺរ៉ាំរៃពុំជាសះស្បើយ នេះជាចម្លើយឆ្លើយប្រាប់ដល់គ្នា ។
រឿងនេះពុំមានអ្នកណាបានដឹង បើមិនខំប្រឹងមានព្យេរវេរា
ជាប់តាមជានិច្ចរស់នៅកំព្រា គ្មានអ្វីការពាររហេមរហាម ។
លុះមានព្រះពុទ្ធទ្រង់ប្រោសទេសនា ទើបដឹងជាក់ថាត្រូវបដិបត្តិតាម
បន្តិចម្តង១ចេញចាកពីកាម ហៅថាសំរាមដែលគេបោះចោល ។
កុសលជួយច្រានរំលឹកស្មារតី ជាប្រក្រតីពុំមានទោសថ្កោល
មិនជំពាក់ចិត្តទៅលើស្រមោល ប្រឹងរត់ប្រឹងបោលទើបឆាប់ដល់ត្រើយ ។
វិបល្លាសមួយទៀតយល់ថាល្អស្អាត ក្នុងរបស់មិនស្អាតយកធ្វើជាខ្មើយ
ដាក់លើដំណេកគ្រែសំរាប់កើយ សម្រាន្តរួចហើយទុកដាក់ត្រឹមត្រូវ ។
របស់ក្នុងលោកសុទ្ធតែមិនទៀង គេយល់ថាទៀងឋិតថេរគង់នៅ
ហៅថាវិបល្លាសប្រាកដត្រឹមត្រូវ នេះហើយជាផ្លូវទៅរកអបាយ ។
លោកនេះជាទុក្ខភ្លើងក្តៅគគុក បែរយល់ថាសុខ នាំគ្នាសប្បាយ
ពុំមានគំនិតគិតគួរវែងឆ្ងាយ បោះបង់កុំស្តាយពីធម៌វិបល្លាស ។

ផ្លូវលោកផ្លូវធម៌មិនដូចគ្នាទេ ត្រូវគិតគ្នាន់គ្នេរប្រយ័ត្នវិនាស
បើយល់ច្រឡំធ្វើហេតុទំនាស់ ខូចខាតរបស់នាំឱ្យនឹកស្តាយ ។
ត្រូវចែកឱ្យដាច់មួយណាផ្លូវលោក ព្រះទ្រង់មានជោគទូន្មានបរិយាយ
ស្តាប់ពុទ្ធោវាទរកកលឧបាយ យកធម៌ទាំងឡាយទៅពិចារណា ។
មានតែផ្លូវធម៌ចម្រើនបានសុខ មង្គលគ្រប់មុខរាល់គ្រប់កិច្ចការ
យកធម៌ទីពឹងគ្រប់៧អាត្មា ព្រះពុទ្ធដីកាមិនដែលខុសឡើយ ។
បើអ្នកតម្កល់តាំងចិត្តមិនត្រង់ ទៅតាមចំណង់គ្មានពេលធូរស្បើយ
ទុក្ខធ្ងន់ក្រៃលែងពុំមានល្ហែល្ហើយ ទោសទាំងនេះហើយហៅថាផ្លូវលោក ។
គ្មានអ្វីប្រសើរជាជាងមានធម៌ ត្រេកអរសាទរជាស្រឡះរោគ
រោគនៅក្នុងកាយមានច្រើនគរគោក គរដូចដំបូកអាចសះស្បើយបាន ។
ព្រះធម៌មានគុណធ្ងន់ជាងប្រថពី ប្រណមអញ្ជលីលើកដៃគ្រប់ប្រាណ
បង្គំថ្វាត់ថ្វាយជ្រះថ្លាក្សេមក្សាន្ត បានផលចំណោនគ្មានអ្វីគណនា ។
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃទាំងបី តែងមានមេត្រីស្រឡាញ់គ្រប់គ្នា
សូមបង្អោនចិត្តគោរពបូជា មិនឱ្យឃ្លាតឃ្លាពីរតនត្រៃ ។
គុណកែវវិសេសរកអ្វីប្រៀបគ្មាន នូវពាក្យទូន្មានប្រសើរថ្លាថ្លៃ
សូមយកទីពឹងរាល់ពេលយប់ថ្ងៃ ជាទីអាស្រ័យទុកក្នុងសន្តាន ។
ផ្លូវលោកសំរាប់តែពេលរស់នៅ លុះដល់ស្លាប់ទៅយកអ្វីមិនបាន
មាសប្រាក់កែវកងពិទូរ្យសូរកាន សូម្បីខ្លួនប្រាណយកមិនបានផង ។
មានតែវិបាកនាមកូន្ធ៤ ធ្វើកិច្ចមាំមួនរងចាំជួយត្រង
ចុតិភ្លាមបដិសន្ធិឆ្លង ភវង្គចម្បងតម្រង់ភពជាតិ ។

# ចប់

## មេរៀនជីវិត

ើបានជាចេះៗឱ្យគេកោត បើបានជាឆោតៗប្រឹងឧស្សាហ៍
ៀនសូត្រតាមក្បួនវិន័យធម៌អាថ៌ កើតមានបញ្ញាជួយខ្លួនឯងរួច។
ស្រួតចង់បានមិនដឹងខុសត្រូវ អាចដើរខុសផ្លូវទឹកវល់លិចគួច
ូវរស់ដោយល្អទ្រព្យគេមិនលួច មានអ្វីតិចតួចប្រើប្រាស់ធម្មតា។
នមែនសំខាន់ត្រង់មានទ្រព្យច្រើន បើមិនចម្រើនខាងការសិក្សា
ណធម៌ប្រណីតឧត្តមថ្លៃថ្លា ចិត្តស្អាតជ្រះថ្លាសុខស្ងប់រាល់ថ្ងៃ។